EarthRights International

# Environmental Impact Assessment in the Mekong Region

MATERIALS AND COMMENTARY (FIRST EDITION)
OCTOBER 2016

Cambodia

# ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់មេគង្គ

ឧបករណ៍ច្បាប់ផ្សេងៗនិងសេចក្តីពន្យល់ (ការបោះពុម្ពលើកទី១)
ខែតុលាឆ្នាំ២០១៦

ប្រទេសកម្ពុជា



ការងារនេះអាចដំណើរការទៅបានដោយមានការគាំទ្រពីប្រជាជនអាមេរិក តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ (USAID) ភាពជាដៃគូសម្រាប់កម្មវិធីបរិស្ថានទន្លេមេគង្គ។

ខ្លឹមសារដូចមានបង្ហាញនៅក្នុងឯកសារនេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ទីភ្នាក់សហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ ឬរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកទេ។

អក្សរកាត់

| | |
|---|---|
| ធអអ (ADB) | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| អាស៊ាន (ASEAN) | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of South East Asian Nations) |
| អសស (CSO) | អង្គការសង្គមស៊ីវិល (Civil Society Organisation) |
| វប (EA) | ការវាយតម្លៃបរិស្ថាន (Environmental Assessment) |
| វបប (ECC) | វិញ្ញាបនបត្រប្រតិបត្តិបរិស្ថាន (Environmental Compliance Certificates) |
| វហបស (EHIA) | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសុខភាព (Environmental and Health Impact Assessment) |
| វហប (EIA) | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (Environmental Impact Assessment) |
| ផពគប (EMMP) | ផែនការពិនិត្យតាមដាន និងគ្រប់គ្រងបរិស្ថាន (Environmental Management and Monitoring Plan) |
| ផគប (EMP) | ផែនការគ្រប់គ្រងបរិស្ថាន (Environmental Management Plan) |
| វហសប (ESIA) | ការវាយតម្លៃហេតុប៉ះពាល់សង្គមនិងបរិស្ថាន (Environmental and Social Impact Assessment) |
| ផពគសប (ESMMP) | ផែនការពិនិត្យតាមដាននិងគ្រប់គ្រងសង្គមនិងបរិស្ថាន (Environmental and Social Management and Monitoring Plans) |
| មអម (GMS) | មហាអនុតំបន់ទន្លេមេគង្គ (Greater Mekong Subregion) |
| សអវផ (IAIA) | សមាគមអន្តរជាតិដើម្បីវាយតម្លៃហេតុប៉ះពាល់ (International Association for Impact Assessment) |
| សអចស (IAP2) | សមាគមអន្តរជាតិដើម្បីការចូលរួមជាសាធារណៈ (International Association for Public Participation) |
| វបប (IEE) | ការវាយតម្លៃបរិស្ថានដំបូង (Initial Environmental Evaluation) |
| វបផប (IEIA) | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (Initial Environment Impact Assessment) |
| ក.ស្ថ (MoE) | ក្រសួងបរិស្ថាន (Ministry of Environment) |
| គទម (MRC) | គណៈកម្មការទន្លេមេគង្គ (Mekong River Commission) |

អមរ (NGO) អង្គការមិនមែនរដ្ឋាភិបាល (Non-Government Organisation)

កផបធ (ONEP) ការិយាល័យផែនការនិងគោលនយោបាយបរិស្ថាននិងធនធានធម្មជាតិ (Office of Natural Resources and Environmental Policy and Planning)

ពផគ (PAP) ពលរដ្ឋរងផលប៉ះពាល់ដោយសារគម្រោង (Project Affected Persons)

ជមពពម (PNPCA) ការជូនដំណឹងមុន ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (Prior Notification, Prior Consultation and Agreement)

វយប (SEA) ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (Strategic Environmental Assessment)

វផស (SIA) ការវាយតម្លៃហេតុប៉ះពាល់សង្គម (Social Impact Assessment)

លក (ToR) លក្ខខណ្ឌបំពេញការងារ (Terms of Reference)

អប (UN) អង្គការសហប្រជាជាតិ (United Nations)

គសអបអ (UN ECE) គណៈកម្មាធិការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិតំបន់អឺរ៉ុប (United Nations Economic Commission for Europe)

កបអប (UNEP) កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ (United Nations Environment Programme)

## មាតិកា


សេចក្តីផ្តើមអំពីការបោះពុម្ពលើកទី១ ..... 1

សេចក្តីថ្លែងអំណរគុណ ..... 3

អាស៊ាននិងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... 4

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ..... 4

សិទ្ធិមនុស្ស ..... 5

តើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាអ្វី? ..... 6

គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... 6

លក្ខណៈសំខាន់ៗនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិដ្ឋាន ..... 10

គោលការណ៍សំខាន់ៗនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ..... 13

ដំណើរការដែលបង្កើតឡើងដោយស្របច្បាប់ ច្បាស់លាស់ និងប្រសិទ្ធភាព ..... 13

អ្នកស្នើសុំរ៉ាប់រងចំណាយលើដំណើរការអនុវត្តនិងវាយតម្លៃ ..... 13

ការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យនៅគ្រប់ជំហាននៃដំណើរការ ..... 14

ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធត្រូវតែអាចទទួលបានព័ត៌មាន ..... 15

ត្រូវមានព័ត៌មានពាក់ព័ន្ធទាំងអស់ ..... 15

ការធ្វើសេចក្តីសម្រេចចិត្តដោយបើកចំហ និងមានភស្តុតាងជាមូលដ្ឋាន ..... 15

ការពិនិត្យតាមដាន ការប្រតិបត្តិ និងការពង្រឹងការអនុវត្តដែលមានប្រសិទ្ធភាព ..... 16

យន្តការសំខាន់ៗសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... 17

ការពឹងផ្អែកលើបណ្តាវិធីសាស្ត្របែបចូលរួម ..... 17

ការអនុវត្តគោលការណ៍បង្ការទុកមុន ..... 18

ការអនុវត្តគោលការណ៍សមធម៌មនុស្សអន្តរជំនាន់ ..... 18

ការអភិរក្សជីវចម្រុះ និងបូរណភាពអេកូឡូស៊ីគឺជាការគិតពិចារណាជាចម្បង ..... 18

ការវាយតម្លៃ ការកំណត់តម្លៃ និងការលើកទឹកចិត្តកាន់តែល្អប្រសើរ ..... 19

ការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... 19

អត្ថន័យអំពីការចូលរួមជាសាធារណៈ ..... 24

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងការអនុវត្តជាក់ស្តែងនៅតំបន់ទន្លេមេគង្គ ..... 27

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតំបន់ទន្លេមេគង្គ ..... 28

ជំហានក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... **30**
ជំហានទី ១៖ ការពិនិត្យ ...... 31
ជំហានទី ២៖ ការកំណត់វិសាលភាព ...... 32
ជំហានទី ៣៖ ការៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... 36
ជំហានទី ៤៖ ការពិនិត្យនិងការវាយតម្លៃលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... 37
ជំហាទី ៥៖ ការអនុម័តរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... 38
ជំហានទី ៦៖ ការពិនិត្យតាមដាន និងការប្រតិបត្តិ ...... 39
ព្រះរាជាណាចក្រកម្ពុជា ...... **47**
សេចក្តីផ្តើម ...... **47**
នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ...... **55**
ការប្រតិបត្តិ និងការពង្រឹងការអនុវត្ត ...... **61**
ការពិនិត្យតាមដាននិងការប្រតិបត្តិ ...... **62**
បណ្តាបញ្ហាឆ្លងដែនក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ...... **64**
**អនុសញ្ញាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែន (អនុសញ្ញាអ៊ែស្ពូ) ...... 67**
**ពិធីសារស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ...... 68**
**អនុសញ្ញាស្តីពីសិទ្ធិទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេច និងសិទ្ធិទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន (អនុសញ្ញាអាហ៊ូស) ...... 69**
**កិច្ចព្រមព្រៀងទន្លេមេគង្គ ...... 71**
នីតិវិធីជូនដំណឹង ពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ...... 73
ការពិចារណាអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយគណៈកម្មការទន្លេមេគង្គ ...... 75
**កិច្ចព្រមព្រៀងបរិស្ថានមហាអនុតំបន់ទន្លេមេគង្គ ...... 77**
**លក្ខខណ្ឌតម្រូវឲ្យមានប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដោយប្រសិទ្ធភាព ...... 78**
ការសង្ខេបបញ្ចប់គំនិតអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតាមបណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គ ...... 81

ឧបសម្ព័ន្ធ ១៖ តារាងរៀបរាប់ចំណុចសំខាន់ៗនៃគម្រោង ..... **84**

ឧបសម្ព័ន្ធ ២៖ ច្បាប់ពាក់ព័ន្ធ ..... **87**

ឧបសម្ព័ន្ធ ៣៖ ប្រភពបន្ថែម ..... **88**

បញ្ជីពិនិត្យសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការពិនិត្យបរិស្ថានដំបូង នៅក្នុងប្រទេសមួយចំនួននៃតំបន់ទន្លេមេគង្គ ..... **88**

សេចក្តីព្រាងគោលការណ៍ណែនាំថ្នាក់តំបន់ស្តីពីការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... **88**

សេចក្តីព្រាងគោលការណ៍ណែនាំរបស់ប្រទេសកម្ពុជា ស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ..... **88**

កំណត់សម្គាល់របស់អ្នកនិពន្ធ៖ *នេះគឺជាឯកសារជាក់លាក់អំពីប្រទេសកម្ពុជា ដែលដកស្រង់ចេញពីឯកសារសៀវភៅធំមួយដែលមានសេចក្តីលម្អិតអំពីប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃប្រទេសទាំងប្រាំមួយនៃតំបន់ទន្លេមេគង្គ។ ចំពោះ ឯកសារសៀវភៅធំពេញលេញ និងសម្រង់ជាក់លាក់អំពីប្រទេសផ្សេងៗទៀត លោកអ្នកអាចរកអានបានតាមអាសយដ្ឋាននេះ៖* https://www.earthrights.org/publications

## សេចក្តីផ្តើមអំពីការបោះពុម្ពលើកទី១

ដោយនេះជាគម្រោងដែលមានមហិច្ឆតាយ៉ាងធំតាំងពីដំបូង ដូច្នេះរហូតមកដល់ពេលនេះ វាជាការអនុវត្តមួយយ៉ាងលំបាក ក្នុងការបញ្ចូលគ្នាឲ្យទៅជាសៀវភៅតែមួយនូវការវិភាគអំពីប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃបណ្តាប្រទេសទាំងប្រាំមួយក្នុងតំបន់ទន្លេមេគង្គ។ នេះជាលើកទីមួយហើយ ដែលគេបានព្យាយាមបញ្ចូលគ្នា ដោយមានសេចក្តីយោងលើប្រធានបទនិងវិធីសាស្ត្ររួម ក្នុងចំណោមបណ្តាប្រទេសទាំងប្រាំមួយ។

នេះក៏ជាគម្រោងដំបូងដែរ ដែលត្រូវបានអនុវត្តដោយបណ្តាញអង្គការច្បាប់តំបន់ទន្លេមេគង្គ ដោយមានកិច្ចសហការជាមួយអង្គការអឺត្សរ៉ៃយថ៍អន្តរជាតិ (EarthRights International)។ ជាលទ្ធផល គឺមានការរៀនសូត្រច្រើនតាមរយៈដំណើរការនៃកិច្ចសហការនិងការប្រមូលព័ត៌មានពីភាគីពាក់ព័ន្ធទាំងអស់ តាំងពីដំបូងរហូតដល់ចប់។ ទោះបីជា សមាជិកនៃបណ្តាញអង្គការច្បាប់តំបន់ទន្លេមេគង្គ សុទ្ធតែជាមេធាវីមានបទពិសោធន៍ក៏ដោយ ក៏យើងបានរកឃើញថាមានចំណុចខ្វះចន្លោះរវាងច្បាប់និងការអនុវត្តដែរ។ វាក៏មានតម្រូវការដែលអាចប្រាស្រ័យទាក់ទងគ្នាទៅតាមវិធីឆ្លងដែនដែរ ទោះបីជា មានការទទួលស្គាល់ថា ប្រទេសផ្សេងៗគ្នា អនុវត្តនូវដំណើរការខុសៗគ្នា និងមានវិធីសាស្ត្រខុសគ្នាខ្លះក្នុងការអនុវត្តដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏ដោយ។

ឯកសារបោះពុម្ពលើកទីមួយនេះ ជាលទ្ធផលបានមកពីរយៈពេលនៃកិច្ចសហការគ្នា។ យើងបានព្យាយាមធ្វើយ៉ាងណាធានានូវភាពត្រឹមត្រូវ និងពេញលេញ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងទទួលស្គាល់ថា នៅមានចំណុចខ្វះខាតដែលត្រូវធ្វើឲ្យប្រសើរឡើង។ យើងសូមស្វាគមន៍ចំពោះយោបល់ មតិរិះគន់ ឬការមិនពេញចិត្តផ្សេងៗ។ គោលបំណងរបស់យើងគឺដើម្បីផ្តល់ឯកសារ និងបន្តការពិភាក្សាដែលកំពុងធ្វើទៅលើគុណតម្លៃនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងតំបន់ និងធ្វើយ៉ាងណាដើម្បីឲ្យការវាយតម្លៃផលប៉ះពាល់បរិស្ថានកាន់តែប្រសើរឡើង។

ការងារនៃអង្គការភាពជាដៃគូតំបន់ទន្លេមេគង្គដើម្បីបរិស្ថាន និងការងាររបស់អង្គការ PACT គឺចំណាយទៅលើតួនាទីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ទម្រង់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានលើកឡើងដោយឆ្លងកាត់ការងាររបស់ PACT និងអ្នកអនុវត្ត ព្រមទាំងសហគមន៍ជាច្រើនផ្សេងទៀត។ មានការពិភាក្សាជាច្រើន កំពុងផ្តោតលើការកែលម្អបទដ្ឋាន និងគុណតម្លៃនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ជាពិសេស ការរៀបចំគោលការណ៍ណែនាំសម្រាប់ថ្នាក់តំបន់ស្តីពីការចូលរួមជាសាធារណៈ និងការតាក់តែងសេចក្តីព្រាងគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការចូលរួមជាសាធារណៈ ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ទាំងប្រទេសកម្ពុជា និងភូមា គឺសុទ្ធតែជាសូចនាករយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការចូលរួមជាសាធារណៈ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ការបោះពុម្ពលើកទីមួយនេះ គឺយោងទៅលើក្រុមអ្នកអនុវត្តន៍ សង្គមស៊ីវិល មេធាវី ទីប្រឹក្សាពិគ្រោះយោបល់ផ្នែកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអ្នកស្នើសុំគម្រោង។ យើងសង្ឃឹមថាដោយមានការយល់ដឹងអំពីកាតព្វកិច្ចផ្លូវច្បាប់ ក្រោមច្បាប់ជាតិ ភាគីពាក់ព័ន្ធទាំងអស់នឹងធ្វើការរួមគ្នាដើម្បីបន្តធ្វើឱ្យប្រសើរឡើងជាប្រចាំនូវដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ក្រុមអ្នកនិពន្ធ
*ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៦*

## សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធ សូមទទួលស្គាល់ថា កិច្ចការនេះនឹងមិនអាចធ្វើទៅបានទេ ប្រសិនបើ គ្មានការគាំទ្រពីបុគ្គល និងអង្គការយ៉ាងច្រើនបែបនេះ។ ជាពិសេស យើងសូមអរគុណដល់បណ្តាបុគ្គល និងអង្គការនានាដែលបានផ្តល់មតិ និងសំណើនានា។ បុគ្គលនិងអង្គការទាំងនោះមានដូចតទៅ៖ EarthRights International, Christy Owen, Barry Flaming, បណ្ឌិត វង្ស សុខ (Dr Vong Sok), PACT MPE, Dr Peter Jensen, Dr Richard Frankel, Dr Peter King, David Annandale, Iain Watson, Martin Cosier, BJ Schulte, Sui Tip Lam (សាលាច្បាប់ Vermont), Vesna Kolar Planinsic, Tahra Vose, Kim Smaczniak។

ជាពិសេស លោក Matthew Baird សូមអរគុណ លោក Chris Chun ដែលបានគាំទ្រគម្រោងនេះ និងការងារទាំងអស់ពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការចូលរួមជាសាធារណៈក្នុងរយៈពេលពីរ-បីឆ្នាំកន្លងមកនេះ។

ការដកស្រង់ពី៖ សៀវភៅអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងតំបន់ទន្លេមេគង្គ ការអត្ថាធិប្បាយ និងឯកសារ (បោះពុម្ពលើកទី១), បណ្តាញអង្គការច្បាប់តំបន់ទន្លេមេគង្គ និង Matthew Baird, EarthRights International, ខែកញ្ញា ឆ្នាំ២០១៦។

អ្នកនិពន្ធ៖ Matthew Baird, Sor Rattanamanee Polkla, Songkrant Pongboonjun, Manolinh Thepkhamvong, Dang Dinh Bach, Tep Neth, Than Than Aye, Oo Kyaw Thein, Jinmei Liu, Rémy Kinna។

## អាស៊ាននិងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលបានចូលជាធរមាននៅខែធ្នូ ឆ្នាំ ២០០៨ បានបញ្ចូលជាផ្នែកនៃគោលបំណងមួយរបស់ខ្លួន៖

| |
|---|
| លើកស្ទួយការអភិវឌ្ឍប្រកបដោយនិរន្តរភាពដើម្បីធានាកិច្ចការពារបរិស្ថានតំបន់ និរន្តរភាពនៃធនធានធម្មជាតិ និងការអភិរក្សមរតកវប្បធម៌ និងគុណភាពនៃជីវភាពរស់នៅរបស់ប្រជាជន។[1] |

គោលបំណងផ្សេងទៀតរបស់អាស៊ានរួមមាន៖

- លើកកំពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋ
- បង្កើតទីផ្សាររួមមួយ និងមូលដ្ឋានផលិតកម្មរួម[2]
- ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន[3] និង
- លើកកម្ពស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលផ្តោតលើប្រជាជន។[4]

មាត្រា២នៃធម្មនុញ្ញនេះ ក៏បានអះអាងឡើងវិញ នូវគោលការណ៍របស់អាស៊ាន រួមទាំង (ប៉ុន្តែមិនកំណត់ចំពោះ) ការចូលរួមប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នា មិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋជាសមាជិកអាស៊ាន គោរពសេរីភាពជាមូលដ្ឋាន លើកស្ទួយ និងការពារសិទ្ធិមនុស្ស លើកស្ទួយយុត្តិធម៌សង្គម និងលើកកម្ពស់ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ។[5]

| |
|---|
| ទស្សនៈដល់ឆ្នាំ២០២០សម្រាប់សហគមន៍អាស៊ានគឺ "ស្អាត និងបៃតង ... ដោយមានការបង្កើតឡើងនូវយន្តការពេញលេញសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ...” |

[1] ASEAN Charter Article 1(9).
[2] Article 1(5).
[3] Article 1(7).
[4] Article 1(13).
[5] Article 2(2).

ការទទួលស្គាល់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅក្នុងតំបន់អាស៊ាន ត្រូវបានទទួលស្គាល់បន្ថែមទៀតនៅក្នុងសេចក្តីប្រកាសស្តីពីបរិស្ថានអាស៊ាន នៅទីក្រុងបាងកក ឆ្នាំ១៩៨៤។[6] សេចក្តីប្រកាសនេះបានព្យាយាម "ពង្រឹងការប្រើប្រាស់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវិភាគចំណាយ-ចំណេញលម្អិតដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរ និងដើម្បីធានាការពិចារណាត្រឹមត្រូវអំពីគុណតម្លៃបរិស្ថាននៅក្នុងគម្រោងនិងកម្មវិធីទាំងអស់ របស់រដ្ឋាភិបាលដែលអាចនឹងបង្កឲ្យមានផលប៉ះពាល់ផ្នែកបរិស្ថានយ៉ាងធ្ងន់ធ្ងរ និងការពង្រីកជាបណ្តើរៗរបស់រដ្ឋទៅវិស័យឯកជន ក្នុងវិស័យឧស្សាហកម្ម"។[7]

ដំណោះស្រាយក្រុងហ្សាការតាឆ្នាំ១៩៨៧ស្តីពីការអភិវឌ្ឍប្រកបដោយនិរន្តរភាព បានទទួលស្គាល់ថា "និរន្តរភាពនៃការអភិវឌ្ឍកំណត់ថា ដំណើរការអភិវឌ្ឍន៍និងការគ្រប់គ្រងបរិស្ថានគប្បីត្រូវបានធ្វើឡើងក្នុងលក្ខណៈសំខាន់មួយ" និងកត់សម្គាល់បន្ថែមទៀតថា៖ "ការបញ្ចូលនូវការគិតគូអំពីបរិស្ថានទៅក្នុងដំណើរការអភិវឌ្ឍតម្រូវថា ត្រូវលើកកម្ពស់ និងបង្កើនបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ"។[8] សេចក្តីសម្រេចក្រុងហ្សាការតានេះ បានកំណត់ថា បណ្តាប្រទេសជាសមាជិកអាស៊ាន "អនុម័តគោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ជាមាគ៌ា និងប្រើប្រាស់ជាកត្តាក្នុងកិច្ចប្រឹងប្រែងរួមរបស់ប្រទេសទាំងនោះ"។

សេចក្តីប្រកាសរបស់អាស៊ានស្តីពីនិរន្តរភាពបរិស្ថាន ដែលត្រូវបានចុះហត្ថលេខានៅប្រទេសសិង្ហបុរី កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៧ ដោយប្រមុខនៃប្រទេសជាសមាជិកអាស៊ាន បានបញ្ជាក់ឡើងវិញការប្តេជ្ញាចិត្តបង្កើតសហគមន៍អាស៊ាន ដែលមានសេដ្ឋកិច្ចរស់រវើកនិងបរិស្ថានល្អ ដើម្បីឲ្យ "មនុស្សជំនាន់បច្ចុប្បន្ន និងអនាគតអាចមានបរិស្ថានល្អ និងមាននិរន្តរភាព"។ មានផ្នែកមួយស្តីពីកិច្ចការពារ និងគ្រប់គ្រងបរិស្ថានដែលសំដៅទៅយន្តការមួយដើម្បីលើកស្ទួយការអនុវត្តប្រកបដោយនិរន្តរភាព។

## សិទ្ធិមនុស្ស

សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សរបស់អាស៊ាននាពេលថ្មីៗនេះ មានគោលការណ៍មួយចំនួនដែលពាក់ព័ន្ធនឹងសិទ្ធិដីធ្លី និងសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ រួមទាំង សិទ្ធិទទួលបាន "បរិស្ថានមានសុវត្ថិភាពល្អ និងប្រកបដោយនិរន្តរភាព" និងសិទ្ធិទទួលបានការថែទាំសុខភាព។

---

[6] Bangkok Declaration of the ASEAN Environment 29 November 1984, Koh, 2009, p.657.
[7] Koh, 2009, p.658.
[8] Koh, 2009, p.663.

មាត្រា២៨៖
ពលរដ្ឋគ្រប់រូបមានសិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ ទាំងសម្រាប់ខ្លួនឯងផ្ទាល់និង
សម្រាប់ក្រុមគ្រួសារ ដូចជា៖
(e) សិទ្ធិមានទឹកស្អាតប្រើប្រាស់ និងអនាម័យ
(f) សិទ្ធិមានបរិស្ថានមានសុវត្ថិភាពល្អ និងប្រកបដោយនិរន្តរភាព

លើសពីនេះទៅទៀត ទោះបីជា សិទ្ធិក្នុងការអភិវឌ្ឍ ត្រូវបានទទួលស្គាល់ដោយសេចក្តីប្រកាសរបស់អាស៊ានស្តីពីសិទ្ធិមនុស្សក៏ដោយ ក៏វាមានការលំបាកដែលសិទ្ធិក្នុងការអភិវឌ្ឍគប្បីត្រូវអនុវត្តដើម្បីបំពេញដោយសមធម៌នូវតម្រូវការក្នុងការអភិវឌ្ឍ និងផ្នែកបរិស្ថានសម្រាប់ជំនាន់បច្ចុប្បន្ន និងអនាគត។[9]

## តើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាអ្វី?

គោលការណ៍ ១៧៖
ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលជាលិខិតបទដ្ឋានថ្នាក់ជាតិ ត្រូវអនុវត្តសម្រាប់បណ្តាសកម្មភាពស្នើសុំដែលទំនងជានឹងមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងលើបរិស្ថាន ហើយជាកម្មវត្ថុនៃការសម្រេចចិត្តរបស់អាជ្ញាធរមានសមត្ថកិច្ចថ្នាក់ជាតិ។[10]

គេអាចកំណត់និយមន័យអំពីការវាយតម្លៃផលប៉ះពាល់បរិស្ថានថា៖

ដំណើរការនៃការកំណត់ ការប៉ាន់ស្មាន ការវាយតម្លៃ និងការកាត់បន្ថយផលប៉ះពាល់ ជីវរូប សង្គម និងផលប៉ះពាល់ពាក់ព័ន្ធផ្សេងៗទៀតដោយសារសំណើនៃគម្រោងអភិវឌ្ឍន៍ (និងសកម្មភាពផ្សេងទៀត) មុនពេលសម្រេចចិត្ត និងតាំងចិត្តអនុវត្ត។

## គោលបំណងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

[9] ASEAN Human Rights Declaration, Article 35.
[10] Principle 17 of the Rio Declaration on Environment and Development, 1992.

- ធានាឱ្យបានថា ការគិតគូរអំពីបរិស្ថានត្រូវបានលើកយកមកដោះស្រាយយ៉ាងជាក់លាក់ ហើយត្រូវបានបញ្ចូលទៅក្នុងដំណើរការនៃការសម្រេចចិត្តលើគម្រោងអភិវឌ្ឍន៍
- ប្រមើលមើលនិងបញ្ចៀស កាត់បន្ថយ ឬប៉ះប៉ូវ ផលប៉ះពាល់ ជីវរូបសាស្ត្រ សង្គម និង ផលប៉ះពាល់ពាក់ព័ន្ធផ្សេងៗទៀតដោយសារសំណើនៃគម្រោងអភិវឌ្ឍន៍
- ការពារផលិតភាព និងសមត្ថភាពនៃប្រព័ន្ធធម្មជាតិនិងដំណើរការអេកូឡូស៊ីដែលរក្សាមុខងាររបស់វា និង
- លើកកម្ពស់ការអភិវឌ្ឍដែលមាននិរន្តរភាព និងបង្កើនប្រសិទ្ធភាពប្រើប្រាស់ និង ឱកាសគ្រប់គ្រងធនធាន។[11]

ពីដំបូង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានដាក់ឲ្យប្រើប្រាស់នៅសហរដ្ឋអាមេរិកនៅដើមឆ្នាំ១៩៧០ ទៅតាមច្បាប់គោលនយោបាយបរិស្ថានជាតិ។[12] ចាប់តាំងពីពេលនោះមក គំនិតនិងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានការអភិវឌ្ឍយ៉ាងខ្លាំង។ ការពិនិត្យឡើងវិញ[13] នៅឆ្នាំ១៩៩៦ ដោយសមគមអន្តរជាតិដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទៅលើបទពិសោធន៍អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទូទាំងពិភពលោក បានស្នើឡើងនូវធាតុផ្សំធំៗបួន សម្រាប់ការអនុវត្តការវាយតម្លៃបរិស្ថានដោយប្រសិទ្ធភាព គឺ៖

- ការកំណត់ពេលវេលាសមរម្យក្នុងការផ្តួចផ្តើមការវាយតម្លៃ ដើម្បីឲ្យមានការពិនិត្យសំណើគ្រប់គ្រាន់ទាន់ពេលចំពោះវិសាលភាពសម្រាប់ការអភិវឌ្ឍជម្រើសសមហេតុផល
- ការណែនាំជាក់លាក់ ច្បាស់លាស់ក្នុងទម្រង់នៃលក្ខខណ្ឌការងារ ឬគោលការណ៍ណែនាំដែលផ្តោតលើបញ្ហាអាទិភាព ពេលវេលា និងឱកាសសម្រាប់ផ្តល់ព័ត៌មាន និង ការផ្តល់គំនិតក្នុងដំណាក់កាលធ្វើសេចក្តីសម្រេចសំខាន់ៗ
- ព័ត៌មាន និងផលិតផលមានគុណភាពដែលលើកកម្ពស់ដោយអនុលោមតាមគោលការណ៍ណែនាំតាមនីតិវិធី និងការអនុវត្ត "វិធីអនុវត្តន៍ល្អ" និង
- ការទទួលយកដោយក្រុមអ្នកធ្វើការសម្រេចចិត្ត និងអ្នកគាំទ្រ ចំពោះលទ្ធផលនៃការវាយតម្លៃបរិស្ថាន ដែលបង្កើតឡើងដោយផ្អែកលើការផ្សព្វផ្សាយល្អ និងគណនេយ្យភាព។

---

11 More details are available at www.iaia.org/publicdocuments/specialpublications/principles%20of%20IA_web.pdf.

12 Elliot,2014, p.103.

13 Sadler, 1996.

ធាតុទាំងបួននេះ ត្រូវបំពេញបន្ថែម លក្ខខណ្ឌតម្រូវ ដើម្បីការចូលរួមជាសាធារណៈមានអត្ថន័យ។

និយមន័យខាងក្រោមត្រូវបានអនុម័តដោយការពិនិត្យឡើងវិញនៅឆ្នាំ១៩៩៦នោះ ហើយនៅតែសមស្របរហូតដល់ពេលបច្ចុប្បន្ននេះ៖

> ការវាយតម្លៃបរិស្ថានគឺជា ដំណើរការជាប្រព័ន្ធនៃការវាយតម្លៃនិងចងក្រងឯកសារអំពីសក្តានុភាព សមត្ថភាព និងមុខងារនៃប្រព័ន្ធនិងធនធានធម្មជាតិ ក្នុងគោលបំណងដើម្បីជួយសម្រួលដល់ការធ្វើផែនការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងការសម្រេចចិត្តទូទៅ និងដើម្បីប្រមើលមើល និងគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន និងផលវិបាកពីសំណើសកម្មភាពអនុវត្ត ជាពិសេស។
>
> ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជាដំណើរការនៃការកំណត់ ការប៉ាន់ស្មាន ការវាយតម្លៃ និងការកាត់បន្ថយជីវរូបសាស្ត្រ សង្គម និងផលប៉ះពាល់ពាក់ព័ន្ធផ្សេងៗទៀតដែលបណ្តាលមកពីសំណើគម្រោង និងសកម្មភាពរូបវន្តនានាមុនពេលធ្វើសេចក្តីសម្រេចសំខាន់ៗ និងការប្តេជ្ញាចិត្តអនុវត្តគម្រោង។
>
> ការវាយតម្លៃជាយុទ្ធសាស្ត្រអំពីបរិស្ថានគឺជា ដំណើរការនៃការពិនិត្យជាមុន និងវាយតម្លៃគោលនយោបាយ ផែនការ និងកម្មវិធីនានា ព្រមទាំងគំនិតផ្តួចផ្តើមមុនពេលបង្កើតគម្រោងកម្រិតខ្ពស់ផ្សេងៗទៀត។
>
> ការវាយតម្លៃហេតុប៉ះពាល់សង្គមគឺជា ដំណើរការនៃការប៉ាន់ប្រមាណផលវិបាកសង្គមដែលទំនងជា
> អនុវត្តតាមគោលនយោបាយជាក់លាក់ និងសំណើរបស់រដ្ឋាភិបាល ជាពិសេសនៅក្នុងបរិបទដែលជាតម្រូវការវាយតម្លៃបរិស្ថានថ្នាក់ជាតិ (អន្តរគណៈកម្មាធិការស្តីពីគោលការណ៍ណែនាំ និងគោលការណ៍ ឆ្នាំ១៩៩៤, ១០៨)។[14]

លើសពីនេះទៅទៀត ការពិនិត្យឡើងវិញឆ្នាំ១៩៩៦ បានស្នើឡើងនូវគោលបំណងសំខាន់ពីរក្នុងការវាយតម្លៃហេតុប៉ះបាល់បរិស្ថាន គឺ៖

[14] Sadler, 1996, p.13.

ទី១ គោលបំណងចំពោះមុខ គឺដើម្បីជួយសម្រួលឲ្យមានការធ្វើសេចក្តីសម្រេចគួរឲ្យទុកចិត្ត បញ្ចូលគ្នា ដែលនៅក្នុងការសម្រេចចិត្តនោះ ការគិតអំពីបរិស្ថានត្រូវបានបញ្ចូលយ៉ាងច្បាស់លាស់។ ដំណើរការនៃការវាយតម្លៃបរិស្ថាន ត្រូវធ្វើដោយផ្តល់ព័ត៌មានច្បាស់លាស់ និងមានរបៀបរៀបចំយ៉ាងល្អ អំពីផលប៉ះពាល់ ហានិភ័យ និងផលវិបាកផ្នែកបរិស្ថានដែលបណ្តាលមកពីជម្រើស និងសំណើគម្រោងអភិវឌ្ឍន៍។

ទី២ ដំណើរការនៃការវាយតម្លៃបរិស្ថានជាទូទៅ (ប៉ុន្តែមិនជាសកលទេ) ត្រូវសំដៅទៅរកការសម្រេចបាននូវឬគាំទ្រដល់ គោលដៅចុងក្រោយនៃកិច្ចការពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ សេចក្តីយោង ឬគោលដៅចុងក្រោយទាំងនេះត្រូវបានរៀបចំ និងបង្កើតឡើងនៅក្នុងក្របខណ្ឌច្បាប់ និងគោលនយោបាយអំពីការវាយតម្លៃបរិស្ថាន ដូចគ្នានឹងការបំពេញបាននូវបំណងជាក់លាក់ដោយដំណើរការនេះ។[15]

បួនទសវត្សរ៍កន្លងមកនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានបង្កើតឡើងនិងប្រើប្រាស់ក្នុង "ដំណើរការពហុគោលបំណង" ដោយមានការសង្កត់ធ្ងន់កាន់តែខ្លាំងឡើងទៅលើការលើកកម្ពស់គោលដៅសង្គមរយៈពេលវែង ដែលឆ្លុះបញ្ចាំង និងបង្ហាញឧត្តមភាពនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ធាតុផ្សេងៗទៀតត្រូវបានគេកំណត់អត្តសញ្ញាណ (បន្ថែមលើគោលបំណងខាងលើ) ដែលធាតុទាំងនោះមាន៖

- ការការពារតំបន់បេតិភណ្ឌ ដំណើរការអេកូឡូស៊ីមានតម្លៃ
- បញ្ចៀសការបាត់បង់ដែលមិនអាចស្តារឡើងវិញបាន មិនអាចទទួលយកបាន និងការធ្លាក់ចុះនៃមូលធនធម្មជាតិ
- ធានាថា ការអភិវឌ្ឍត្រូវបានលៃតម្រូវទៅតាមសក្តានុភាព និងសមត្ថភាពនៃមូលដ្ឋានធនធាន
- ការប្រើឱកាសនៃការប្រើប្រាស់ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិឲ្យមានប្រសិទ្ធភាពខ្ពស់
- ការការពារសុខភាពប្រជាជន និងសុខុមាលភាពរបស់សហគមន៍
- ដោះស្រាយកង្វល់រួមទាក់ទងទៅនឹងការរំខានដល់របៀបរស់នៅបែបប្រពៃណីរបស់ប្រជាជន
- ការកែលម្អការសហការសម្របសម្រួល បណ្តាសកម្មភាព និងស្ថាប័នដែលចូលរួម

[15] Sadler, 1996, p.13.

- ជំរុញគម្រោងអភិវឌ្ឍន៍ដែលបានរៀបចំបង្កើតនោះឲ្យកាន់តែល្អប្រសើរ ដូចជា បរិស្ថានកាន់បៃតង និងការចំណាយកាន់តែមានប្រសិទ្ធភាព
- ផ្តល់សិទ្ធិអំណាច ក្នុងការអភិវឌ្ឍសហគមន៍ និងក្នុងការកសាងសមត្ថភាពម្ចាស់ស្រុក តាមរយៈការចូលរួមជាសាធារណៈ
- បណ្តុះគុណតម្លៃផ្នែកបរិស្ថាន និងគណនេយ្យភាព នៅតាមបណ្តាស្ថាប័នមួយចំនួន និង
- បញ្ចូលការចំណាយ និងការខូចខាតផ្នែកបរិស្ថានទៅក្នុងឧស្សាហកម្ម ស្របទៅតាមគោលការណ៍ទូទាត់របស់អ្នកបំពុលបរិស្ថាន។[16]

## លក្ខណៈសំខាន់ៗនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិដ្ឋាន

លក្ខណៈសំខាន់ៗមួយចំនួននៅក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងសម័យទំនើបនេះគប្បីត្រូវមានៈ

- **ការជ្រើសរើស (គម្រោង)** - ដើម្បីកំណត់ថា តើសំណើមួយស្ថិតនៅក្រោមការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរឬទេ ហើយប្រសិនបើដូច្នេះ តើត្រូវធ្វើក្នុងភាពលម្អិតកម្រិតណា។
- **ការកំណត់វិសាលភាព** - ដើម្បីកំណត់បញ្ហានិងផលប៉ះពាល់ដែលអាចមានសារសំខាន់ និងបង្កើតបាននូវលក្ខខណ្ឌសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- **ការពិនិត្យលើជម្រើសផ្សេងៗ** - ដើម្បីបង្កើតនូវជម្រើសផ្នែកបរិស្ថានគួរជាទីពេញចិត្ត ឬល្អនិងមានសុវត្ថិភាពបំផុតដើម្បីសម្រេចគោលដៅដែលបានស្នើ។
- **ការវិភាគអំពីផលប៉ះពាល់** - ដើម្បីកំណត់អត្តសញ្ញាណ និងប៉ាន់ស្មានភាពដែលអាចនឹងប៉ះពាល់ដល់បរិស្ថាន សង្គម និងបញ្ហាផ្សេងៗទៀត ដោយសារសំណើនោះ។
- **ការកាត់បន្ថយ និងគ្រប់គ្រងផលប៉ះពាល់** - ដើម្បីបង្កើតវិធានការដែលចាំបាច់ដើម្បីបញ្ចៀស កាត់បន្ថយ ឬប៉ះប៉ូវផលប៉ះពាល់អវិជ្ជមានដែលគេបានប៉ាន់ស្មាន ហើយនៅពេលសមស្របនឹងបញ្ចូលវិធានការទាំងនេះទៅក្នុងផែនការឬប្រព័ន្ធគ្រប់គ្រងបរិស្ថាន។
- **ការវាយតម្លៃអំពីសារសំខាន់** - ដើម្បីកំណត់អំពីសារសំខាន់ទាក់ទង និងការទទួលយកនូវផលប៉ះពាល់ដោយសំណល់ (ឧទាហរណ៍ ផលប៉ះពាល់ដែលគេមិនអាចកាត់បន្ថយបាន)។

[16] Sadler, 1996, p.14.

- **ការរៀបចំសេចក្តីថ្លែងការណ៍នៃរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬ (របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)** - ចងក្រងឯកសារយ៉ាងច្បាស់លាស់ និងមិនលម្អៀងអំពីផលប៉ះពាល់ដោយសារសំណើគម្រោងអភិវឌ្ឍន៍ សំណើវិធានការសម្រាប់កាត់បន្ថយផលប៉ះពាល់ សារសំខាន់នៃផលប៉ះពាល់ និងការព្រួយបារម្ភរបស់សាធារណជនដែលចាប់អារម្មណ៍ និងបណ្តាសហគមន៍ដែលរងផលប៉ះពាល់ដោយសំណើនេះ។
- **ការពិនិត្យឡើងវិញលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** - ដើម្បីកំណត់ថា តើរបាយការណ៍នេះបានបំពេញតាមលក្ខខណ្ឌការងារដែរឬទេ តើវាផ្តល់នូវការវាយតម្លៃជាទីពេញចិត្តចំពោះសំណើនោះដែរឬទេ និងតើវាមានព័ត៌មានដែលជាលក្ខខណ្ឌសម្រាប់ការធ្វើសេចក្តីសម្រេចដែរឬទេ។
- **ការសម្រេច** - ដើម្បីអនុម័តឬបដិសេធសំណើនោះ និងដើម្បីបង្កើត ខនិងលក្ខខណ្ឌសម្រាប់ការអនុវត្ត។
- **តាមដានការអនុវត្ត ត្រួតពិនិត្យ ប្រតិបត្តិ និងពង្រឹងការអនុវត្ត** - ដើម្បីធានាថា ខនិងលក្ខខណ្ឌដែលបានអនុម័តត្រូវបានបំពេញ ដើម្បីពិនិត្យតាមដានផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍និងប្រសិទ្ធភាពនៃវិធានការកាត់បន្ថយផលប៉ះពាល់ ដើម្បីពង្រឹងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយផលប៉ះពាល់ទៅអនាគត និងនៅពេលដែលចាំបាច់ គឺដើម្បីអនុវត្តការវាយតម្លៃដំណើរការ និងសវនកម្មបរិស្ថាន ដើម្បីបង្កើនប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងបរិស្ថាន។

*សិទ្ធិមានបរិស្ថានល្អ*

សាលក្រមតុលាការធម្មនុញ្ញប្រទេសថៃលេខ៣២/២៥៥២ (២០០៩)

- គូភាគី៖ លោក Paiboon Kongkerd និងដើមបណ្តឹង២១០នាក់ បញ្ជូនដោយការិយាល័យតុលាការរដ្ឋបាលដែលជាអ្នកដាក់ញត្តិ
- អង្គហេតុសង្ខេប៖ ដើមបណ្តឹងដាក់ពាក្យបណ្តឹងទៅតុលាការរដ្ឋបាលដើម្បីប្តឹងអាជ្ញាធរមូលដ្ឋានចំនួនបី នៅខេត្តខុនខែន ប្រទេសថៃ ដោយអះអាងថា អាជ្ញាធរមូលដ្ឋានទាំងនោះបានអនុម័តសេចក្តីសម្រេចដោយខុសច្បាប់ដើម្បីសាងសង់កន្លែងចាក់សំរាមមួយនៅក្នុងសហគមន៍ក្នុងខេត្តខុនខែនដោយគ្មានការរៀបចំការវាយតម្លៃហេតុប៉ះពាល់សុខភាព បរិស្ថាន ឬពុំមានបើកវេទិកាសាធារណៈ ឬទទួលយោបល់ពីអ្នកជំនាញសុខភាពនិងបរិស្ថានឡើយ។
- តុលាការរដ្ឋបាលខេត្តខុនខែនបានច្រានចោលរឿងក្តីនេះដោយសារៈ

- យោងតាមច្បាប់ស្តីពីបរិស្ថាន ព.ស ២៥៣៥ (គ.ស ១៩៩២) ជាច្បាប់តែមួយគត់ដែលទាក់ទងទៅនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាន មាត្រា៤៦ និងអនុក្រឹត្យពាក់ព័ន្ធ គម្រោងនេះមិនតម្រូវឲ្យអនុវត្តដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទេ។
- ផ្អែកលើមូលដ្ឋាននៃវេទិកាសាធារណៈ ដោយសារវិធាននៃការិយាល័យរបស់នាយករដ្ឋមន្ត្រីស្តីពីការពិគ្រោះយោបល់ជាសាធារណៈ ព.ស ២៥៤៨ (គ.ស២០០៥) បញ្ជាក់ថា វាមិនចាំបាច់ដែលត្រូវបើកវេទិកាសាធារណៈទេ ប៉ុន្តែផ្តល់ឆន្ទានុសិទ្ធិទៅលោកអភិបាលខេត្តខុនខែន និងគ្មានភស្តុតាងបញ្ជាក់ថា លោកអភិបាលរំលោភបំពាននៃឆន្ទានុសិទ្ធិទេ ដូច្នេះវាមិនខុសច្បាប់ទេ។
- ភាគីដើមចោទបានប្តឹងសាទុក្ខទៅតុលាការរដ្ឋបាលកំពូល និងបានស្នើសុំតុលាការរដ្ឋបាលកំពូលឲ្យបញ្ជូនបញ្ហាធម្មនុញ្ញទៅតុលាការធម្មនុញ្ញដើម្បីសម្រេច។
- បញ្ហាផ្នែកច្បាប់៖ បញ្ហាគឺស្ថិតនៅត្រង់ថា តើមាត្រា៤៦នៃច្បាប់បរិស្ថាន ព.ស ២៥៣៥ (គ.ស ១៩៩២) នោះផ្ទុយទៅនឹងមាត្រា៥៦នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ ព.ស ២៥៤០ (គ.ស ១៩៩៧) ឬមាត្រា៦៧នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ ព.ស ២៥៥០ (គ.ស ២០០៧) ទេ? តើមាត្រា៤៦នៃច្បាប់ស្តីពីបរិស្ថាន ព.ស ២៥៣៥ (គ.ស ១៩៩២) នោះផ្ទុយនឹងមាត្រា៥៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ ព.ស ២៥៤០ (គ.ស ១៩៩៧) ឬមាត្រា៦៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ ព.ស ២៥៥០ (គ.ស ២០០៧) ទេ?
- សាលក្រម៖ តុលាការធម្មនុញ្ញបានសម្រេចថា មាត្រា៤៦ នៃច្បាប់ស្តីពីបរិស្ថាន ព.ស ២៥៣៥ មិនផ្ទុយនឹងមាត្រា៥៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ ព.ស. ២៥៤០ ឬមាត្រា៦៧នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រថៃ ព.ស ២៥០៥ នោះទេ។ តុលាការនេះបានបង្កើតលក្ខខណ្ឌទុកជាមុនថា សិទ្ធិក្នុងការរស់នៅក្នុងបរិស្ថានសមរម្យ អនុលោមតាមមាត្រា៦៧នៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ ត្រូវបានធានា។ វាតម្រូវឱ្យអាជ្ញាធរពាក់ព័ន្ធពិចារណាថា តើគម្រោងណាមួយ ត្រូវមានកាតព្វកិច្ចអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមិនអនុវត្តនោះ អាចនឹងបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានធម្មជាតិ និងបរិស្ថាននៅក្នុងសហគមន៍ ឬបណ្តាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពរបស់ប្រជាជន។ អាជ្ញាធរពាក់ព័ន្ធត្រូវអនុវត្តតាមវិធីនេះ ប្រសិនបើមិនអនុវត្តតាមទេ ប្រជាជនមានសិទ្ធិតវ៉ាទាមទារឲ្យការអនុម័តគម្រោងនោះ ត្រូវអនុវត្តការវាយតម្លៃហេតុប៉ះពាល់សុខភាពនិងបរិស្ថាន ទាមទារឲ្យមានវេទិកាសាធារណៈ និងទទួលយកនូវយោបល់ពីអ្នកជំនាញផ្នែកសុខភាព និងបរិស្ថាន។

## គោលការណ៍សំខាន់ៗនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានប្រសិទ្ធភាពនឹងត្រូវសម្រេចបានតាមរយៈការអនុម័ត និងការអនុវត្តគោលការណ៍សំខាន់ៗ ដូចខាងក្រោម ៖

- ដំណើរការដែលបង្កើតឡើងដោយស្របច្បាប់ ច្បាស់លាស់ និងប្រសិទ្ធភាព
- អ្នកស្នើសុំគម្រោង រ៉ាប់រងចំណាយលើដំណើរការអនុវត្តនិងវាយតម្លៃ
- ការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យនៅគ្រប់ជំហាននៃដំណើរការ
- ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធអាចទទួលបានព័ត៌មាន
- មានព័ត៌មានពាក់ព័ន្ធទាំងអស់
- ការធ្វើសេចក្តីសម្រេចដោយបើកចំហ និងមានភស្តុតាងជាមូលដ្ឋាន និង
- ការពិនិត្យតាមដាន ការប្រតិបត្តិ និងការពង្រឹងការអនុវត្តដែលមានប្រសិទ្ធភាព។[17]

## ដំណើរការដែលបង្កើតឡើងដោយស្របច្បាប់ ច្បាស់លាស់ និងប្រសិទ្ធភាព

ដំណើរការនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន អាចមានភាពស្មុគស្មាញ ស៊ីពេលវេលា និងចំណាយច្រើន (ថ្លៃ)។ ដូច្នេះហើយ វាត្រូវការឱ្យមានការទ្រទ្រង់ដោយលក្ខខណ្ឌច្បាប់ច្បាស់លាស់ ដែលគូសបញ្ជាក់អំពីដំណើរការដែលត្រូវអនុវត្តតាម។ ធ្វើបែបនេះ វាផ្តល់នូវភាពច្បាស់លាស់សម្រាប់ភាគីពាក់ព័ន្ធទាំងអស់-រួមទាំង ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង អ្នកស្នើសុំគម្រោង ទីប្រឹក្សាពិគ្រោះយោបល់អំពីវាយតម្លៃហេតុប៉ះពល់បរិស្ថាន និយតកររដ្ឋាភិបាល (មិនមែនតែផ្នែកបរិស្ថានទេ) និងភាគីពាក់ព័ន្ធផ្សេងៗទៀត - និងភាពស៊ីចង្វាក់គ្នាក្នុងវិធីអនុវត្តទៅតាមពេលវេលា។

ការអនុវត្តតាមនីតិវិធីច្បាប់ដែលមានការយល់ដឹងយ៉ាងទូលំទូលាយ ក៏ជួយកាត់បន្ថយសក្តានុភាពនៃជម្លោះដែលអាចកើតឡើងដែរ នៅពេលដែលការសម្រេចចិត្តមួយត្រូវបានធ្វើឡើងនៅទីបំផុត។

## អ្នកស្នើសុំរ៉ាប់រងចំណាយលើដំណើរការអនុវត្តនិងវាយតម្លៃ

[17] Baird and Cosier, 2014, as modified by Baird and Cosier, 2016.

ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ពេលអនុវត្តអាចនឹងចំណាយច្រើន ជាពិសេសសម្រាប់ បណ្តាសំណើគម្រោងអភិវឌ្ឍន៍ធំៗ ដែលពាក់ព័ន្ធនឹងទិដ្ឋភាពព្រមទាំងដំណាក់កាលច្រើន។ ការស៊ើបអង្កេត និងការវិភាគឱ្យបានត្រឹមត្រូវអំពីផលប៉ះពាល់នានាដែលអាចនឹងកើតឡើងដោយសារសំណើគម្រោង តម្រូវឱ្យមានការងារបច្ចេកទេសដែលរៀបរាប់យ៉ាងលម្អិត។ ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏តម្រូវឱ្យមានការចូលរួមជាសាធារណៈយ៉ាងទូលំទូលាយដែរ។ សាធារណជនទូទៅមិនគួរជាអ្នកទទួលបន្ទុកចំណាយលើការចូលរួមក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយរដ្ឋាភិបាលនោះឡើយ។ រាល់ការចំណាយចាំបាច់ត្រូវបញ្ចូលទៅក្នុងខ្ទង់ថវិការសម្រាប់ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំងមូល។

ក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏អាចនឹងបណ្តាលឲ្យមានកាតព្វកិច្ចត្រូវពិនិត្យតាមដាន និងគ្រប់គ្រងដែរ នេះប្រសិនបើសំណើគម្រោងបន្តទៅជំហានអនុវត្ត។ ថវិកាគម្រោងចាំបាច់ត្រូវមានគ្រប់គ្រាន់សម្រាប់សកម្មភាពទាំងនេះ។

## ការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យនៅគ្រប់ជំហាននៃដំណើរការ

គោលដៅសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺ ដើម្បីកាត់បន្ថយការប្រឈមនៃជម្លោះក្នុងសង្គមដែលកើតឡើងពីគម្រោង ដោយធានាថា ប្រជាជនទាំងអស់ដែលរងផលប៉ះពាល់ដោយគម្រោង និងភាគីពាក់ព័ន្ធផ្សេងៗទៀត មានអារម្មណ៍ថា ពួកគាត់បានចូលរួម មានគុណតម្លៃ និងទទួលបានការគោរព ក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចលើសំណើគម្រោងអភិវឌ្ឍន៍។

ដើម្បីឱ្យមានប្រសិទ្ធភាពពាក់ព័ន្ធចំណុចខាងលើនេះ ដាច់ខាតត្រូវតែធ្វើយ៉ាងណាឲ្យសាធារណជនចូលរួម ដោយមានផែនការរៀបចំ និងមានការរៀបរយក្នុងដំណាក់កាលពីដំបូងរហូតដល់ចប់នៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ កិច្ចខិតខំប្រឹងប្រែងដើម្បីឲ្យសាធារណជនចូលរួម ក៏ត្រូវរៀបចំឡើងដោយពិតប្រាកដ និងមានអត្ថន័យ មិនមែនគ្រាន់តែធ្វើឡើងឲ្យតែមាន ឬគ្រាន់តែអនុវត្តដើម្បីបំពេញតម្រូវការ ឬលក្ខខណ្ឌនៃបទប្បញ្ញត្តិនោះទេ។

ដំណើរការនៃការចូលរួមជាសាធារណៈនេះ ត្រូវតែធ្វើឡើងតាមតម្រូវការ និងស្ថានភាពជាក់លាក់របស់អ្នកចូលរួម។

## ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធត្រូវតែអាចទទួលបានព័ត៌មាន

ដើម្បីចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងធ្វើការសម្រេចចិត្តអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយមានព័ត៌មានច្បាស់លាស់ ប្រជាជនទាំងអស់ដែលរងផលប៉ះពាល់ដោយសារគម្រោង និងបណ្តាភាគីពាក់ព័ន្ធផ្សេងៗទៀត រួមទាំងសង្គមស៊ីវិល និងការិយាល័យនានារបស់រដ្ឋាភិបាលផង ត្រូវតែអាចទទួលបានព័ត៌មានសមរម្យគ្រប់គ្រាន់។ សិទ្ធិទទួលបានព័ត៌មាននេះ មានសិទ្ធិទទួលបានព័ត៌មានផ្នែកបច្ចេកទេស ក៏ដូចជា ព័ត៌មានដែលមនុស្សសមញ្ញអាចយល់បាន។ ព័ត៌មានទាំងនោះចាំបាច់ត្រូវផ្តល់ជូនក្នុងទម្រង់និងភាសាដែលក្រុមគោលដៅអាចប្រើប្រាស់បាន ព្រមទាំងផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីឲ្យពួកគាត់ស្វែងយល់ គិតពិចារណា និងឆ្លើយតប។

## ត្រូវមានព័ត៌មានពាក់ព័ន្ធទាំងអស់

ដើម្បីឲ្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្លាយជាឧបករណ៍គាំទ្រដល់ការសម្រេចចិត្តមានសារប្រយោជន៍ ដូច្នេះចាំបាច់ត្រូវតែផ្អែកលើព័ត៌មានល្អបំផុតដែលគេអាចរកបាន។ ព័ត៌មានទាំងនេះត្រូវតែសមស្រប ឬពាក់ព័ន្ធ ហើយដែលត្រូវដាក់ឲ្យប្រជាជនរងផលប៉ះពាល់ដោយសារគម្រោងទាំងអស់ និងភាគីពាក់ព័ន្ធផ្សេងៗទៀតអាចរកមកប្រើប្រាស់ ឬសិក្សាស្វែងយល់បាន។ នេះមានព័ត៌មានផ្នែកវិទ្យាសាស្ត្រ ក៏ដូចជា ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងជនជាតិដើមភាគតិច ដែលគេអាចរកបានតែតាមរយៈការចូលរួមជាសាធារណៈពិតប្រាកដ និងប្រកបដោយអត្ថន័យប៉ុណ្ណោះ (ដូច្នេះ នេះជាការពង្រឹងឡើងវិញនូវសារសំខាន់នៃគោលការណ៍មុននេះ)។

ការកំណត់បានច្បាស់នូវព័ត៌មាន "ល្អបំផុតដែលអាចរកបាន" វាពាក់ព័ន្ធដល់តុល្យភាពរវាងការពឹងផ្អែកលើចំណេះដឹងទូលំទូលាយនិងថ្មីបំផុត និងការផ្តល់នូវអ្វីដែលអាចរកបាន (និងអាចលៃលកបាន ក្នុងបរិបទនៃសំណើគម្រោងអភិវឌ្ឍន៍)។

## ការធ្វើសេចក្តីសម្រេចចិត្តដោយបើកចំហ និងមានភស្តុតាងជាមូលដ្ឋាន

ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានប្រកបដោយប្រសិទ្ធភាព ទាមទារឲ្យមានទាំងការរៀបចំការវាយតម្លៃហេតុប៉ះពាល់ដោយអ្នកគាំទ្រគម្រោង (និង/ឬអ្នកពិគ្រោះយោបល់អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) ទាំងការពិនិត្យឡើងវិញលើរបាយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយរដ្ឋាភិបាលដើម្បីកំណត់ថា តើសំណើគម្រោងគប្បីត្រូវបន្ត ឬបញ្ឈប់។ ការពិនិត្យឡើងវិញនេះ ត្រូវតែប្រព្រឹត្តទៅដោយតម្លាភាព និងផ្អែកលើហេតុផលល្អត្រឹមត្រូវ។

ការពិនិត្យឡើងវិញរបស់រដ្ឋាភិបាលលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចាំបាច់ត្រូវមានការងាររៀបចំដោយឯករាជ្យ ហើយត្រូវមានដំណើរការការចូលរួមជាសាធារណៈដោយឯករាជ្យ។ ការសម្រេចចិត្តចុងក្រោយថា ត្រូវអនុម័ត ឬមិនត្រូវអនុម័តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងថា តើគម្រោងនេះគួរតែត្រូវបានធ្វើឡើងដោយយោងតាមភ័ស្តុតាងដែលមាននៅក្នុងរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងក្នុងសំណើដែលស្នើជាសាធារណៈដាក់ជូនរដ្ឋាភិបាលនោះដែរឬទេ។

ការពិនិត្យឡើងវិញទាំងស្រុង និងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តគប្បីត្រូវធ្វើឡើងដោយតម្លាភាព ដោយសាធារណជនទូទៅអាចតាមទាន់នូវដំណើរការ និងអាចទទួលបានការសម្រេចចិត្ត និងហេតុផលសមរម្យចុងក្រោយ។

## ការពិនិត្យតាមដាន ការប្រតិបត្តិ និងការពង្រឹងការអនុវត្តដែលមានប្រសិទ្ធភាព

ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបញ្ចប់ជាផ្លូវការដោយការសម្រេចចិត្តចុងក្រោយ ប៉ុន្តែការអនុម័តលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានរបស់ខ្លួនគឺជា ឧបករណ៍ប្រើប្រាស់ជាប្រចាំយ៉ាងសំខាន់ ដើម្បីធានាថា ផលប៉ះពាល់ដោយសារគម្រោង ត្រូវបានដោះស្រាយ ទៅតាមវិធីដូចគោលបំណង នៅពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានអនុម័ត។ វាសំខាន់ណាស់ដែលការបញ្ចូលគ្នានៃប្រព័ន្ធនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទូទៅ ដែលរដ្ឋាភិបាល និងភាគីខាងក្រៅផ្សេងៗទៀត អាចពិនិត្យតាមដានលើការអនុវត្ត គម្រោង និងធានាថា មានគោរពតាមការប្តេជ្ញាចិត្ត និងកាតព្វកិច្ចទាំងឡាយដែលមានចែងក្នុងរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន។

យន្តការ និងលទ្ធផលរកឃើញពីការពិនិត្យតាមដានដែលបានអនុម័តឲ្យប្រើប្រាស់នៅក្នុងគម្រោងត្រូវតែប្រកាស ឬផ្សព្វផ្សាយជាសាធារណៈដល់ភាគីពាក់ព័ន្ធទាំងអស់ឱ្យមានទំនុកចិត្ត

ទាំងនៅក្នុងគម្រោងដែលមាននៅក្នុងដៃ និងនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំងអស់នាពេលអនាគត។

## យន្តការសំខាន់ៗសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ដើម្បីសម្រេចបានគោលដៅសំខាន់បំផុតនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គប្បីត្រូវប្រើលក្ខណៈវិនិច្ឆ័យវិភាគសំខាន់ៗមួយចំនួនក្នុងដំណើរការវាយតម្លៃ។ យន្តការទាំងនេះឆ្លុះបញ្ចាំងអំពីក្រឹត្យក្រមបច្ចុប្បន្ននៃច្បាប់បរិស្ថានអន្តរជាតិ។ មានយន្តការច្រើនក្នុងចំណោមយន្តការទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងសេចក្តីប្រកាសទីក្រុងរីយ៉ូ (Rio) ស្តីពីបរិស្ថាន និងការអភិវឌ្ឍ នៅឯកិច្ចប្រជុំកំពូលអំពីផែនដី ឆ្នាំ១៩៩២ (ហៅថា សេចក្តីប្រកាសទីក្រុងរីយ៉ូ)។

អាចកំណត់យន្តការចម្បងៗប្រាំ ដូចខាងក្រោម៖

- ការពឹងផ្អែកលើបណ្តាវិធីសាស្ត្របែបចូលរួម[18]
- ការអនុវត្តគោលការណ៍បង្ការទុកមុន[19]
- ការអនុវត្តគោលការណ៍សមធម៌មនុស្សអន្តរជំនាន់[20]
- ការអភិរក្សជីវចម្រុះ និងបញ្ចូលអេកូឡូស៊ីគឺជាការគិតពិចារណាជាចម្បង[21] និង
- ការវាយតម្លៃ ការកំណត់តម្លៃ និងការលើកទឹកចិត្តកាន់តែល្អប្រសើរ។[22]

## ការពឹងផ្អែកលើបណ្តាវិធីសាស្ត្របែបចូលរួម

លក្ខណៈពិសេសយ៉ាងសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺធ្វើយ៉ាងណាផ្តល់ឱកាសសម្រាប់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ភាគីពាក់ព័ន្ធ រួមមាន នាយកដ្ឋានពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល សហគមន៍ទូទៅ (ទោះបីជា ប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលក្តី) សហគមន៍ជនជាតិដើមភាគតិច និងវិស័យសាជីវកម្ម។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយប្រើវិធីអនុវត្តល្អបំផុត នឹងផ្តល់ឱកាសឲ្យមានការចូលរួមជាសាធារណៈ នៅគ្រប់ដំណាក់កាលនៃដំណើរការវាយតម្លៃ ចាប់ពីការវាយតម្លៃវិសាលភាព រហូតដល់

---

[18] Rio Declaration on Environment and Development, 1992, Principle 10.
[19] Rio Declaration 1992, Principle 15.
[20] Rio Declaration 1992, Principle 3.
[21] Rio Declaration 1992, Principle 4.
[22] Rio Declaration 1992, Principle 8, Principle 12, Principle 13, Principle 16.

ការធ្វើសេចក្តីសម្រេចចិត្ត និងផ្តល់ឱកាសដល់សហាគមន៍បានចូលរួមដោយអនុលោមតាម និងក្នុងដំណាក់កាលនៃការអភិវឌ្ឍគ្រប់ជំហាន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានវិធីអនុវត្តល្អបំផុត ក៏នឹងផ្តល់ជូននូវយុទ្ធសាស្ត្រនៃការចូលរួមជាក់លាក់ដល់ស្ត្រី និងជនជាតិដើមភាគតិច ព្រមទាំងបណ្តាសហាគមន៍របស់ពួកគាត់ដែរ។[23]

## ការអនុវត្តគោលការណ៍បង្ការទុកមុន

ទីណាដែល មានការគំរាមអំពីការបំផ្លាញ ឬខូចខាតបរិស្ថានធ្ងន់ធ្ងរ ឬមិនអាចស្តារឡើងវិញបានទេ ដូច្នេះគេមិនគប្បីត្រូវលើកហេតុផលនៃកង្វះព័ត៌មានពេញលេញផ្នែកវិទ្យាសាស្ត្រមកធ្វើជាហេតុផលសម្រាប់ការមិនចាត់វិធានការ ឬពន្យារវិធានការក្នុងការទប់ស្កាត់ការខូចខាតបរិស្ថាននោះឡើយ។ ក្នុងការអនុវត្តគោលការណ៍ស្តីពីការបង្ការមុន ការសម្រេចចិត្តជាសាធារណៈ និងឯកជនគប្បីត្រូវអនុវត្តតាមការណែនាំ ដូចខាងក្រោម៖

- ទីណាដែលអាចធ្វើបាន ត្រូវមានការវាយតម្លៃដោយប្រុងប្រយ័ត្នដើម្បីបញ្ចៀសនូវការខូចខាតបរិស្ថានធ្ងន់ធ្ងរ ឬមិនអាចស្តារឡើងវិញបាន និង
- ការវាយតម្លៃផលវិបាកដោយមានការថ្លឹងថ្លែងហានិភ័យពាក់ព័ន្ធនឹងជម្រើសផ្សេងៗ។[24]

## ការអនុវត្តគោលការណ៍សមធម៌មនុស្សអន្តរជំនាន់

គោលការណ៍នៃសមធម៌អន្តរជំនាន់ ចែងថា មនុស្សជំនាន់បច្ចុប្បន្ន គប្បីត្រូវតែធានាថាសុខភាព ភាពចម្រុះ និងផលិតភាពនៃបរិស្ថានត្រូវបានថែរក្សាការពារ ឬត្រូវធ្វើឲ្យប្រសើរឡើងដើម្បីជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយ។ ចំណុចនេះតម្រូវឱ្យមានការគិតពិចារណាអំពីផលប៉ះពាល់ដោយសារសកម្មភាព ឬគម្រោងដែលបានស្នើសុំ ដោយត្រូវគិតពិចារណាអំពីផលប៉ះពាល់រយៈពេលវែង។ ត្រង់នេះ ក៏អាចតម្រូវឱ្យមានការគិតពិចារណាអំពីការកំចាត់សារធាតុចម្លងមេរោគនៅតាមការដ្ឋានពេលបិទឬបញ្ចប់គម្រោងដែរ។

## ការអភិរក្សជីវចម្រុះ និងបូរណភាពអេកូឡូស៊ីគឺជាការគិតពិចារណាជាចម្បង

[23] Rio Declaration 1992, Principle 22.
[24] Inter-Governmental Agreement on the Environment, signed by the Australian Government and its States and Territories and Local Government, 1 May 1992, www.environment.gov.au/about-us/esd/publications/intergovernmental-agreement.

ចំណុចចាប់ផ្តើមសម្រាប់ការវាយតម្លៃលើសំណើគម្រោងអភិវឌ្ឍន៍គឺគប្បីត្រូវគិតពិចារណាជាចម្បងអំពីការអភិរក្សជីវចម្រុះ និងបូរណភាពអេកូឡូស៊ី។[25] នេះមិនមែនមានន័យថា គ្មានគម្រោងណាដែលអាចទទួលបានការអនុម័តហើយនឹងមិនបង្កគ្រោះថ្នាក់ដល់បរិស្ថាននោះទេ។ វាគ្រាន់តែធានាថា គ្រោះថ្នាក់និងការខូចខាតដល់បរិស្ថាន និងសង្គមត្រូវតែមានការពន្យល់ហេតុផលត្រឹមត្រូវដោយគម្រោង។ គម្រោងត្រូវតែមានការវាយតម្លៃជម្រើសផ្សេងៗ និងស្នើនូវវិធីផ្សេងៗដើម្បីបញ្ចៀស ឬកាត់បន្ថយគ្រោះថ្នាក់ដែលអាចនឹងកើតឡើង។ ប្រសិនបើ មិនអាចបញ្ចៀសការខូចខាតនោះបានទេ ត្រូវតែផ្តល់សំណងសមរម្យចំពោះការខូចខាតដែលកើតឡើងនោះ។

## ការវាយតម្លៃ ការកំណត់តម្លៃ និងការលើកទឹកចិត្តកាន់តែល្អប្រសើរ

ការប្រើប្រាស់ឧបករណ៍សេដ្ឋកិច្ចនេះ សំខាន់ណាស់ចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថានប្រកបដោយប្រសិទ្ធភាព។ កត្តាបរិស្ថានគប្បីត្រូវបញ្ចូលទៅក្នុងការវាយតម្លៃទ្រព្យសម្បត្តិ និងសេវាកម្ម រួមទាំងការផ្តល់សេវាកម្មប្រព័ន្ធអេកូឡូស៊ីផង។ ចំណុចនេះមានសារសំខាន់ជាពិសេសក្នុងការវាយតម្លៃ ចំណាយនិងចំណេញរបស់គម្រោង។ លើសពីនេះទៅទៀត ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គប្បីត្រូវប្រើគោលការណ៍ "អ្នកបំពុលត្រូវបង់ថ្លៃ"។[26] គោលការណ៍នេះច្រើនតែមានការកំណត់ និយមន័យថា អ្នកដែលបង្កឲ្យមានការបំពុលបរិស្ថាន និងមានកាកសំណល់ គប្បីត្រូវទទួលបន្ទុកលើចំណាយលើការទប់ស្កាត់ ការបញ្ចៀស ឬលើការកាត់បន្ថយនោះ។

វិធានការផ្នែកសេដ្ឋកិច្ចមួយទៀតគឺ អ្នកប្រើប្រាស់ទំនិញនិងសេវាកម្ម គប្បីត្រូវបង់ថ្លៃ ដោយផ្អែកលើមូលដ្ឋានចំណាយពេញមួយវដ្តជីវិតនៃការផ្គត់ផ្គង់ទំនិញនិងសេវានានា រួមទាំងការប្រើប្រាស់ធនធានធម្មជាតិ និងទ្រព្យសម្បត្តិ ព្រមទាំងការបោះចោលកាកសំណល់ចុងក្រោយ។[27]

## ការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការចូលរួមជាសាធារណៈត្រូវបានទទួលស្គាល់ថា ជាផ្នែកយ៉ាងសំខាន់នៃដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ ការចូលរួមជាសាធារណៈត្រូវបានកំណត់នៅក្នុងសេចក្តីប្រកាសទីក្រុង

[25] See for example the National Environment Policy of Myanmar 1994 that makes environmental protection the primary objective in seeking development.
[26] Rio Declaration, Principle 16.
[27] Rio Declaration, Principle 8, Principle 13, Principle 16.

រីយ៉ូ ឆ្នាំ១៩៩២ ហើយត្រូវបានគេទទួលយកជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន តាំងពីពេលចាប់ផ្តើមការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅទសវត្សរ៍ ឆ្នាំ១៩៧០មកម្ល៉េះ។

| |
|---|
| គោលការណ៍ទី១០នៃសេចក្តីប្រកាសនៅទីក្រុងរីយ៉ូះ<br>បញ្ហាបរិស្ថានត្រូវបានដោះស្រាយល្អបំផុត ដោយការចូលរួមរបស់ប្រជាពលរដ្ឋពាក់ព័ន្ធទាំងអស់ នៅកម្រិតសមស្រប។ នៅកម្រិតថ្នាក់ជាតិ បុគ្គលម្នាក់ៗ ត្រូវមានសិទ្ធិទទួលបានព័ត៌មានសមស្របពាក់ព័ន្ធនឹងបរិស្ថានដែលព័ត៌មានទាំងនោះគ្រប់គ្រងដោយអាជ្ញាធរ ដូចជាព័ត៌មានអំពីសម្ភារៈនិងសកម្មភាពដែលមានគ្រោះថ្នាក់ដល់សហគមន៍ ព្រមទាំងមានឱកាសបានចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច។ បណ្តាប្រទេសនានា ត្រូវជួយសម្រួល និងលើកទឹកចិត្តឲ្យមានការយល់ដឹង និងការចូលរួមជាសាធារណៈ ដោយត្រូវប្រកាសផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយ។ ត្រូវផ្តល់ជូននូវសិទ្ធិចូលរួមដោយប្រសិទ្ធភាព ក្នុងដំណើរការនីតិវិធីរដ្ឋបាលនិងតុលាការ រួមទាំងការផ្តល់ដំណោះស្រាយ និងសំណងផង។[28] |

អត្ថប្រយោជន៍ខ្លះអាចមានការលំបាកក្នុងការផ្តល់តម្លៃ ដូចជា ការធ្វើការសម្រេចចិត្តបានល្អប្រសើរ ឬការពង្រឹកសេចក្តីទុកចិត្តកាន់តែធំធេងនៅតាមការិយាល័យរដ្ឋាភិបាលជាដើម។ អត្ថប្រយោជន៍ផ្សេងទៀត ដូចជា ការរៀបចំបង្កើតគម្រោងបានល្អប្រសើរ ការគ្រប់គ្រងបរិស្ថានដែលមានប្រសិទ្ធភាព ឬដំណើរការបណ្តឹងសាទុក្ខដែលមានប្រសិទ្ធភាព ជាដើម អាចមានការលំបាកក្នុងការវាស់វែង ប៉ុន្តែអាចផ្តល់នូវផលប្រយោជន៍ពិតប្រាកដដល់បណ្តាសហគមន៍ដែលរងផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍។

ដូចគ្នានេះដែរ ដោយសារតែការចូលរួមជាសាធារណៈស្ថិតលើទស្សនៈនៃវិធីសាស្ត្រ និងការអនុវត្តធំទូលំទូលាយ ដូច្នេះការជ្រើសរើសវិធីសាស្ត្រដែលពាក់ព័ន្ធ និងមានប្រសិទ្ធភាពបំផុតអាចមានការលំបាក។ សមាគមអន្តរជាតិដើម្បីការចូលរួមជាសាធារណៈ បានបង្កើតទស្សនៈមួយសម្រាប់ការចូលរួមជាសាធារណៈ។ យើងប្រើទស្សនៈនេះនៅក្នុងគោលការណ៍ណែនាំនេះ។ ការចូលរួមជាសាធារណៈល្អ ត្រូវពឹងផ្អែកលើរបៀបនៃការគ្រប់គ្រងជំហាននីមួយៗ។

ក្នុងករណីច្រើនបំផុត អ្នកស្នើសុំគម្រោង និងអ្នកពិគ្រោះយោបល់អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គប្បីត្រូវរៀបចំផែនការស្តីពីការចូលរួមជាសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធ។ ផែនការ

[28] Rio Declaration, Principle 10.

ដែលត្រូវគេហៅម្យ៉ាងទៀតដែរថា ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធនោះគឺជាផែនទីបង្ហាញផ្លូវ ឬមគ្គុទេសក៍ឆ្ពោះទៅរកការចូលរួម និងការពិគ្រោះយោបល់ ដែលនឹងប្រព្រឹត្តទៅក្នុងអំឡុងពេលនៃដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ផែនការចូលរួមជាសាធារណៈចាំបាច់ត្រូវតែសមស្របនឹងគម្រោង និងបរិស្ថាននៅមូលដ្ឋាន ព្រមទាំងសហគមន៍ ហើយត្រូវតម្រូវតាមគម្រោងជាក់លាក់នោះ។

ជានិច្ចកាល គេត្រូវទទួលស្គាល់ថា ការពិគ្រោះយោបល់មិនមែនជាការចូលរួមទេ។ វាគឺជាផ្នែកមួយនៃដំណើរការ។ ការផ្លាស់ប្តូរព័ត៌មានមានសារសំខាន់ ហើយការឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងដោយភាគីពាក់ព័ន្ធគឺជាផ្នែកយ៉ាងសំខាន់នៃការចូលរួមជាសាធារណៈ។

# IAP2 Spectrum of Public Participation

International Association for Public Participation

*Increasing Level of Public Impact* →

| | Inform | Consult | Involve | Collaborate | Empower |
|---|---|---|---|---|---|
| **Public participation goal** | To provide the public with balanced and objective information to assist them in understanding the problem, alternatives, opportunities and/or solutions. | To obtain public feedback on analysis, alternatives and/or decisions. | To work directly with the public throughout the process to ensure that public concerns and aspirations are consistently understood and considered. | To partner with the public in each aspect of the decision including the development of alternatives and the identification of the preferred solution. | To place final decision-making in the hands of the public. |
| **Promise to the public** | We will keep you informed. | We will keep you informed, listen to and acknowledge concerns and aspirations, and provide feedback on how public input influenced the decision. | We will work with you to ensure that your concerns and aspirations are directly reflected in the alternatives developed and provide feedback on how public input influenced the decision. | We will look to you for advice and innovation in formulating solutions and incorporate your advice and recommendations into the decisions to the maximum extent possible. | We will implement what you decide. |
| **Example techniques** | ▪ Fact sheets<br>▪ Web sites<br>▪ Open houses | ▪ Public comment<br>▪ Focus groups<br>▪ Surveys<br>▪ Public meetings | ▪ Workshops<br>▪ Deliberative polling | ▪ Citizen advisory committees<br>▪ Consensus-building<br>▪ Participatory decision-making | ▪ Citizen juries<br>▪ Ballots<br>▪ Delegated decision |

© 2007 International Association for Public Participation

ការចូលរួមជាសាធារណៈបានក្លាយជាផ្នែកមួយនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចាប់តាំងពីច្បាប់ស្តីពីគោលនយោបាយបរិស្ថានជាតិសហរដ្ឋអាមេរិក ដែលត្រូវបានបង្កើតឡើងជាផ្លូវការ នៅសហរដ្ឋអាមេរិក នៅឆ្នាំ១៩៦៩នោះម្ល៉េះ។[29] ដោយបណ្តាសហគមន៍អន្តរជាតិបានកែសម្រួល និងអនុម័តប្រើប្រាស់ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ ដូច្នេះហើយ ការចូលរួមជាសាធារណៈនៅតែជាកត្តាយ៉ាងសំខាន់នៃដំណើរការវាយតម្លៃ។ ចំណុចនេះត្រូវបានទទួលស្គាល់ដោយគោលការណ៍ទី១០នៃសេចក្តីប្រកាសទីក្រុងរីយ៉ូ ឆ្នាំ១៩៩២ ដែលបានបញ្ជាក់ថា៖ "បញ្ហាបរិស្ថានត្រូវដោះស្រាយបានយ៉ាងល្អបំផុត ដោយមានការចូលរួមពីពលរដ្ឋដែលពាក់ព័ន្ធទាំងអស់ នៅតាមលំដាប់ថ្នាក់សមស្រប"។ នៅឆ្នាំ១៩៩៨ គណៈកម្មាធិការសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិដើម្បីអឺរ៉ុប បានចរចាអនុសញ្ញាស្តីពីសិទ្ធិទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេច និងសិទ្ធិទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន (អនុសញ្ញាក្រុងអាហ៊្វស, អាហ៊្វស convention)។ អនុសញ្ញាក្រុងអាហ៊្វស ទទួលស្គាល់ថា ការចូលរួមជាសាធារណៈធ្វើឲ្យការសម្រេចចិត្ត និងធ្វើឲ្យគុណភាពនិងការអនុវត្តសេចក្តីសម្រេចចិត្ត កាន់តែល្អប្រសើរ។

អនុសញ្ញាក្រុងអាហ៊្វសមាននិយមន័យមួយចំនួនដូចខាងក្រោម៖

| |
|---|
| "**សាធារណៈ**" មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល ម្នាក់ឬច្រើននាក់ និងយោងតាមច្បាប់ជាតិ ឬការអនុវត្តថ្នាក់ជាតិគឺ សមាគម អង្គការ ឬក្រុមរបស់រូបវន្ត ឬនីតិបុគ្គលនោះ<br><br>"**សាធារណជនពាក់ព័ន្ធ**" មានន័យថា សាធារណជនដែលបានរងផលប៉ះពាល់ ឬនឹងត្រូវរងផលប៉ះពាល់ដោយ ឬសាធារណជនដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកបរិស្ថាន។ ក្នុងគោលបំណងនៃការផ្តល់និយមន័យនេះ អង្គការមិនមែនរដ្ឋាភិបាលដែលមានបេសកកម្មលើកកម្ពស់ការការពារបរិស្ថាន ហើយដែលបានបំពេញលក្ខខណ្ឌច្បាប់ជាតិ ត្រូវបានចាត់ទុកថា ជាភាគីមានការចាប់អារម្មណ៍។ |

ទោះបីជា មាត្រា៦ បញ្ជាក់អំពីបទប្បញ្ញត្តិសម្រាប់ការចូលរួមជាសាធារណៈក្នុងការសម្រេចចិត្តលើសកម្មភាពជាក់លាក់ក៏ដោយ ក៏វាមាននិយមន័យមិនច្បាស់លាស់អំពីអ្វីដែលជាការចូលរួមជាសាធារណៈពេញលេញនោះឡើយ។ កត្តាមួយចំនួនត្រូវបានទទួលស្គាល់នៅក្នុងមាត្រា៦៖

- ការជូនដំណឹងពីដំបូង

[29] Glucker et al, *Public Participation in environmental impact assessment: why, who and how?*, EIA Review 43, 2013, pp.104-11.

- គ្រប់គ្រាន់
- ទាន់ពេល
- មានប្រសិទ្ធភាព
- លក្ខណៈរបស់សំណើសុំ
- អត្តសញ្ញាណរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត
- នីតិវិធីសម្រាប់ឲ្យសាធារណជនផ្តល់យោបល់
- ពេលកំណត់សម្រាប់ការផ្តល់យោបល់គ្រប់គ្រាន់ និង
- តើសំណើសុំនោះត្រូវស្ថិតក្រោមការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរឬទេ ឬត្រូវស្ថិតក្រោមនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដែរឬទេ។

**អត្ថន័យអំពីការចូលរួមជាសាធារណៈ**

ការពិនិត្យឡើងវិញនាពេលថ្មីៗនេះអំពីការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានកំណត់ច្បាស់ថា វាមិនមែនចេះតែច្បាស់លាស់ជានិច្ចចំពោះអ្វីដែលជាអត្ថន័យនៃ "ការចូលរួមជាសាធារណៈ" ឬអ្វីជា "ការពិគ្រោះយោបល់សហគមន៍" ហើយវាក៏មិនចេះតែច្បាស់លាស់ចំពោះអ្វីដែលថា "សាធារណៈ" ឬ "សហគមន៍" នោះដែរ។ គេក៏បានកត់សម្គាល់ឃើញដែរថា មានការខ្វែងគំនិតគ្នាយ៉ាងច្រើន ពាក់ព័ន្ធនឹងគោលបំណងជាក់លាក់នៃការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[30]វាមិនគ្រាន់តែពាក់ព័ន្ធនឹងការជជែកពិភាក្សាដែលមានតែទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំង "ឆ្លុះបញ្ចាំងទៅលើការអនុវត្តដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន" ថែមទៀតផង។[31]

ដូចគ្នានោះ វាក៏មាន "ជម្លោះច្រើនគួរចាប់អារម្មណ៍" ដែរ ពាក់ព័ន្ធនឹងនិយមន័យនៃការចូលរួមជាសាធារណៈ។[32] Glucker និងអ្នកផ្សេងទៀត បានកំណត់គោលបំណងសំខាន់ៗចំនួនប្រាំបួនសម្រាប់ការចូលរួមជាសាធារណៈ៖

- ធ្វើឲ្យមានឥទ្ធិពលលើការសម្រេចចិត្ត
- បង្កើនសមត្ថភាពបែបប្រជាធិបតេយ្យ
- រៀនអំពីសង្គម
- ផ្តល់សិទ្ធិអំណាចជូន និងរំដោះប្រជាជននិងក្រុមដែលទន់ខ្សោយ
- គ្រប់គ្រងនិងប្រើប្រាស់ព័ត៌មានព្រមទាំងចំណេះដឹងនៅមូលដ្ឋាន

[30] Glucker, et al, 2013, p.104.
[31] Glucker, et al, 2013, p.106.
[32] Glucker, et al, 2013, p.106.

- បញ្ចូលចំណេះដឹងផ្អែកលើគុណតម្លៃនិងបទពិសោធន៍
- ពិនិត្យសភាពរឹងមាំនៃព័ត៌មានពីប្រភពផ្សេងៗទៀត
- បង្កើតភាពស្របច្បាប់សម្រាប់ការសម្រេចចិត្ត និង
- ការដោះស្រាយជម្លោះ។

បន្ថែមលើនេះទៀត វាពុំមែនចេះតែមានការយល់ដឹង និងការព្រមព្រៀងច្បាស់លាស់ជានិច្ចថា តើអ្នកណាគប្បីត្រូវចូលរួមនោះទេ។ តើឲ្យតែអ្នកដែលមានការចាប់អារម្មណ៍ លើគម្រោងឬលទ្ធផល ឬអ្នកដែលមានការចាប់អារម្មណ៍ដោយមានការទទួលស្គាល់ សុទ្ធអ្នកដែលគប្បីត្រូវតែចូលរួម? វិធីសាស្ត្រកៀរគរអ្នកចូលរួម អាចនាំឱ្យកាន់តែមានភាពស្របច្បាប់ ប៉ុន្តែមិនមែនធនធានគួរខ្លាច និងសមត្ថភាពមានកម្រិតដែលបានផ្តល់ឲ្យនោះទេ។ តើវិធីសាស្ត្រនោះនឹងដាក់បន្ទុកបន្ថែមលើប្រព័ន្ធនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទេ?[33]

នៅក្នុងប្រទេសជាច្រើន រួមទាំងប្រទេសកូស្តារីកា និងនីការាហ្គ័រផង ការបរាជ័យក្នុងការពិចារណាលើយោបល់ និងសំណើដាក់ជូនដែលទទួលបានពីសាធារណជន បានបណ្តាលឲ្យប្រជាជន "មិនចូលរួមជាផ្លូវការក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយបែរជាអនុវត្តទម្រង់នៃការចូលរួមមិនផ្លូវការ ជំនួសវិញ (ដូចជា ការដើរដង្ហែតវ៉ា ធ្វើពហិការ ជាដើម)"។[34]

អ្នកស្រី Cheryl Wasserman មកពីការិយាល័យការពារបរិស្ថានសហរដ្ឋអាមេរិក កត់សម្គាល់ថា "ការចូលរួមជាសាធារណៈប្រកបដោយអត្ថន័យ មិនមែនគ្រាន់តែតម្រូវឱ្យ បើកកិច្ចប្រជុំ ឬបើកវេទិកាសាធារណៈ ឬគ្រាន់តែប្រមូលយកយោបល់របស់សាធារណជននោះទេ"។[35] នៅសហរដ្ឋអាមេរិក គេផ្តោតខ្លាំងលើការចូលរួម និងការពិចារណាអំពីបញ្ហាដែលលើកឡើងដោយការចូលរួម។[36] ល្អបំផុត ការចូលរួមជាសាធារណៈនិងផ្តល់ឱកាសឱ្យសាធារណជន ប្រើឥទ្ធិពលដោយស្របច្បាប់ និងដោយសន្តិវិធីលើការសម្រេចចិត្ត។ អ្នកស្រីបានកំណត់នូវហេតុផលមួយចំនួននៅពីក្រោយការដាក់បញ្ចូលការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចខាងក្រោម៖

---

[33] Glucker, et al, 2013, p.109.
[34] Glucker, et al, 2013, p.109.
[35] Wasserman (2012), Cheryl Wasserman, USEPA, Application of Public Participation Principles in EIA, Jakarta, Indonesia, 10-11 July 2012. Wasserman (2014), Cheryl Wasserman, USEPA, Associate Director for Policy Analysis, National Environmental Policy Act (NEPA) Regulations, Guidelines and Experience, November 19, 2014, epa.connectsolutions.com/p6qgkt3cfqh.
[36] Citizens Guide to NEPA, USEPA, 2007, https://ceq.doe.gov/nepa/Citizens_Guide_Dec07.pdf.

- ព័ត៌មានពាក់ព័ន្ធ
- ការសម្រេចចិត្តកាន់តែល្អប្រសើរ
- កសាងការយល់ដឹងនិងភាពស្របច្បាប់
- ច្រើនតែទទួលបានលទ្ធផលក្នុងដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត
- តួនាទីមានប្រយោជន៍ក្នុងការពិនិត្យតាមដានលើការអនុវត្ត
- កាត់បន្ថយការចំណាយ និងការពន្យារពេលពីជម្លោះមិនទាន់បានដោះស្រាយ និង
- សម្របសម្រួលការអនុវត្ត។

អ្នកស្រីបានបង្ហាញធាតុ៩ចំនុច ដើម្បីកំណត់នូវតួនាទីនៃការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចខាងក្រោម៖

- យល់អំពីតម្រូវការចូលរួមជាសាធារណៈ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បញ្ចូលគោលការណ៍ចូលរួមជាសាធារណៈក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- កំណត់អត្តសញ្ញាណសាធារណជន និងអ្នកពាក់ព័ន្ធ
- កំណត់និយមន័យនៃតួនាទីរបស់ភាគីពាក់ព័ន្ធ/សាធារណជនក្នុងការធ្វើសេចក្តីសម្រេចចិត្ត
- បង្កើត និងអនុវត្តឧបករណ៍តម្រូវតាមការចូលរួមជាសាធារណៈ
- ឆ្លើយតបទៅនឹងផលប្រយោជន៍៖ បញ្ចៀស កាត់បន្ថយ ទូទាត់សំណង
- អនុវត្តការដោះស្រាយជម្លោះបរិស្ថាន
- តម្លាភាព និងចងក្រងឯកសារ និង
- កំណត់និយមន័យនៃការអនុវត្តទៅតាមលក្ខខណ្ឌនៃសូចនាករជោគជ័យ។[37]

លើសពីនេះទៅទៀត ច្បាប់ស្តីពីគោលនយោបាយបរិស្ថានសហរដ្ឋអាមេរិកបានកំណត់ មេរៀនដែលស៊ីសង្វាក់គ្នាប្រាំសម្រាប់ការទទួលបានជោគជ័យពីការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺ៖

- សម្រួលដំណើរការឲ្យត្រូវនឹងតម្រូវការនៃស្ថានភាព
- ចុះទៅជួបនិងស្វែងយល់អំពីក្រុមគោលដៅ
- ឆាប់ចាប់ផ្តើមក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ចាត់ទុកការពិគ្រោះយោបល់ជាសាធារណៈ និងការចូលរួមជាដំណើរការអនុវត្តប្រចាំមិនមែនជាព្រឹត្តិការណ៍តែម្តងចប់នោះទេ និង

[37] Wasserman, 2014.

- ព្យាយាមរកវិធីដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភដោយគ្មានការសម្រុះសម្រួលបូរណភាពវិទ្យាសាស្ត្រ ច្បាប់ ឬលទ្ធភាព។[38]

លើសពីនេះទៅទៀត បទពិសោធន៍នៅសហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលីបានកំណត់យន្តការផ្សេងៗគ្នាជាច្រើនដើម្បីប្រមូលព័ត៌មាន និងគំនិតពីភាគីពាក់ព័ន្ធ។ យន្តការទាំងនេះអាចមានចំណុចណាមួយនៃចំណុចខាងក្រោមនេះ៖

- សវនាការសាធារណៈ
- រយៈពេលផ្តល់យោបល់ជាសាធារណៈដែលសុំឲ្យមានសរសេរលិខិតផ្តល់យោបល់
- កិច្ចប្រជុំជាសាធារណៈ
- កិច្ចប្រជុំក្រុមតូច ក្រុមគោលដៅ ឬសិក្ខាសាលាក្រុមគោលដៅ
- ក្រុមប្រឹក្សាយោបល់ និងការងារពិសេស
- ការចេញផ្សាយដំណឹង ព្រឹត្តិបត្រដែលមានទម្រង់ផ្តល់យោបល់ជាសាធារណៈ តារាងសង្ខេបព័ត៌មាន ខិត្តប័ណ្ណ
- ប្រព័ន្ធផ្សព្វផ្សាយ - បទយកការណ៍ សំភាសន៍ សេចក្តីប្រកាសសេវាសាធារណៈ
- វីបសាយគម្រោង/កម្មវិធី
- ឃ្លាំងសាព័ត៌មាន ឬមណ្ឌលផ្តល់ព័ត៌មាន
- ការិយាល័យវាគ្មិន
- ការស្រង់ព័ត៌មាន ឬការស្ទង់មតិ
- បញ្ជីសំបុត្រ
- ការសង្ខេបដោយនិងសម្រាប់មន្ត្រីសាធារណៈ
- បណ្តាញព័ត៌មានសង្គម (ដូចជា ហ្វេសប៊ុក ធ្វីតធ័រ។ល។) និង
- ចក្ខុវិស័យ។[39]

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងការអនុវត្តជាក់ស្តែងនៅតំបន់ទន្លេមេគង្គ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានប្រើប្រាស់ស្ទើរគ្រប់ប្រទេសនៅលើពិភពលោក។ មានការលើកឡើងថា បណ្តាប្រទេសចំនួន១៩១ប្រទេសក្នុងចំណោម១៩៣ប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិ មានទាំងច្បាប់ជាតិផង ឬបានចុះហត្ថលេខាលើសំណុំលិខិតុបរណ៍អន្តរជាតិផងយោងទៅលើការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[40] ការរីករាល

[38] Wasserman, 2012.
[39] Wasserman, 2012.
[40] Morgan, 2012.

ដាលនៅទូទាំងពិភពលោកនូវការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានគាំទ្រដោយគោលការណ៍ទី១៧នៃសេចក្តីប្រកាសទីក្រុងរីយ៉ូ ដែលបញ្ជាក់ថា បណ្តាប្រទេសហត្ថលេខីត្រូវតែអនុវត្ត ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន "ចំពោះបណ្តាសកម្មភាពដែលបានស្នើឡើង ហើយដែលអាចនឹងបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងលើបរិស្ថាន និងដែលត្រូវស្ថិតក្រោមកម្មវត្ថុនៃការសម្រេចចិត្តរបស់អាជ្ញាធរសមត្ថកិច្ចថ្នាក់ជាតិ"។[41]

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតំបន់ទន្លេមេគង្គ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជា ដំណើរការដែលប្រើប្រាស់ដោយរដ្ឋាភិបាលទាំងអស់នៅក្នុងតំបន់ទន្លេមេគង្គ ដើម្បីវាយតម្លៃអំពីផលប៉ះពាល់ដែលអាចកើតឡើងពីសំណើគម្រោងអភិវឌ្ឍន៍ និងដើម្បីពិចារណារកជម្រើស និងយុទ្ធសាស្ត្រគ្រប់គ្រងផ្សេងៗ ដែលជាផ្នែកនៃការសម្រេចចិត្តថា តើត្រូវបន្ត ឬមិនបន្តគម្រោងអភិវឌ្ឍន៍ដែលស្នើសុំនោះ។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានទទួលស្គាល់ថា ជាឧបករណ៍យ៉ាងសំខាន់សម្រាប់វាយតម្លៃ និងវិភាគអំពីហេតុប៉ះពាល់បរិស្ថាន សង្គម សេដ្ឋកិច្ច និងផលប៉ះពាល់ផ្សេងៗទៀតដែលបណ្តាលមកពីគម្រោងណាមួយ ហើយរៀបចំនិងរកវិធីដើម្បីបញ្ចៀសកាត់បន្ថយ ឬគ្រប់គ្រងផលប៉ះពាល់ដែលអាចកើតឡើងនោះ។ វាក៏ជាដំណើរការដែលគេប្រើប្រាស់ដែរដើម្បីកំណត់អត្តសញ្ញាណ និងឆ្លើយតបទៅនឹងការព្រួយបារម្ភចម្បងៗរបស់ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

ដំណើរការពីដំបូងដល់ចប់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវតែបញ្ចប់ មុនពេលទទួលបានការយល់ព្រមឲ្យអនុវត្តគម្រោងជាក់លាក់ណាមួយ។ ត្រង់ចំណុចនេះ វាពិតជាសំខាន់ណាស់ ដោយហេតុថា គោលបំណងសំខាន់មួយក្នុងចំណោមគោលបំណងសំខាន់ៗនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺការធានាបានថា ផលប៉ះពាល់អវិជ្ជមានពីសំណើសុំអនុវត្តគម្រោងត្រូវបានបញ្ចៀស ឬយ៉ាងហោចណាស់ក៏ត្រូវបានបន្ថយ ឬកាត់បន្ថយដែរ មុនពេលផលប៉ះពាល់កើតឡើង។ វាក៏សំខាន់ដែរ ដែលត្រូវឆ្លើយតបនឹងគោលបំណងនៃការធានាថាពលរដ្ឋរងផលប៉ះពាល់មានឱកាសក្នុងការចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។

[41] Morrison-Saunders, 2012, pp 34-41.




*រូបទី១៖ ទិដ្ឋភាពទូទៅអំពីដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន*[42]

[42] PACT RTWG Draft Guidelines on Public Participation (2015).

ប្រទេសនីមួយៗចាត់តាំងក្រសួង ឬនាយកដ្ឋានជាក់លាក់ឲ្យទទួលខុសត្រូវលើដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ នៅក្នុងប្រទេសទាំងអស់នៅតំបន់ទន្លេមេគង្គ ការអង្កេត និងការរៀបចំរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តដោយអ្នកទីប្រឹក្សាយោបល់ផ្នែកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលជួលដោយអ្នកស្នើសុំគម្រោង។ ទីប្រឹក្សាពិគ្រោះយោបល់ផ្នែកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តការវាយតម្លៃ និងរៀបចំធ្វើការសិក្សា ដែលបង្កើតបាននូវមូលដ្ឋានសម្រាប់ធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជាដំណើរការដែលគេអាចចែកជាជំហានៗ។ ជំហាននីមួយៗសុទ្ធតែជាផ្នែកនៃដំណើរការនេះ។ គេត្រូវអនុវត្តតាមនូវជំហានទាំងអស់នេះ ដើម្បីសម្រេចដោយអនុលោមតាមនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ទោះបីជា ប្រទេសនីមួយៗពុំមានប្រព័ន្ធនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានផ្ទាល់ខ្លួនក៏ដោយ ក៏ប្រទេសនោះមានប្រព័ន្ធនៃការវាយតម្លៃស្រដៀងៗគ្នាមួយចំនួនដែរ។

## ជំហានក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ប្រព័ន្ធនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងតំបន់ទន្លេមេគង្គ និងនៅតាមបណ្តាប្រទេសជាច្រើនទូទាំងពិភពលោក ជាទូទៅមានស្ទើរតែគ្រប់ជំហាន ឬមានជំហានទាំងអស់ដូចខាងក្រោមនេះ៖

1. ការពិនិត្យ
2. ការកំណត់វិសាលភាពឬកំណត់លក្ខខណ្ឌយោង
3. ការប្រមូលទិន្នន័យដោយទីប្រឹក្សាពិគ្រោះយោបល់ផ្នែកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
4. ការរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
5. ការរៀបចំផែនការគ្រប់គ្រងបរិស្ថាននិងសង្គម
6. ការស្នើដាក់ជូនរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
7. ការវាយតម្លៃលើរបាយការណ៍ស្តីពីលទ្ធផលវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងផែនការគ្រប់គ្រងបរិស្ថាន និងសង្គម
8. សេចក្តីសម្រេចថា តើអនុម័តឬមិនអនុម័តលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាននិងសង្គម
9. ការចេញវិញ្ញាបនប័ត្រប្រតិបត្តិបរិស្ថាន
10. អនុម័តផ្តល់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតផ្សេងៗទៀត

11. ការចាប់ផ្តើមដំណើរការសាងសង់
12. ការចាប់ផ្តើមដំណើរការប្រតិបត្តិការ
13. ការពិនិត្យតាមដាន និងប្រតិបត្តិទៅតាមវិញ្ញាបនប័ត្រប្រតិបត្តិបរិស្ថាន ព្រមទាំងផែនការគ្រប់គ្រងបរិស្ថាននិងសង្គម, និង
14. ការបិទ ឬបញ្ចប់គម្រោង។

ដំណើរការនេះមានបង្ហាញនៅក្នុងតារាងរំហូរ ក្នុងរូបទី១។ វាត្រូវបានយកមកពីអង្គការភាពជាដៃគូសម្រាប់ក្រុមការងារគុម្ពលផ្នែកបរិស្ថានស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ដើម្បីជាការពិចារណាអំពីវិធីសាស្ត្រដែលកាន់តែសាមញ្ញបន្ថែមទៀតចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បណ្តាជំហានដូចខាងក្រោមនេះ អាចត្រូវបានកំណត់ថាជាផ្នែកយ៉ាងសំខាន់នៃដំណើរការការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន៖

1. ការពិនិត្យ
2. ការកំណត់វិសាលភាព
3. ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការរៀបចំរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាននិងសង្គម
4. ការពិនិត្យឡើងវិញលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាននិងសង្គម
5. ការសម្រេចចិត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន និង
6. ការពិនិត្យតាមដាន និងការប្រតិបត្តិ

ជំហាននីមួយៗ ផ្តល់ឱកាសឲ្យប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធផ្សេងៗទៀត ចូលរួម។ ហេតុដូច្នេះហើយ ជំហានទាំងប្រាំមួយនេះ ត្រូវបានប្រើប្រាស់ជាផ្នែកយ៉ាងសំខាន់សម្រាប់សៀវភៅណែនាំនេះ។

**ជំហានទី ១៖ ការពិនិត្យ**

ដំណាក់កាលដំបូងក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជា ការពិនិត្យ។ ការពិនិត្យគឺជាផ្នែកសំខាន់មួយ ក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ជាទូទៅ វាជាពេលដំបូងដែលអ្នកគាំទ្រគម្រោង ត្រូវពិភាក្សាអំពីគម្រោងដែលស្នើសុំជាមួយរដ្ឋាភិបាល

និងជាមួយសហគមន៍។ លទ្ធផលសំខាន់ៗសម្រាប់ជំហាននៃការពិនិត្យគឺរបាយការណ៍ស្តីពីការពិនិត្យគម្រោង។

ភាគច្រើននៃបញ្ជីពិនិត្យគម្រោងនៅក្នុងប្រទេសមហាអនុតំបន់ទន្លេមេគង្គ ប្មូកបញ្ចូលគ្នានូវកត្តាទាំងនេះទៅក្នុងបញ្ជីឈ្មោះគម្រោង ដែលតម្រូវឱ្យធ្វើការរៀបចំដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ប៉ុន្តែបញ្ជីឈ្មោះគម្រោងដែលត្រូវពិនិត្យ អាចដកចេញនូវការបែងចែកប្រភេទដែលជាប្រធានបទនៃគម្រោងអភិវឌ្ឍន៍។ សំខាន់គឺត្រូវធ្វើឲ្យប្រាកដជានិច្ចថា គម្រោងទាំងអស់ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់បរិស្ថាន ឬសង្គមធ្ងន់ធ្ងរ ត្រូវស្ថិតនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មិនមែនតែបណ្តាគម្រោងដែលនៅក្នុងបញ្ជីដែលត្រូវពិនិត្យនោះទេ។

**ជំហានទី ២៖ ការកំណត់វិសាលភាព**

ការកំណត់វិសាលភាពជាជំហានសំខាន់ ក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ វាជាដំណើរការសម្រាប់កំណត់វិសាលភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ឧទាហរណ៍ ទិន្នន័យដែលចាំបាច់ត្រូវប្រមូល និងវិភាគដើម្បីវាយតម្លៃហេតុប៉ះពាល់ដោយសារគម្រោង) និងបង្កើតចេញជា លក្ខខណ្ឌការងារសម្រាប់ការរៀបចំធ្វើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[43]

ការកំណត់វិសាលភាព គឺជាពេលដំបូងដែលអ្នកស្នើសុំគម្រោង ត្រូវពិភាក្សាអំពីគម្រោងដែលបានស្នើសុំជាមួយរដ្ឋាភិបាលនិងជាមួយសហគមន៍។ លទ្ធផលសំខាន់សម្រាប់ធ្វើរបាយការណ៍ស្តីពីការកំណត់វិសាលភាពគឺ ការរៀបចំសេចក្តីព្រាងលក្ខខណ្ឌការងារសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលស្នើសុំ។ សេចក្តីព្រាងលក្ខខណ្ឌការងារ ត្រូវមានបញ្ចូលផលប៉ះពាល់បរិស្ថាននិងសង្គមសំខាន់ៗដែលនឹងត្រូវធ្វើការអង្កេត និងត្រូវវាយតម្លៃដោយទីប្រឹក្សាពិគ្រោះយោបល់ផ្នែកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ សេចក្តីព្រាងនៃលក្ខខណ្ឌការងារនេះ ត្រូវទទួលបានការយល់ព្រមដោយរដ្ឋាភិបាល ដោយអមភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីការកំណត់វិសាលភាព ដែលគប្បីត្រូវតែបញ្ជាក់ច្បាស់អំពីកិច្ចខិតខំប្រឹងប្រែងចូលរួមជាសាធារណៈរហូតមកដល់ពេលនេះ និងផែនការស្តីពីការចូលរួមជាសាធារណៈសម្រាប់ពេលអនាគត។ បន្ទាប់មក ជំហាននៃការវាយតម្លៃលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវប្រមូលទិន្នន័យ ព្រមទាំងវិភាគលើបណ្តាផលប៉ះពាល់ដែលបាន

[43] Myanmar EIA Procedures 2015.

កំណត់ក្នុងលក្ខខណ្ឌការងារ និងពិចារណារកវិធានការកាត់បន្ថយផលបះពាល់ រួមទាំងរកជម្រើសផ្សេងៗសម្រាប់គម្រោង។

ជំហាននៃការកំណត់វិសាលភាពនៃគម្រោងដែលបានស្នើសុំ មានគោលបំណងដូចខាងក្រោម៖

- កំណត់តំបន់សិក្សា តំបន់ដែលមានឥទ្ធិពល ដែនពេលវេលា ដំណាក់កាលនៃគម្រោង និងភាគីពាក់ព័ន្ធដែលមានសក្តានុភាព
- ការចាប់ផ្តើមដំណើរការនៃការស្វែងយល់អំពីបទប្បញ្ញត្តិ និងបទដ្ឋានអនុវត្តនិងបរិបទនៃបទប្បញ្ញត្តិនិងបទដ្ឋាននោះសម្រាប់ការរៀបចំបង្កើតគម្រោង និងការបញ្ចប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- កំណត់អត្តសញ្ញាណបណ្តោះអាសន្នអំពីផលប៉ះពាល់បរិស្ថាន ដោយផ្តោតជាពិសេសទៅលើបញ្ហាបរិស្ថាន សង្គម និងសុខភាព ដែលចាំបាច់ត្រូវដោះស្រាយនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បញ្ជាក់អំពីជម្រៅនិងទំហំនៃការស៊ើបលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមទាំងទិន្នន័យនិងព័ត៌មានគោលអ្វីខ្លះដែលតម្រូវឲ្យមានការសិក្សានិងអង្កេតបន្ថែមអ្វីខ្លះទៀតដែលត្រូវអនុវត្ត និងតើត្រូវអនុវត្តការប្រមូលទិន្នន័យ ការសិក្សា និងការអង្កេតនោះដោយវិធីណា។
- ផ្តល់ឱកាសជូនអ្នកពិគ្រោះយោបល់ អាជ្ញាធរពាក់ព័ន្ធ ក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង និងភាគីដែលមានចំណាប់អារម្មណ៍និងរងផលប៉ះពាល់ ដើម្បីលើកឡើងអំពីទស្សនៈនិងកង្វល់របស់ពួកគាត់ទាក់ទងនឹងសំណើសុំ មុននឹងបន្តវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- អនុញ្ញាតឲ្យមានដំណើរការនៃការវាយតម្លៃល្អិតល្អន់និងមានប្រសិទ្ធភាព ជាដំណើរការដែលចំណេញពេលវេលា ធនធាន និងចំណាយ ព្រមទាំងបញ្ចៀសការពន្យារពេល និង
- កំណត់អត្តសញ្ញាណបណ្តាសហគមន៍ដែលអាចនឹងរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធផ្សេងៗទៀតដែលមានការចាប់អារម្មណ៍លើគម្រោង។[44]

ជាផ្នែកនៃការកំណត់វិសាលភាព អ្នកស្នើសុំគម្រោង ត្រូវធានាថា ដំណើរការនៃពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈ ដូចខាងក្រោមនេះ ត្រូវបានអនុវត្តៈ

- បង្ហាញព័ត៌មានអំពីគម្រោងដែលស្នើសុំនោះជូនសាធារណៈនិងសង្គមស៊ីវិល តាមរយៈការបិទប្រកាសព័ត៌មានអំពីគម្រោង ឬតាមវិបសាយរបស់អ្នកស្នើសុំគម្រោង និងតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក រួមទាំងការផ្សព្វផ្សាយតាមមធ្យោបាយដែលស្នើសុំគម្រោង

[44] Myanmar EIA Procedures.

ដាក់ផ្សាយឲ្យលេចធ្លោដែលគេមើលឃើញច្បាស់លើប៉ាណូផ្សព្វផ្សាយស្របច្បាប់ និង ប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្ម នៅទីតាំងរបស់គម្រោង ដែលសាធារណជនអាចមើល ឃើញ និង

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់បំពេញបន្ថែមតាមលក្ខខណ្ឌតម្រូវដែលណែនាំដោយ ក្រសួង ជាមួយសហគមន៍មូលដ្ឋាន ប្រជាជនដែលអាចនឹងរងផលប៉ះពាល់ដោយសារ គម្រោង អាជ្ញាធរមូលដ្ឋាន អង្គការដែលមានមូលដ្ឋាននៅសហគមន៍ និងសង្គមស៊ីវិល ព្រមទាំងពន្យល់ឲ្យបានសមស្របនិងទាន់ពេលវេលាតាមរយៈសន្និសីទកាសែត និង ការសំភាសន៍តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។[45]

**បញ្ជីផ្ទៀងផ្ទាត់អំពីប្រជាជនរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធ សម្រាប់ការកំណត់វិសាលភាព[46]**

1. **អាជ្ញាធរ**
   - អាជ្ញាធរថ្នាក់ជាតិ ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងអាជ្ញាធរមូលដ្ឋាន
   - អាជ្ញាធរទទួលខុសត្រូវចំពោះការគ្រប់គ្រងការបំពុលបរិស្ថាន រួមមាន ទឹក កាកសំណល់ សំឡេងរំខាន និងការបំពុលខ្យល់
   - អាជ្ញាធរទទួលខុសត្រូវលើការការពារធម្មជាតិ បេតិកភ័ណ្ឌវប្បធម៌ និងទេសភាព
   - អាជ្ញាធរទទួលបន្ទុកសុខភាពនិងសុវត្ថិភាព
   - អាជ្ញាធរគ្រប់គ្រងការប្រើប្រាស់ដីធ្លី ធ្វើផែនការកំណត់ទំហំ និងរៀបចំ តំបន់ និង
   - អាជ្ញាធរប្រទេសជិតខាង ដែលផលប៉ះពាល់ឆ្លងដែនអាចជាបញ្ហា
2. ភាគីពាក់ព័ន្ធផ្សេងៗទៀត
   - ក្រុមដែលមានចំណាប់អារម្មណ៍លើបរិស្ថាន សង្គម និងការអភិវឌ្ឍ ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ
   - នាយកដ្ឋានតាមវិស័យនៃរដ្ឋាភិបាល ដែលទទួលខុសត្រូវលើវិស័យ កសិកម្ម ថាមពលព្រៃឈើ នេសាទ។ល។ (ដែលផលប្រយោជន៍ របស់ខ្លួនអាចនឹងរងផលប៉ះពាល់)
   - ទីភ្នាក់ងារអន្តរជាតិ ដែលផលប្រយោជន៍របស់ខ្លួនអាចនឹងទទួលរង

[45] Myanmar EIA Procedures, Article 50.
[46] Laos EIA Guidelines, MONRE, 2012. Box 3.3, p.26.

ផលប៉ះពាល់។ ឧទាហរណ៍៖ គណៈកម្មាធិការទន្លេមេគង្គ

- សមាគមវិនិយោជក និងក្រុមហ៊ុនក្នុងស្រុក ដូចជា សភាពាណិជ្ជកម្ម សមាគមពាណិជ្ជកម្ម។ល។
- អង្គការសង្គមស៊ីវិល ដូចជា អង្គការស្ត្រី ក្រុមយុវជន និងក្រុមផ្សេងៗទៀត។ល។
- អង្គការនិយោជិត ដូចជា សហជីពកម្មករ
- បណ្ដាក្រុមដែលតំណាងអ្នកប្រើប្រាស់បរិស្ថាន, ឧទាហរណ៍៖ កសិករ អ្នកនេសាទ ស្ត្រីដែលប្រើប្រាស់ធនធាននៅមូលដ្ឋានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងសម្រាប់លក់ដូរ ប្រតិបត្តិករទេសចរណ៍
- វិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យនិងមជ្ឈមណ្ឌលជំនាញផ្សេងទៀត និង
- ប្រព័ន្ធផ្សព្វផ្សាយនៅមូលដ្ឋាន និងថ្នាក់ជាតិ

3. ប្រជាជនរងផលប៉ះពាល់ និងសហគមន៍នានា
   - ម្ចាស់ដី និងអ្នកស្រុក
   - ក្រុមជនជាតិនៅតំបន់ដែលរងផលប៉ះពាល់
   - តំណាងដែលជាប់ឆ្នោត និងបុគ្គលលេចធ្លោក្នុងសហគមន៍ ដូចជា ចៅអធិការវត្ត ឬគ្រូបង្រៀន
   - ក្រុមសហគមន៍មូលដ្ឋាន ក្រុមអ្នកស្រុក ជាដើម និង
   - ប្រជាជនទូទៅនៅមូលដ្ឋាន និងសាធារណជន

បញ្ហានិងផលប៉ះពាល់ចម្បងៗ ក៏ត្រូវចែកទៅជាដំណាក់កាលផ្សេងៗគ្នានៃគម្រោងដែរ។ ដំណាក់កាលទាំងនេះ អាចជា ដំណាក់កាលនៃការសាងសង់ ប្រតិបត្តិការ និងដំណាក់កាលបិទ ឬបញ្ចប់គម្រោង។ ជួនកាលដំណាក់កាលប្រតិបត្តិការ មានបញ្ចូលផែនការពង្រីក ឬពង្រឹងគម្រោង ដូចជាតំបន់សេដ្ឋកិច្ចពិសេស ឬការដ្ឋានអណ្ដូងរ៉ែជាដើម។ អ្នកពិគ្រោះយោបល់អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គប្បីត្រូវគូសបញ្ជាក់ឲ្យបានច្បាស់លាស់អំពីដំណាក់កាលផ្សេងៗគ្នានៃគម្រោង និងដំណាក់កាលសាងសង់ និងពេលវេលាប្រតិបត្តិការដែលបានស្នើសុំ។

បញ្ហាធំៗខ្លះ ដែលត្រូវពន្យល់ដោយទីប្រឹក្សាពិគ្រោះយោបល់អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងកិច្ចប្រជុំក្នុងអំឡុងពេលនៃជំហាននៃការកំណត់វិសាលភាព មាន៖

- កម្រិតនិងដែនកំណត់គម្រោង
- កង្វល់សំខាន់ៗ (ដោយផ្អែកលើគម្រោងស្រដៀងគ្នា)

- កំណត់/ពន្យល់អំពីជំហានក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ផលប៉ះពាល់ធំៗដែលអាចនឹងកើតឡើង
- កំណត់តំបន់ងាយមានប្រតិកម្ម/តំបន់សំខាន់ៗ
- កំណត់ជម្រើសផ្សេងៗ
- កំណត់បញ្ហាបរិស្ថាន/សង្គមសំខាន់ៗ
- កំណត់ប្រជាជនដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង
- កំណត់ភាគីពាក់ព័ន្ធផ្សេងៗទៀត
- ផែនការចូលរួមរបស់ភាគីពាក់ព័ន្ធ (ផែនការចូលរួមជាសាធារណៈ) និង
- សេចក្តីព្រាងលក្ខខណ្ឌការងារ

## ជំហានទី ៣៖ ការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

នៅពេលដែលរបាយការណ៍ស្តីពីការកំណត់វិសាលភាព និងលក្ខខណ្ឌការងារ ត្រូវបានអនុម័តដោយអាជ្ញាធរពាក់ព័ន្ធផ្នែកវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួចហើយ ឬត្រូវបានបង្ហើយចុងក្រោយដោយទីប្រឹក្សាពិគ្រោះយោបល់អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានហើយ ភារកិច្ចក្នុងការប្រមូលព័ត៌មាន និងរៀបចំរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចាប់ផ្តើម។ ជំហាននេះ អាចប្រើរយៈពេលចន្លោះពីបីខែ ទៅបីឆ្នាំ ដោយអាស្រ័យលើប្រភេទនៃគម្រោង និងបញ្ហាបរិស្ថាននិងសង្គមដែលត្រូវដោះស្រាយ។

ផ្អែកតាមទិន្នន័យដែលបានប្រមូល ទីប្រឹក្សាពិគ្រោះយោបល់អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងត្រូវរៀបចំរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ នៅពេលដែលរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានព្រាង ពេលនោះទីប្រឹក្សាពិគ្រោះយោបល់អំពីហេតុប៉ះពាល់បរិស្ថាន គប្បីត្រូវរៀបចំកិច្ចប្រជុំមួយ (ឬកិច្ចប្រជុំច្រើន) ដើម្បីធ្វើបទបង្ហាញជូនក្រសួង ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធនានា។ បន្ទាប់ពីបានពិចារណាដោយទីប្រឹក្សាពិគ្រោះយោបល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អំពីយោបល់និងបញ្ហាដែលលើកឡើងដោយប្រជាជនដែលរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធរួចហើយ របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគប្បីត្រូវពិនិត្យឡើងវិញ។ ពេលនោះ របាយការណ៍នេះត្រូវបានរៀបចំរួចរាល់ជាស្រេច ដែលត្រូវដាក់ជូនទៅអង្គភាពទទួលបន្ទុកវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីពិនិត្យនិងវាយតម្លៃ។

របាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គប្បីត្រូវបញ្ចូលផ្នែកសំខាន់ៗ ទៅតាមលក្ខខណ្ឌតម្រូវដោយច្បាប់ជាតិ។ គេអាចសង្ខេបផ្នែកសំខាន់ៗទាំងនេះដូចខាងក្រោម៖

- សេចក្តីសង្ខេប
- បរិបទគម្រោង
- គោលនយោបាយ ក្របខណ្ឌស្ថាប័ន និងច្បាប់ (រួមទាំង បទដ្ឋានគុណភាពបរិស្ថាន)
- សេចក្តីរៀបរាប់អំពីគម្រោង និងជម្រើសផ្សេងៗ
- សេចក្តីរៀបរាប់អំពីបរិស្ថាន (រួមទាំង ទិដ្ឋភាពសង្គម)
- ការវាយតម្លៃហេតុប៉ះពាល់ និងវិធានការកាត់បន្ថយ
- ការវាយតម្លៃហេតុប៉ះពាល់ថ្មីបន្ថែម
- ការវាយតម្លៃហានិភ័យ
- របាយការណ៍ស្តីពីការចូលរួមជាសាធារណៈនិងយោបល់ និង
- របាយការណ៍បច្ចេកទេស

ត្រូវតែរៀបចំ ផែនការគ្រប់គ្រងបរិស្ថាន សម្រាប់គម្រោង។ ផែនការគ្រប់គ្រងបរិស្ថាន គប្បីត្រូវតែបង្ហាញក្នុងឧបសម្ព័ន្ធដោយឡែកក្នុងរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ គេគប្បីត្រូវរៀបចំវាសម្រាប់ដំណាក់កាលនីមួយៗនៅក្នុងគម្រោងតាមតម្រូវការនូវឧបសម្ព័ន្ធ៖ មុនពេលសាងសង់ ពេលសាងសង់ ពេលប្រតិបត្តិការ ពេលបិទការសាងសង់ ពេលបញ្ឈប់ប្រើប្រាស់ការដ្ឋាន និងពេលស្តារនីតិសម្បទា។

## ជំហានទី ៩៖ ការពិនិត្យនិងការវាយតម្លៃលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការសម្រេចចិត្តថា តើត្រូវអនុម័ត ឬមិនអនុម័ត តម្រូវឲ្យមានការធ្វើវិសោធនកម្ម ឬបដិសេធទាំងស្រុងចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅទីបំផុតគឺ ស្ថិតលើរដ្ឋាភិបាលជាអ្នកសម្រេច។ ការសម្រេចនេះគប្បីត្រូវធ្វើឡើងដោយឯករាជ្យ តម្លាភាព និងផ្អែកលើមូលដ្ឋាននៃព័ត៌មាន និងភស្តុតាងវិទ្យាសាស្រ្តពេញលេញ។ ដូច្នេះហើយ ដំណើរការពិនិត្យច្បាស់លាស់ដែលផ្តល់ឱកាសឲ្យមានការចូលរួមជាសាធារណៈ ជាលក្ខខណ្ឌចាំបាច់។

សំខាន់បំផុតគឺ នៅក្នុងជំហាននៃការពិនិត្យនេះ ការទទួលខុសត្រូវក្នុងការរៀបចំឲ្យ មានការចូលរួមជាសាធារណៈ និងក្រុមគោលដៅដើម្បីឲ្យប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធផ្តល់គំនិត ប្តូរពីអ្នកស្នើសុំគម្រោង (និងទីប្រឹក្សាពិគ្រោះយោបល់អំពី

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) ទៅអង្គភាពរដ្ឋាភិបាលដែលទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេច (អាជ្ញាធរទទួលបន្ទុកលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)។

ការគិតពិចារណាយ៉ាងសំខាន់សម្រាប់អាជ្ញាធរវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងការពិនិត្យលើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការសម្រេចចិត្តថា តើគប្បីត្រូវអនុម័ត ឬមិនអនុម័ត ត្រូវមាន (ប៉ុន្តែមិនបានកំណត់) ចំពោះចំណុចដូចខាងក្រោមនេះ៖

- កម្រិតនៃការចូលរួមជាសាធារណៈដែលអនុវត្តពីដើមដល់ចប់នៃការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ទស្សនៈរបស់ប្រជាជនដែលរងផលប៉ះពល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធ ទៅលើសំណើសុំគម្រោង រួមមានផែនការគ្រប់គ្រងបរិស្ថាន និងសំណើផ្តល់សំណង
- តើវិធានការកាត់បន្ថយដែលស្នើឡើង និងផែនការគ្រប់គ្រងបរិស្ថាននឹងអាចទទួលបានការដោះស្រាយ/កាត់បន្ថយផលប៉ះពាល់បានសមរម្យឬទេ
- ភាពសមស្រប និងគុណតម្លៃនៃការប្តេជ្ញាចិត្តអនុវត្តគម្រោង (ឧ. បណ្តាផលចំណេញទាំងឡាយដែលស្នើឡើង ជាការបន្ថែមលើវិធានការផែនការគ្រប់គ្រងបរិស្ថាន)
- ភាពស៊ីចង្វាក់គ្នាជាមួយគោលបំណងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពទូលំទូលាយ
- ភាពស៊ីចង្វាក់គ្នាជាមួយលក្ខខណ្ឌការងារដែលបានអនុម័ត
- បណ្តាលក្ខខណ្ឌដែលគប្បីត្រូវភ្ជាប់ជាមួយនឹងសេចក្តីអនុម័ត (បន្ថែមលើការប្តេជ្ញាចិត្តនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន)

## ជំហាទី ៥៖ ការអនុម័តរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

រដ្ឋាភិបាលធ្វើការសម្រេចចុងក្រោយថា តើត្រូវអនុម័ត តម្រូវឱ្យធ្វើវិសោធនកម្ម ឬបដិសេធទាំងស្រុងចំពោះការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ការសម្រេចចិត្តនេះត្រូវតែធ្វើឡើងដោយឯករាជ្យ មានតម្លាភាព និងផ្អែកលើមូលដ្ឋាននៃព័ត៌មាននិងភស្តុតាងវិទ្យាសាស្ត្រពេញលេញ។

នៅពេលដែលរដ្ឋាភិបាលបានសម្រេចចិត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានហើយ ទាំងសាធារណជន ទាំងអ្នកស្នើសុំគម្រោងគប្បីត្រូវមានសិទ្ធិអនុវត្តដំណើរការបណ្តឹងឧទ្ធរណ៍។ ដើម្បីឲ្យដំណើរការបណ្តឹងឧទ្ធរណ៍នេះមានប្រសិទ្ធភាព និងគួរឲ្យជឿទុកចិត្ត គេត្រូវតែចេញផ្សាយជាសាធារណៈនូវការសម្រេចចិត្តនេះដោយមានហេតុផលសមរម្យ។

បន្ទាប់ពីបានអនុម័តរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួច គម្រោងត្រូវតែឲ្យមានការអនុម័ត និងការអនុញ្ញាតផ្សេងៗទៀត រួមទាំងការអនុម័តការវិនិយោគបរទេសផង។

## ជំហានទី ៦៖ ការពិនិត្យតាមដាន និងការប្រតិបត្តិ

ចំពោះគម្រោងដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទទួលបានការអនុម័ត និងអនុញ្ញាតឲ្យបន្តអនុវត្តហើយ ពេលនោះវាសំខាន់ណាស់ដែលត្រូវធ្វើយ៉ាងណា ទាំងចំពោះលទ្ធផលបរិស្ថាន និងសង្គម ទាំងចំពោះសុចរិតភាពនៃប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលការសាងសង់ ប្រតិបត្តិការ និងបញ្ឈប់គម្រោង គោរពតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម និងបណ្តាលក្ខខណ្ឌផ្សេងៗទៀតដែលបានអនុម័ត។

ដើម្បីធានាបាននូវការប្រតិបត្តិតាមនិងដើម្បីសម្រេចបាននូវការប្តេជ្ញាចិត្តតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចាំបាច់ត្រូវការមានប្រព័ន្ធពិនិត្យតាមដាន ដែលត្រូវមានការចូលរួមពិនិត្យតាមដានផ្ទៃក្នុងដោយនាយកគ្រប់គ្រងគម្រោងផង និងការពិនិត្យតាមដានគោលបំណងដោយបណ្តាភាគីពីខាងក្រៅផង។ ការពិនិត្យតាមដានពីខាងក្រៅនេះ អាចត្រូវបានអនុវត្តដោយភាគីណាមួយ (ឬដោយភាគីទាំងពីរ) គឺស្ថាប័នរដ្ឋាភិបាល ឬអង្គការសហគមន៍។

ការពិនិត្យតាមដានគឺជាសកម្មភាពធ្វើបន្តជាប្រចាំ។ ការពិនិត្យតាមដាន នឹងជួយបំពេញចិត្តសហគមន៍ ដោយគម្រោងត្រូវបានដំណើរការអនុលោមតាមលក្ខខណ្ឌនៃការអនុម័តនេះ។ វាក៏អាចជួយឲ្យមានការឆ្លើយតបទៅនឹងបញ្ហានានា និងកង្វល់ផ្សេងៗ មុនពេលផលវិបាកធ្ងន់ធ្ងរកើតឡើងដែរ។

វាក៏ចាំបាច់ដែលគេត្រូវការឱ្យមានយន្តការមួយដើម្បីធានាថា ការចូលរួមរបស់សហគមន៍ដែលគេបានប្តេជ្ញាចិត្ត នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន ត្រូវបានអនុវត្តក្នុងអំឡុងពេល អនុវត្តគម្រោង។ ប្រសិនបើ ការពិនិត្យតាមដានរកឃើញថា ពុំមានការប្រតិបត្តិតាម ឬមានការរំលោភបំពានលក្ខខណ្ឌនានា ដូច្នេះ យន្តការដើម្បីពង្រឹងការប្រតិបត្តិតាម ចាំបាច់ត្រូវតែមានជាស្រេច ហើយឲ្យអ្នកស្នើសុំគម្រោង ក៏ដូចជា ប្រជាជនដែលរងផលប៉ះពាល់ និងភាគីពាក់ព័ន្ធផ្សេងៗយល់។

### ការប្រតិបត្តិ ការពិនិត្យតាមដាន និងការពង្រឹងការអនុវត្ត

បើទោះបីជា ដំណើរការជាផ្លូវការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន អាចនឹងចប់ដោយទទួលបានការអនុម័តក៏ដោយ នោះគឺនៅពេលដែលប្រជាជនរងផលប៉ះពាល់ចាប់ផ្តើមដឹងថាមានផលប៉ះពាល់លើពួកគាត់។ នៅពេលដែលគម្រោងចាប់ផ្តើមដំណើរការ ពេលនោះ គប្បីជាឱកាសដើម្បីឲ្យប្រជាជនដែលរងផលប៉ះពាល់បរិស្ថាន និងភាគីពាក់ព័ន្ធដទៃទៀតធ្វើយ៉ាងណាធានាថា ការអនុវត្តគម្រោង បានបំពេញតាមគ្រប់លក្ខខណ្ឌដែលបានអនុម័ត ឬបានអនុញ្ញាត ហើយប្រតិបត្តិតាមកាតព្វកិច្ច និងការប្តេជ្ញាចិត្ត ដែលបានធ្វើក្នុងអំឡុងពេលនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

*ដំណាក់កាលមុនពេលសាងសង់*

អ្នកស្នើសុំគម្រោង និងអ្នកសាងសង់ គប្បីត្រូវរៀបចំកិច្ចប្រជុំជាមួយ ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងឲ្យបានមុនពេលនៃដំណាក់ចាប់ផ្តើមសាងសង់ និងក្នុងដំណាក់កាលសំណង់ចាប់ផ្តើមនៅការដ្ឋាន។ កិច្ចប្រជុំនេះ គប្បីត្រូវផ្តល់ឬពន្យល់លម្អិតអំពីកាលវិភាគនៃការសាងសង់ដែលបានស្នើឡើង។ ការពន្យល់លម្អិតនោះ គប្បីត្រូវលើកឡើងអំពីបណ្តាបញ្ហាដូចជា ចំនួនរថយន្តដឹកសម្ភារៈ និងយានយន្តសម្រាប់សាងសង់ ចំនួនការងារ ម៉ោងនៃការសាងសង់ រយៈពេលនៃការសាងសង់ និងគប្បីត្រូវពន្យល់អំពីផលប៉ះពាល់ដែលអាចនឹងកើតមានចំពោះប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង។

*ដំណាក់កាលសាងសង់*

អ្នកសាងសង់ ក៏គប្បីត្រូវលម្អិតអំពី ផែនការចូលរួមជាសាធារណៈដែលបានស្នើឡើង ក្នុងអំឡុងពេលនៃដំណាក់កាលសាងសង់ដែរ។ ត្រង់នេះគេគប្បីត្រូវផ្តល់សេចក្តីលម្អិតអំពីគណៈកម្មាធិការពិគ្រោះយោបល់សហគមន៍ និងយន្តការដោះស្រាយបណ្តឹងសាទុក្ខ។ ចំពោះគម្រោងធំៗដែលប្រើពេលច្រើនខែ (ឬឆ្នាំ) ហើយដែលបង្កឲ្យមានផលប៉ះពាល់ខ្លាំងក្នុងអំឡុងពេលនៃការសាងសង់ គណៈកម្មាធិការពិគ្រោះយោបល់សហគមន៍ គប្បីត្រូវប្រជុំ ជាទៀងទាត់។ ប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង គប្បីត្រូវមានតំណាងល្អនៅក្នុងគណៈកម្មាធិការពិគ្រោះយោបល់សហគមន៍ ហើយប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង គប្បីត្រូវទទួលបានការអនុញ្ញាតឱ្យជ្រើសរើសតំណាងរបស់ខ្លួន។ ដូចគ្នានេះដែរអង្គការសង្គមស៊ីវិល ក៏គប្បីត្រូវមានតំណាងនៅគណៈកម្មាធិការពិគ្រោះយោបល់សហគមន៍ដែរ។ អ្នកសាងសង់គម្រោង ក៏គប្បីត្រូវមានតំណាងដែរ។ បែបនេះគឺដើម្បីធ្វើឱ្យមានការដោះស្រាយបណ្តឹង និងកង្វល់ដែលលើកឡើងបានយ៉ាងលឿន។

គណៈកម្មាធិការពិគ្រោះយោបល់សហគមន៍ គប្បីត្រូវចូលរួម និងពង្រឹងសិទ្ធិអំណាចជូនប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងនិងភាគីពាក់ព័ន្ធ ដែលធ្វើបែបនេះ គឺដើម្បីឲ្យបញ្ហាត្រូវបានដោះស្រាយបានរហ័ស និងមានប្រសិទ្ធភាព។

*ដំណាក់កាលប្រតិបត្តិការ*

ដំណាក់កាលប្រតិបត្តិការនឹងត្រូវប្រើរយៈពេលរហូតមួយវដ្តជីវិតនៃគម្រោង និងត្រូវមានផែនការគ្រប់គ្រងបរិស្ថានផ្ទាល់ខ្លួន។ ផែនការគ្រប់គ្រងបរិស្ថាននេះ ត្រូវបញ្ចូលព័ត៌មានលម្អិតសម្រាប់ការគ្រប់គ្រងផលប៉ះពាល់បរិស្ថាននិងសង្គម ដែលបណ្តាលមកពីគម្រោង។

ក្នុងដំណាក់កាលប្រតិបត្តិការ គេតម្រូវឲ្យគម្រោងអនុវត្តការពិនិត្យតាមដាន ការបំពុលបរិស្ថានដែលកើតឡើងពីប្រតិបត្តិការរបស់គម្រោង។ ការបំពុលបរិស្ថាន អាចជាការបំពុលខ្យល់ ការបំពុលសំឡេង ការបំពុលចក្ខុ ឬការបំពុលទឹក។ គម្រោងក៏បង្កឲ្យមានកាកសំណល់ដែរ។ កាកសំណល់នេះ អាចជាកាកសំណល់អេតចាយ សំរាមទូទៅ ឬសំណល់ពុល ឬសំណល់បង្កគ្រោះថ្នាក់។

តារាងទី២៖ សេចក្តីសង្ខេបអំពីការចូលរួមជាសាធារណៈ នៅដំណាក់កាលសំខាន់ៗនៅក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

| | កម្ពុជា | ឡាវ | ភូមា | ថៃ | វៀតណាម |
|---|---|---|---|---|---|
| ការពិនិត្យ | មាន, កំពុងអនុវត្ត | អត់មាន | អត់មានលក្ខខណ្ឌតម្រូវឲ្យពិគ្រោះជាមួយ ជនរងផលប៉ះពាល់ | អត់មានលក្ខខណ្ឌតម្រូវសម្រាប់ ការចូលរួមជាសាធារណៈ។ | សិក្សាលទ្ធភាព ការវាយតម្លៃគប្បីត្រូវបញ្ចូលការពិគ្រោះយោបល់ខ្លះ។ |
| ការកំណត់វិសាល | មាន | មាន, ជនរងគ្រោះ | មាន, លក្ខខណ្ឌ | មាន | មិនទាន់ផ្ទៀងផ្ទាត់ |

| | | | | | |
|---|---|---|---|---|---|
| ភាព/លក្ខខណ្ឌការងារ | | គប្បីត្រូវចូលរួមក្នុងការកំណត់វិសាលភាព។ | តម្រូវច្បាស់សម្រាប់ការចូលរួមជាសាធារណៈ | | ជាមួយការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ មានលក្ខខណ្ឌតម្រូវសម្រាប់ ការចូលរួមជាសាធារណៈ។ |
| ការរៀបចំ | មាន | មាន, ត្រូវពិគ្រោះយោបល់ជាមួយជនរងផលប៉ះពាល់និងបណ្តាសហាគមន៍មូលដ្ឋាន | លក្ខខណ្ឌការងារត្រូវមានលម្អិតអំពីការចូលរួមជាសាធារណៈ, ផែនការត្រូវអនុម័តដោយក្រសួងអភិរក្សបរិស្ថាននិងរុក្ខាប្រមាញ់ | មាន, ពីរដងសម្រាប់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសុខភាព។ | មាន, គោលការណ៍ណែនាំមានកម្រិត។ |
| ការវាយតម្លៃ | មាន, ត្រូវមានលក្ខខណ្ឌតម្រូវឲ្យក្រសួង បរិស្ថានបើកកិច្ចប្រជុំជាសាធារណៈ | មាន, ក្រសួងធនធានធម្មជាតិនិងបរិស្ថាន ត្រូវតែពិគ្រោះយោបល់ | ក្រសួងអភិរក្សបរិស្ថាននិងរុក្ខាប្រមាញ់ ត្រូវតែបើកកិច្ចប្រជុំជាសាធារណៈ និងទទួលយក | ក្រុមជំនាញពិនិត្យឡើងវិញ អាចបើកកិច្ចប្រជាសាធារណៈ។ លក្ខខណ្ឌតម្រូវ | គ្មានលក្ខខណ្ឌច្បាស់លាស់សម្រាប់បើកកិច្ចប្រជុំដែលមានការចូលរួមជាសាធារ |

| | | | | | |
|---|---|---|---|---|---|
| | | នៅថ្នាក់ផ្សេងៗ ក្នុងអំឡុងពេលវាយតម្លៃ រួមទាំងផែនការគ្រប់គ្រងបរិស្ថាន | យោបល់នានា។ | សម្រាប់ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសុខភាព។ | ណ: អំឡុងពេលវាយតម្លៃ។ |
| ការអនុម័ត | មិនច្បាស់ថាតើ ការអនុម័តជាឯកសារសាធារណៈ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងវិញ្ញាបនបត្រប្រតិបត្តិបរិស្ថានមិនទាន់បង្ហាញជាសាធារណៈ។ | | វិញ្ញាបនបត្រប្រតិបត្តិបរិស្ថាន ត្រូវតែដាក់ផ្សព្វផ្សាយជាសាធារណៈ រួមទាំងផែនការគ្រប់គ្រងបរិស្ថាន។ | ការអនុម័តជាឯកសារសាធារណៈ និងគប្បីត្រូវបញ្ចូលផែនការគ្រប់គ្រងបរិស្ថាន។ | ត្រូវផ្សព្វផ្សាយរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ |
| ការពិនិត្យតាមដាន | មាន, ប្រជាជនរងផលប៉ះពាល់គប្បីត្រូវចូលរួម និងមាន GRM | មាន, សហាគមន៍ចូលរួមក្នុងផែនការគ្រប់គ្រងបរិស្ថាន។ | អត់មាន, លក្ខខណ្ឌតម្រូវសម្រាប់សហាគមន៍ចូលរួម។ | របាយការណ៍ត្រូវបានផ្តល់ជូនការិយាល័យផែនការនិងគោលនយោបាយបរិស្ថាននិង | |

| | | | | | |
|---|---|---|---|---|---|
| | | | | ធនធានធម្មជាតិ និង អាជ្ញាធរចេញការអនុញ្ញាត។ | |
| ការពង្រឹងការអនុវត្តដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយប្រជាជនរងផលប៉ះពាល់ | អត់មាន | អត់មាន | អត់មាន | ពលរដ្ឋអាចដាក់បណ្ដឹងទៅតុលាការ។ | អត់មាន |

លក្ខខណ្ឌតម្រូវឲ្យអនុវត្តតាមកាតព្វកិច្ចនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសុខភាពតាមរដ្ឋធម្មនុញ្ញនៃប្រទេសថៃ ព.ស. ២៥៥០ (គ.ស. ២០០៧), សាលក្រមរបស់តុលាការរដ្ឋបាលកណ្ដាល លេខ១៣៥២/២៥៥

- បណ្ដាភាគី៖ សមាគមប្រឆាំងការឡើងកម្ដៅសកលនិងដើមបណ្ដឹង៤២នាក់ និងក្រុមប្រឹក្សាភិបាល
- អង្គហេតុ៖ រដ្ឋធម្មនុញ្ញនៃប្រទេសថៃ ព.ស. ២៥៥០ (គ.ស. ២០០៧) បានចូលជាធរមាននៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧។ បញ្ហានៅត្រង់ថា តើចាប់តាំងពីពេលនោះចុងចោទមានកាតព្វកិច្ចត្រូវពិចារណាថា តើគម្រោង ឬសកម្មភាពទាំងនោះអាចបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានធម្មជាតិ ឬបរិស្ថានរបស់សហគមន៍ ឬសុខភាពរបស់ប្រជាជនដែរឬទេ? ប្រសិនបើ គម្រោងឬសកម្មភាពទាំងនោះស្ថិតក្នុងចំណាត់ថ្នាក់ក្រុមនេះ ដូច្នេះដើម្បីឱ្យស្របនឹងមាត្រា៦៧នៃរដ្ឋធម្មនុញ្ញនេះ ចុងចោទត្រូវការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសុខភាព, រៀបចំសវនាការសាធារណៈ និងផ្ដល់ឱកាសឱ្យអ្នកជំនាញផ្នែកបរិស្ថាននិងសុខភាព ផ្ដល់យោបល់។ តាមការអះអាងថា ចុងចោទបានធ្វើមិនដឹងមិនឮចំពោះលក្ខខណ្ឌតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសុខភាព និងបានផ្ដល់ការអនុញ្ញាតយ៉ាងហោចណាស់ ៧៦គម្រោង ឬសកម្មភាព ដែលអាចនឹងបណ្ដាលឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សហគមន៍ដោយប្រើនីតិវិធីដូចគ្នានឹងនីតិវិធីដែលចុងចោទបានប្រើ មុនពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន។
- បញ្ហាផ្នែកច្បាប់៖ តើការផ្ដល់ការអនុញ្ញាត៧៦គម្រោង ឬសកម្មភាពទៅឱ្យម្ចាស់អាជីវកម្មក្រោយរដ្ឋធម្មនុញ្ញឆ្នាំ២០០៧របស់ប្រទេសថៃចូលជាធរមាននោះ ផ្ទុយនឹងលក្ខខណ្ឌតម្រូវនៃមាត្រា ៦៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ២០០៧នេះដែរឬទេ?
- សាលក្រម៖ តុលាការរដ្ឋបាលកណ្ដាលបានចេញសាលក្រមដោយយោងតាមរដ្ឋធម្មនុញ្ញឆ្នាំ២០០៧ ដែលកាតព្វកិច្ចរបស់ផ្នែកនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការត្រូវតែគោរពតាមនីតិរដ្ឋ។ លើសពីនេះទៅទៀត មាត្រា២៧នៃរដ្ឋធម្មនុញ្ញ ឆ្នាំ២០០៧ បានបញ្ជាក់ថា សិទ្ធិនិងសេរីភាពដែលបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដែលទទួលស្គាល់ដោយតុលាការធម្មនុញ្ញ ត្រូវតែទទួលបានការការពារ និងត្រូវចងកាតព្វកិច្ចដោយផ្ទាល់ទៅនឹងអង្គនីតិបញ្ញត្តិ នីតិប្រតិបត្តិ (គណៈរដ្ឋមន្ត្រី) តុលាការ អង្គធម្មនុញ្ញ និងការិយាល័យរដ្ឋបាលក្នុងការតាក់តែង អនុវត្ត និងបកស្រាយច្បាប់។ តុលាការរដ្ឋបាល មានកាតព្វកិច្ចត្រូវការពារសិទ្ធិ សេរីភាពរបស់ប្រជាជន និងផលប្រយោជន៍សាធារណៈ ដោយបញ្ឈប់ ការបង្កផលប៉ះពាល់ដល់សហគមន៍ គុណភាពនៃបរិស្ថាន និងសុខភាពរបស់ប្រជាជន ដែលបានកើតឡើងនៅក្រុង ម៉ាថាភុត (Mah Tha Phut) និងតំបន់ជុំវិញ ដោយចាប់បង្ខំបណ្ដាភាគីពាក់ព័ន្ធឲ្យប្រតិបត្តិតាមនីតិវិធី ដូចមានចែងក្នុងមាត្រា៦៧ កថាខ័ណ្ឌ២ នៃរដ្ឋធម្មនុញ្ញ។
- តុលាការរដ្ឋបាលកណ្ដាល បានដកហូតបណ្ដាលិខិតអនុញ្ញាត ដែលមានបញ្ចូលទៅក្នុងបញ្ជីនៃគម្រោង ឬសកម្មភាពដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរ ដោយក្រឹត្យរបស់ក្រសួងធនធានធម្មជាតិនិងបរិស្ថាន នៅឆ្នាំ២០១០ ដែលលិខិតអនុញ្ញាតនោះត្រូវបានផ្ដល់ទៅឱ្យម្ចាស់អាជីវកម្ម ក្រោយរដ្ឋធម្មនុញ្ញ ឆ្នាំ២០០៧ ចូលជាធរមាន ហើយមិនបានអនុវត្តទៅតាមនីតិវិធីទាំងអស់ដែលមានចែងនៅក្នុងមាត្រា៦៧ កថាខ័ណ្ឌ២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ២០០៧។

## ព្រះរាជាណាចក្រកម្ពុជា

## សេចក្តីផ្តើម

លក្ខខណ្ឌតម្រូវផ្លូវច្បាប់សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅប្រទេសកម្ពុជាត្រូវបាន កំណត់នៅក្នុង ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ (ជំពូកទី ៣) និងអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

មាត្រា ១៖

ច្បាប់នេះមានគោលដៅ៖

- ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋ ដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល
- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសម្រេចរបស់រដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង
- ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាពនិងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្តនិងផ្តល់លទ្ធភាពឲ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងដំណើរការរៀបចំតាក់តែងក្រមបរិស្ថានថ្មីមួយ។ សេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលត្រូវបានបញ្ចប់នៅឆ្នាំ២០១៥ នោះ ឥឡូវនេះនឹងក្លាយជាផ្នែកនៃក្រមបរិស្ថានថ្មី។ គេរំពឹងថា ក្រមបរិស្ថានថ្មីនេះ នឹងត្រូវដាក់ជូនរដ្ឋសភានៅដើមឆ្នាំ២០១៧។

ក្រមបរិស្ថានថ្មី ក៏ដូចជា ច្បាប់ទាំងអស់នៃប្រទេសកម្ពុជាដែរ ត្រូវតែគោរពតាមរដ្ឋធម្មនុញ្ញ ដែលមានលក្ខខណ្ឌតម្រូវឲ្យការពារបរិស្ថាន។

| |
|---|
| **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** |
| មាត្រា ៥៩៖ |
| រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្មនិងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលិតព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ និងធនធានជលផល។ |

ទន្ទឹមនឹងនេះក៏មាន អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩ ប្រកាស និង សេចក្តីសម្រេចមួយចំនួនទៀតទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការ ធ្វើរបាយការណ៍ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដំបូងនិងពេញលេញ (លេខ. ៣៧៦ ប្រក.បស្ថ ២០០៩)
- ប្រកាសស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សា សម្រាប់ការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (លេខ. ២១៥ ប្រក. ក្រសួងបរិស្ថាន ឆ្នាំ ២០១៤)
- ប្រកាសស្តីពីប្រតិភូកម្មអំណាចក្នុងការធ្វើសេចក្តីសម្រេចក្នុងនាមក្រសួងចំពោះកំរោងវិនិយោគជូន មន្ទីរបរិស្ថានខេត្ត ក្រុង (លេខ ២៣០ ប្រក. បស្ថ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០៥)
- ប្រកាសអន្តរក្រសួងស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោង អាជីវកម្មរ៉ែ សំណង់គ្រប់ប្រភេទឬ រ៉ែផ្សេងទៀតដែលមាន លក្ខណៈជាសិប្បកម្ម ឬអាជីវកម្មខ្នាតតូច (លេខ១៩១ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦)
- សេចក្តីសម្រេចស្តីពីសមាសភាពនិងភារកិច្ចរបស់ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥)

តាមក្របខណ្ឌបច្ចុប្បន្ន គម្រោងស្នើសុំវិនិយោគ និងគម្រោង ស្នើសុំដោយរដ្ឋត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដំបូង របាយការណ៍ស្តីពីការសិក្សាបុរេលទ្ធភាព ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាត្រា៦នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (មាត្រា៧)។ ត្រូវដាក់ជូនមួយច្បាប់ទៅក្រសួង ឬស្ថានប័នអនុម័តគម្រោង និងក្រសួងបរិស្ថាន។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

មាត្រា៦៖

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពឯកជនឬសាធារណៈ ហើយត្រូវបានពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។ ការវាយតម្លៃនេះ ក៏ត្រូវបានអនុវត្តដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។

បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

ប្រភេទនិងទំហំគម្រោង និងសកម្មភាពដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ទាំងឯកជននិងសាធារណៈ ដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន។

មាត្រា៧៖

ចំពោះរាល់ពាក្យសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើង ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យនិងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬក៏ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

ច្បាប់ជាក់លាក់វិស័យផ្សេងៗទៀត ដូចជា ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ យោងទៅលើតម្រូវការក្នុងការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម។

ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២
មាត្រា៨៖
ក្នុងការអនុវត្តច្បាប់នេះ រាល់ការសម្រេចរបស់រដ្ឋាភិបាលដែលមានសក្តានុភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរលើពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។

សកម្មភាពចម្បងៗ ពាក់ព័ន្ធនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែលបណ្តាលឲ្យមានផលប៉ះពាល់អាក្រក់ដល់សង្គមនិងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងផលប៉ះសង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។

រាល់ការសម្រេចចុងក្រោយលើ រាល់សកម្មភាពសម្បងៗពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រដ្ឋាភិបាលត្រូវពិចារណាអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម។ ការសម្រេចចុងក្រោយណាមួយ ក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ។

អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានរៀបចំដោយក្រសួងបរិស្ថាន និងបានប្រកាសឲ្យប្រើប្រាស់ដោយនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា នៅឆ្នាំ១៩៩៩។ គោលបំណងនៃអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវបានកំណត់ក្នុងមាត្រា១។

មាត្រា ១៖
អនុក្រឹត្យនេះមានគោលបំណង៖

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លើរាល់គម្រោងនិងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថាន មុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច
- កំណត់ប្រភេទនិងទំហំគម្រោង សកម្មភាពដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បំផុសឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងទទួលយកមតិ យោបល់ មកធ្វើការពិចារណា ក្នុងដំណើរការអនុម័តគម្រោង។

អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តចំពោះរាល់គម្រោង ឬសកម្មភាពទាំងឯកជន និងសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន កំណត់នូវប្រភេទគម្រោងជាក់លាក់ដែលមាននៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ជារួមគឺមានបួនផ្នែកធំៗគឺ ផ្នែកឧស្សាហកម្ម កសិកម្ម ទេសចរណ៍ និងផ្នែកហេដ្ឋារចនាសម្ព័ន្ធ។ នៅក្នុងផ្នែកនីមួយៗ មានបញ្ជីប្រភេទគម្រោងជាក់លាក់មួយចំនួន។ បញ្ជីឈ្មោះប្រភេទគម្រោងនេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ យោងតាមបញ្ជីនេះ ដំណើរការពិនិត្យនាពេលបច្ចុប្បន្ន នៅកម្ពុជាគឺធ្វើដោយផ្អែកលើគម្រោងជាមូលដ្ឋាន ជាជាង យោងទៅលើផលប៉ះពាល់បរិស្ថាន។

ភាពខុសគ្នាយ៉ាងខ្លាំងក្នុងវិធីសាស្ត្ររបស់កម្ពុជា ក្នុងការពិនិត្យលើដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (បើប្រៀបធៀបបណ្តាប្រទេសផ្សេងៗនៅតំបន់ទន្លេមេគង្គ) គឺថារាល់គម្រោងដែលមាននៅក្នុងបញ្ជីសម្រាប់ពិនិត្យដូចមាននៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យ ត្រូវឆ្លងកាត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដើម្បីកំណត់ថាតើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាលក្ខខណ្ឌតម្រូវដែរឬទេ។ មាត្រា៦ ចែងថា "ម្ចាស់គម្រោងត្រូវធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ... ទៅតាមឧបសម្ព័ន្ធនេះ"។

បន្ទាប់មកម្ចាស់គម្រោង ត្រូវដាក់ដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង និងរបាយការណ៍សិក្សាបុរេលទ្ធភាព ទៅក្រសួងបរិស្ថាន (មាត្រា៧) ឬដាក់ជូនទៅមន្ទីរវាយតម្លៃហេតុប៉ះពាល់បរិស្ថានខេត្ត ប្រសិនបើគម្រោងនោះត្រូវកំណត់ឲ្យធ្វើការសម្រេចនៅថ្នាក់រាជធានី-ខេត្ត។ ប្រកាសស្តីពីប្រតិភូកម្មអំណាចក្នុងការធ្វើសេចក្តីសម្រេចក្នុង

នាមក្រសួងចំពោះកំរោងវិនិយោគជូន ទៅមន្ទីរបរិស្ថានខេត្ត ក្រុងស្តីពីបញ្ហាដែលទាក់ទងទៅនឹងគម្រោងវិនិយោគ ក្នុងនាមក្រសួងបរិស្ថាន លេខ២៣០ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥ (មាត្រា២, ៣, ៤, ៥, ៦, ៨) ចែងថា ចំពោះគម្រោងដែលប្រើទុនវិនិយោគតិចជាង២លានដុល្លារ ការទទួលខុសត្រូវក្នុងការពិនិត្យនិងតាមដានត្រូវផ្ទេរទៅមន្ទីរបរិស្ថាន។ ទោះជាយ៉ាងណា នៅថ្នាក់មន្ទីរពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយប្រសិទ្ធភាពឡើយ។

អនុក្រឹត្យលេខ១៤៦ស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥ ក៏តម្រូវឱ្យវាយតម្លៃផ្នែកបរិស្ថានពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ចដែរ។ មាត្រា៧ ចំណុច៥ នៃអនុក្រឹត្យលេខ១៤៦បញ្ជាក់ថា "ប្រសិនបើការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមបង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬកម្រិតខ្ពស់ ត្រូវរៀបចំឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ"។ នៅឆ្នាំ២០១៤ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានបានចេញប្រកាសអន្តរក្រសួងស្តីពីការពង្រឹងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច (លេខ២០៦ ក្រ.ប, ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤)។ ប្រកាសនេះជាមធ្យោបាយពង្រឹងកិច្ចការពារព្រៃឈើ និងតំបន់ការពារ។ វាក៏តម្រូវឲ្យបណ្តាក្រុមហ៊ុនស្នើសុំការអនុញ្ញាតក្នុងការកាប់ជម្រះអនុផលព្រៃឈើចេញពីដីដែលជាប្រធានបទនៃសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់នោះដែរ។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ក៏មានបញ្ចូលនូវបទប្បញ្ញត្តិទូទៅដើម្បីឲ្យមានការចូលរួមជាសាធារណៈនិងទទួលបានព័ត៌មានដែរ។ មាត្រា១៦ នៃច្បាប់នេះ ចែងថា ក្រសួងបរិស្ថាន ត្រូវបំផុសឲ្យមានការចូលរួមពីសាធារណជនក្នុង "កិច្ចការពារ និងការគ្រប់គ្រងធនធានធម្មជាតិ"។ មាត្រា១៧ ក៏តម្រូវឱ្យក្រសួងបរិស្ថាន រៀបចំបង្កើតអនុក្រឹត្យស្តីពីការចូលរួមជាសាធារណៈនិងសិទ្ធិទទួលបានព័ត៌មានដែរ។ ក្រសួងបរិស្ថាន បានរៀបចំបង្កើតប្រកាសស្តីពីការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលមានបញ្ចូលលក្ខខណ្ឌតម្រូវកាន់តែលម្អិតបន្ថែមទៀត អំពីការចូលរួមជាសាធារណៈ។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

*ជំពូក ៧៖ ការចូលរួមរបស់សាធារណជននិងការស្រង់យកព័ត៌មាន*

មាត្រា ១៦៖
ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណើរបស់សាធារណជននូវព័ត៌មាន អំពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

មាត្រា១៧៖
បែបបទនៃការចូលរួមរបស់សាធារណជន និងស្រង់យកព័ត៌មានក្នុងកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងបរិស្ថាន។

មាត្រា ១៨៖
ព័ត៌មានដែលទាក់ទងទៅនឹងកិច្ចការពារបរិស្ថាន ឬការគ្រប់គ្រងធនធានធម្មជាតិត្រូវផ្សព្វផ្សាយជូនគ្នាទៅវិញទៅមក រវាងក្រសួងបរិស្ថាននិងក្រសួងនានា។

ពាក់ព័ន្ធនឹងការចូលរួមជាសាធារណៈ អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន "លើកទឹកចិត្ត" ឲ្យមានការចូលរួមពីសាធារណជន ប៉ុន្តែគ្មានចែងលក្ខខណ្ឌតម្រូវច្បាស់លាស់ទេ។ លើសពីនេះទៀត អនុក្រឹត្យនេះគ្មានលក្ខខណ្ឌតម្រូវឲ្យមានការពិចារណារកជម្រើសផ្សេងៗ ឬការបង្ហាញព័ត៌មានទេ។ ចំណុចនេះ ត្រូវបានគូសបញ្ជាក់បន្ថែមនៅក្នុងប្រកាសពាក់ព័ន្ធ។ ប្រកាសជាធរមាន អនុញ្ញាតឲ្យអង្គការមិនមែនរដ្ឋាភិបាលចូលរួមជាតំណាងពេលប្រជុំពហុភាគីពាក់ព័ន្ធដើម្បីពិនិត្យឡើងវិញលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការវាយតម្លៃបរិស្ថានដំបូង ដែលដាក់ជូនទៅក្រសួង ឬមន្ទីរបរិស្ថាន។

ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ មាត្រា២០ ផ្តល់សិទ្ធិឱ្យរដ្ឋមន្ត្រីផ្សព្វផ្សាយព័ត៌មានអំពីបញ្ហាបរិស្ថាន និងសង្គមទៅសាធារណជន។

ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០៤ មាត្រា៤ តម្រូវឱ្យផ្សព្វផ្សាយព័ត៌មានលម្អិតអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីទទួលមតិពីសាធារណជន។ តម្រូវឱ្យមានការចូលរួមជាសាធារណៈក្នុង

"ការសម្រេចណាមួយរបស់រដ្ឋាភិបាល" ដែលអាចប៉ះពាល់ដល់ព្រៃឈើ។

> មាត្រា ៩៖
> ក្នុងអនុវត្តច្បាប់នេះ រាល់ការសម្រេចរបស់រដ្ឋាភិបាលដែលមានសក្តានុភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅ លើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការចូលរួមជាសាធារណៈ។
>
> សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែលអាចបណ្តាលឲ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។
>
> រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ រាជរដ្ឋាភិបាលត្រូវពិចារណាលើ អនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិ ស្ថាន និងផលប៉ះពាល់សង្គម។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាល អាចធ្វើការជូនដំណឹងជាសាធារណៈ។

ច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០៩នេះ ក៏តម្រូវឲ្យមានការចូលរួមជាសាធារណៈដែរ។

> មាត្រា ៦៖
> រដ្ឋបាលព្រៃឈើត្រូវបំពេញភារកិច្ចរបស់ខ្លួនស្របតាមគោលការណ៍តម្លាភាព ដោយធានានូវសិទ្ធិរបស់សាធារណជនដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត លើការគ្រប់គ្រងការប្រើប្រាស់ប្រកបដោយនិរន្តរភាព និងការអភិរក្សព្រៃឈើ។

ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដំបូងនិងពេញលេញ (លេខ ៣៧៦ ប្រ.ក ប.ស្ក. ឆ្នាំ២០០៩) បញ្ជាក់ថា៖

ប្រការ ១១៖
ពិនិត្យនិងផ្តល់យោបល់នៅក្នុងកិច្ចប្រជុំពហុភាគីពាក់ព័ន្ធ ដែលមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន ដោយមានតំណាងពីក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាននិងអង្គការមិនមែនរដ្ឋាភិបាល និងភាគីផ្សេងៗទៀតដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគ (ក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ)។

ប្រកាសដដែលនេះបញ្ជាក់ថា៖

ប្រការ ១២៖
ពិនិត្យនិងផ្តល់យោបល់នៅក្នុងកិច្ចប្រជុំពហុភាគី ដែលមានប្រធានមន្ទីរបរិស្ថានជាប្រធាន ដោយមានតំណាងពីមន្ទីរ/អង្គការពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗទៀតដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគ (ក្នុងរយៈពេល៥ថ្ងៃនៃថ្ងៃធ្វើការ)

បច្ចុប្បន្ន ក្រសួងបរិស្ថានកំពុងរៀបចំតាក់តែងប្រកាសមួយស្តីពីការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ សេចក្តីព្រាងប្រកាសនេះ និងគោលការណ៍ណែនាំដែលភ្ជាប់មកជាមួយត្រូវបានដាក់ឲ្យសាធារណជនចូលរួមផ្តល់មតិនៅខែកក្កដាឆ្នាំ២០១៦។ ប្រកាសនិងគោលការណ៍ណែនាំនេះនឹងត្រូវសម្រេចចុងក្រោយនៅចុងឆ្នាំ២០១៦។

## ការគិតថ្លៃសេវា

ប្រកាសរួម ស្តីពីការផ្តល់ សេវាសាធារណៈរបស់ក្រសួងបរិស្ថាន លេខ៩៩៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ។ ប្រកាសរួមនេះ មានចែងអំពីការគិតថ្លៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពយោងតាមប្រភេទនៃសេវាសាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធ។

## នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

កម្ពុជាសម្រេចអនុវត្តជំហានដូចខាងក្រោមនេះ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង/និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ

1. ការជ្រើសរើសគម្រោង

2. ការកំណត់វិសាលភាពគម្រោង
3. ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន
4. ការពិនិត្យ និងវាយតម្លៃរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
5. ការអនុម័តឬការបដិសេធរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
6. ការសាងសង់ ប្រតិបត្តិការ និង
7. ការពិនិត្យតាមដានគម្រោង ការប្រតិបត្តិ និងការពង្រឹងការអនុវត្តច្បាប់។

តាមអនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ម្ចាស់គម្រោងត្រូវដាក់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ទៅក្រសួងបរិស្ថានដើម្បីសុំការពិនិត្យនិងពិចារណា។ ក្រសួងបរិស្ថានត្រូវកំណត់ថា តើគម្រោងនេះត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរឬទេ ឬថាតើ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនោះគ្រប់គ្រាន់ហើយឬនៅ។ ក្រសួងបរិស្ថានក៏ត្រូវកំណត់ដែរថា តើគម្រោងមួយត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងរយៈពេល៣០ថ្ងៃដែរឬទេ។

ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់អនុសាសន៍ជូនទៅអង្គការមានសមត្ថកិច្ចអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ប្រសិនបើ ក្រសួងបរិស្ថានមិនឆ្លើយតបចំពោះលទ្ធផលរកឃើញនិ ងអនុសាសន៍ក្នុងរយៈពេល៣០ថ្ងៃទេ ពេលនោះ ក្រសួង/ស្ថាប័នអនុម័តគម្រោងត្រូវសន្មតថា របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលគេបានពិនិត្យហើយនោះ បានអនុវត្តត្រឹមត្រូវទៅតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងអនុក្រឹត្យនេះ។

> មាត្រា ១៨៖
> ក្នុងករណី ក្រសួងបរិស្ថានខកខានមិនបានបញ្ជូនយោបល់និងសំណើដូចមានចែងក្នុងមាត្រា ១៥ និង១៧ ស្ថាប័នអនុម័តគម្រោងអាចកំណត់ថា គម្រោងនោះត្រូវបានបំពេញតាមតម្រូវការនៃអនុក្រឹត្យ។

អនុក្រឹត្យស្តីពីដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានកំណត់រយៈពេល៣០ថ្ងៃ សម្រាប់ការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឆ្លើយតប អ្នកស្នើសុំ

គម្រោង និងក្រសួងពាក់ព័ន្ធ។ ម្ចាស់គម្រោងត្រូវតែទទួលស្គាល់ថា លទ្ធផលរកឃើញនិងអនុសាសន៍លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលត្រូវបានអនុម័តដោយក្រសួងបរិស្ថាន មុនពេលម្ចាស់គម្រោងទាំងនោះត្រូវបន្តការអនុវត្តគម្រោង។
ក្រសួងបរិស្ថានបានរៀបចំតាក់តែងប្រកាសដើម្បីជួយដល់ការរៀបចំ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងដើម្បីបង្កើតដំណើរការសម្រាប់ការពិនិត្យឡើងវិញ និងផ្តល់មតិលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

## ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន/ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩ មានចែងអំពីគោលការណ៍ណែនាំទូទៅអំពីរបៀបរៀបចំនិងធ្វើរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ (មាត្រា ១)។ ប្រកាសនេះក៏មានបញ្ចូលគោលការណ៍ណែនាំទូទៅអំពីខ្លឹមសារនៃរបាយការណ៍ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការកំណត់វិសាលភាពនៃផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ និងវិធានកាត់បន្ថយផលប៉ះពាល់ដែរ។ ប្រកាសនេះ ក៏មានចែងនិយមន័យមួយចំនួនសម្រាប់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរ។

តាមប្រកាសឆ្នាំ២០០៥ ស្តីពីប្រតិភូកម្មអំណាច ការអនុម័តគម្រោងដែលមានទុនវិនិយោគតិចជាង២លានដុល្លារ ត្រូវបានផ្ទេរសិទ្ធិទៅមន្ទីរបរិស្ថាន។ ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចគ្នា ទោះបីជាគម្រោងនោះត្រូវវាយតម្លៃនៅថ្នាក់ជាតិឬនៅថ្នាក់ក្រោមជាតិក៏ដោយ។

លក្ខណៈពិសេសយ៉ាងសំខាន់មួយក្នុងចំណោមលក្ខណៈសំខាន់ៗ សម្រាប់ប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជាគឺ ការពិនិត្យបញ្ជីដែលកំណត់គម្រោងទាំងអស់ដែលត្រូវអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង។ នៅពេលដែលអ្នកស្នើសុំគម្រោង បានអនុវត្តដំណើរការពិនិត្យរួចហើយ ក្រសួងត្រូវកំណត់ថា តើត្រូវអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬថាតើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនោះគ្រប់គ្រាន់ហើយ។

នាយកដ្ឋានបរិស្ថានចំណុះក្រសួងបរិស្ថាន (ឬមន្ទីរពាក់ព័ន្ធ) ក៏ត្រូវមានកាតព្វកិច្ចចុះទៅពិនិត្យដល់ទីតាំងដែរ ដែលមានឱកាសដើម្បីទទួលបាននូវមតិរបស់សាធារណជន ក្នុងដំណើរការនៃការពិនិត្យ។

> ប្រការ ៧៖
> នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវពិនិត្យនិងផ្តល់យោបល់លើទីតាំងគម្រោង ដូចមានចែងក្នុងប្រការ២ និងប្រការ៣ខាងលើ ដើម្បីកំណត់ឲ្យបានច្បាស់លាស់ថា គម្រោងនេះគួរតម្រូវឲ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។
>
> ប្រការ ៩៖
> នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយអនុវត្តទៅតាមគោលការណ៍ណែនាំទូទៅនេះ។

## ការវាយតម្លៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន/ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង

តាមប្រកាសឆ្នាំ២០០៩នេះ នៅពេលដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវបានដាក់ជូនទៅក្រសួងហើយ ត្រូវតែមានការវាយតម្លៃក្នុងរយៈពេល៣០ថ្ងៃ។ នៅក្នុងរយៈពេលកំណត់នេះ មានលក្ខខណ្ឌតម្រូវឲ្យមានដំណើរទស្សនកិច្ចទៅទីតាំង និងមានការពិគ្រោះយោបល់ជាមួយប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

ក្រសួងបរិស្ថានបានបង្កើតដំណើរការសម្រាប់ពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង/ពេញលេញ។ មានដំណាក់កាលនៃដំណើរការពិនិត្យនេះ ដែលដំបូងគឺត្រូវអនុវត្តដោយក្រុមការងារសម្របសម្រួលដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលក្រសួងបរិស្ថានផ្តល់នូវការវាយតម្លៃដំបូង បន្ទាប់មកមានការពិនិត្យដោយអន្តរក្រសួង។ សេចក្តីសម្រេចអំពីសមាសភាព និងភារកិច្ចពិនិត្យនៃក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លេខ០១៣/២០១៥ សម្រាប់បង្កើត ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះ

ពាល់បរិស្ថាន ដើម្បីពិនិត្យ ពិចារណាលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង/ពេញលេញ សម្រាប់គម្រោងវិនិយោគ។

ប្រការ ២៖
ក្រុមការងារសម្របសម្រួលវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចលើបទបញ្ជាផ្ទៃក្នុងរបស់ក្រុមការងារសម្របសម្រួលវាយតម្លៃហេតុប៉ះ ពាល់បរិស្ថាន
- ពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោងដែលបានស្នើសុំ និងសកម្មភាពអភិវឌ្ឍន៍សាធារណៈ ឬឯកជនដែលមានស្រាប់ និងកំពុងដំណើរការដោយអាស្រ័យលើលទ្ធផលពីការពិនិត្យនិងយោបល់ដំបូងពី នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- សម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង
- រាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងបរិស្ថានអំពីលទ្ធផលនៃកិច្ចប្រជុំផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម។

ប្រការ ៣៖
នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាលេខាធិការដ្ឋាននៃក្រុមការងារសម្របសម្រួលវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមការងារសម្របសម្រួលវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- សហការសម្របសម្រួល និងផ្តល់កិច្ចការពារផ្នែករដ្ឋបាល និងបច្ចេកទេសដោយអនុលោមតាមបទបញ្ជាជាធរមាន
- រៀបចំកំណត់ហេតុប្រជុំរបស់ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំង ជំនាញផ្ទៃក្នុងក្រសួង ទាំងជំនាញអន្តរក្រសួង
- រៀបចំរបាយការណ៍ប្រជុំក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទាំង ជំនាញផ្ទៃក្នុងក្រសួង និងជំនាញអន្តរក្រសួង ជូនរដ្ឋមន្ត្រីក្រសួងបរិស្ថានដើម្បីពិនិត្យនិង សម្រេចដោយអនុលោមតាមនីតិវិធីរដ្ឋបាល
- រៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំអន្តរក្រសួង ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ដើម្បីពិនិត្យនិងសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលកិច្ចប្រជុំនេះត្រូវមានសមាសភាពចូលរួមដោយ ប្រធាន និងអនុប្រធាន ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មន្ត្រីជំនាញ និងថ្នាក់ដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាល/អភិបាលរងរាជធានី-ខេត្ត និងមន្ទីរបរិស្ថានរាជធានី-ខេត្ត

- រៀបចំលិខិតផ្តល់យោបល់អំពីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីឲ្យម្ចាស់គម្រោងកែតម្រូវ។

ក្រុមការងារបច្ចេកទេសទទួលខុសត្រូវក្នុងការវាយតម្លៃនិងពិចារណាលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង/ពេញលេញ។ ក្រុមការងារសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចស្នើសុំ មតិជាលាយលក្ខណ៍អក្សរអំពីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ពីក្រុមអ្នកជំនាញផ្សេងៗទៀត មានដូចជា អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សាស្ត្រាចារ្យពីសកលវិទ្យាល័យនានា ឬវិទ្យាស្ថានស្រាវជ្រាវ (មាត្រា ៩)។

បន្ទាប់ពីការពិនិត្យឡើងវិញផ្នែកបច្ចេកទេស ត្រូវមានកិច្ចប្រជុំពហុភាគីបន្ថែមទៀត ដែលមានក្រសួងផ្សេងៗ និងភាគីពាក់ព័ន្ធនានាចូលរួម ដែលនៅក្នុងពេលប្រជុំនោះ ត្រូវពិចារណាអំពីអនុសាសន៍នានា។ បន្ទាប់ពីកិច្ចប្រជុំនេះ នឹងមានអនុសាសន៍ចុងក្រោយ ផ្តល់ជូនទៅរដ្ឋមន្ត្រីក្រសួងបរិស្ថានថា តើត្រូវអនុម័ត ឬបដិសេធរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញនោះ។ អាចនឹងមានចេញ វិញ្ញាបនប័ត្រអនុម័តរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន អមដោយលក្ខខណ្ឌពាក់ព័ន្ធនឹងគម្រោង។




តារាងរំហូរសម្រាប់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដកស្រង់ចេញពីប្រកាសស្តីពីគោលការណ៍ណែនាំទូទៅ ឆ្នាំ២០០៩

## ការប្រតិបត្តិ និងការពង្រឹងការអនុវត្ត

*ការដាក់ទោសចំពោះការរំលោភដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន*

ទាំងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ទាំងអនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មានចែងអំពីទោសប្បត្តិ ចំពោះការខកខានមិនបានគោរពច្បាប់ស្តីពីកិច្ចការពារបរិស្ថាននៃប្រទេសកម្ពុជា។ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ អនុញ្ញាតឱ្យក្រសួងបរិស្ថានចេញបញ្ជាជាលាយលក្ខណ៍អក្សរឲ្យចាត់វិធានការកែតម្រូវសកម្មភាពដែលមានចរិកលក្ខណៈរំលោភបំពានច្បាប់ ។ លើសពីនេះទៅទៀត ក្រសួងបរិស្ថាន ក៏អាចចេញបញ្ជាឲ្យផ្អាក សកម្មភាពទាំងឡាយ រហូតសកម្មភាពល្មើសត្រូវបានកែតម្រូវ ឬបញ្ជាឱ្យសម្អាតនូវការបំពុល។

មិនច្បាស់ទេថា តើមានការបញ្ជាបែបនោះដែរឬអត់។ ពុំមានលក្ខខណ្ឌតម្រូវឲ្យក្រសួងបរិស្ថានរក្សាសៀវភៅចុះបញ្ជីការបញ្ជាបែបនោះ ឬបញ្ជីពាក្យបណ្តឹងណាមួយដែលដាក់ជូនទៅក្រសួងបរិស្ថានទេ។

> ជំពូកទី ៩៖ ទោសប្បញ្ញត្តិ
> មាត្រា ២០៖ ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងការកំណត់របស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងមាត្រា១៩នៃច្បាប់នេះ ក្រសួងបរិស្ថានត្រូវចេញបញ្ជាជាលាយលក្ខណ៍អក្សរតម្រូវឱ្យ៖
>
> - កែប្រែសកម្មភាពល្មើសជាបន្ទាន់ ឬក្នុងរយៈពេលណាមួយជាក់លាក់ ឬ
> - ផ្អាកសកម្មភាពរបស់ខ្លួនរហូតដល់បទល្មើសនោះត្រូវបានកែតម្រូវ ឬ
> - លុបបំបាត់ការបំពុល ជាបន្ទាន់។

អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបញ្ជាក់អំពីទោសប្បញ្ញត្តិចំពោះការខកខានមិនបានអនុវត្តតាមបញ្ញត្តិនៃអនុក្រឹត្យនេះ។

> ជំពូកទី ៧៖ ទោសប្បញ្ញត្តិ

មាត្រា ២៩៖ ម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធិដែលខកខានមិនបានផ្តល់ ឬបកស្រាយខុសនូវព័ត៌មាន ឬមិនបានអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នានៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយនៅក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២០/២១/២២/២៣ និង២៥ ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

មាត្រា ៣០៖
កំណត់ហេតុនិងការធ្វើបណ្តឹងចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។

មាត្រា ៣១៖
មន្ត្រីបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ។

មិនច្បាស់ទេថា តើសកម្មភាពពង្រឹងការអនុវត្តច្បាប់ ត្រូវបានចាប់ផ្តើមតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឬអនុក្រឹត្យស្តីពីដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរឬអត់នោះទេ។ ដូចបានកត់សម្គាល់ខាងលើនេះ គ្មានលក្ខខណ្ឌតម្រូវណាមួយឲ្យក្រសួងបរិស្ថានរក្សាសៀវភៅចុះបញ្ជីចំណាត់ការសកម្មភាពពង្រឹងការអនុវត្តច្បាប់ ឬបទបញ្ជាដែលបានចេញនោះទេ។

## ការពិនិត្យតាមដាននិងការប្រតិបត្តិ

ការទទួលខុសត្រូវក្នុងការពិនិត្យតាមដាន ការប្រតិបត្តិ និងការពង្រឹងការអនុវត្តច្បាប់ក៏មានចែងនៅក្នុងប្រកាសនោះដែរ គឺអាស្រ័យលើ ស្ថាប័នណាដែលជាអ្នកអនុម័តគម្រោង។

ប្រកាស ១៥៖
នាយកដ្ឋានអង្កេត និងពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត មានភារកិច្ចតាមដាន ឃ្លាំមើល និងចាត់វិធានការឲ្យម្ចាស់គម្រោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិនិងបញ្ចប់គម្រោង ដូចមានចែង

នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញដែលក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្តបានឯកភាព។

បទប្បញ្ញត្តិបន្ថែម សម្រាប់ការត្រួតពិនិត្យ កំណត់ត្រា និងអធិការកិច្ច ក៏មានចែងនៅក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដែរ។

ជំពូកទី ៦៖ ការត្រួតពិនិត្យ កំណត់ត្រា និងអធិការកិច្ច

មាត្រា ១៤៖

ក្រសួងបរិស្ថានត្រូវសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីកំណត់ឲ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងរោងចក្រ ប្រភពបំពុល តំបន់ឧស្សាហកម្ម ឬតំបន់មានសកម្មភាពអភិវឌ្ឍន៍ធនធានធម្មជាតិនានា៖

- តំឡើងឬប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យ
- ផ្តល់នូវគំរូតាង
- រៀបចំឬរក្សាទុក និងផ្ញើជូនពិនិត្យនូវកំណត់ត្រា និងរបាយការណ៍នានា។

មាត្រា ១៥៖

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន និងការទទួលខុសត្រូវលើតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធ អាចចូលធ្វើអធិការកិច្ចក្នុងតំបន់ ទីក្នុងបរិវេណ អគារ ឬក្នុងមធ្យោបាយដឹកជញ្ជូន ឬទីកន្លែងណាមួយ។ល។ ក្នុងករណីដែលក្រសួងបរិស្ថានពិនិត្យឃើញថា ប្រភពនោះធ្វើឲ្យមានការប៉ះពាល់ដល់គុណភាពបរិស្ថាន។ មន្ត្រីអធិការកិច្ចនៃក្រសួងបរិស្ថាន និងមន្ត្រីរបស់ក្រសួងពាក់ព័ន្ធដែលសហការជាមួយ ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួន នៅមុនពេលធ្វើអធិការកិច្ច។ នៅពេលធ្វើអធិការកិច្ច កាលណាពិនិត្យឃើញថា មានបទល្មើសព្រហ្មទណ្ឌកើតឡើង នោះមន្ត្រីអធិការកិច្ចត្រូវរាយការណ៍ជាបន្ទាន់ជូនស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់ការតាមច្បាប់។

## បណ្តាបញ្ហាឆ្លងដែនក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ពុំមានច្បាប់ឬសន្ធិសញ្ញាអន្តរជាតិគ្រប់គ្រងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានតែមួយណាដែលឯកភាពគ្នានោះឡើយ។[47] មានតែគោលការណ៍ទី១៧នៃសេចក្តីប្រកាសទីក្រុងរីយ៉ូ[48] ដែលជាសេចក្តីថ្លែងការណ៍អន្តរជាតិច្បាស់លាស់ស្តីពីសារសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ជាលិខិតុបករណ៍ជាតិ) ជាវិធីមួយសម្រាប់វាយតម្លៃហេតុប៉ះពាល់មានសក្តានុភាពអំពីគម្រោងទាំងឡាយដែលអាចបង្កឲ្យមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ។ ទោះបីជា ច្បាប់ជាតិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានភាគច្រើនផ្អែកលើគោលការណ៍ដែលមានចែងនៅក្នុងសេចក្តីប្រកាសទីក្រុងរីយ៉ូ ក្នុងការវាយតម្លៃហេតុប៉ះពាល់ក៏ដោយ ក៏មានការទទួលស្គាល់ថាមានចំណុចខ្វះចន្លោះរវាងច្បាប់ទាំងនេះ និងការអនុវត្តជាក់ស្តែងក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរ។

សំណើគម្រោងដែលអាចបង្កផលប៉ះពាល់ឆ្លងដែនមានបញ្ហាដូចគ្នាខ្លះពាក់ព័ន្ធការវាយតម្លៃនិងការចូលរួមជាសាធារណៈ។[49] វិធីដែលអ្នកគាំទ្រគម្រោងឲ្យភាគីពាក់ព័ន្ធនៅក្នុងប្រទេសជិតខាងចូលរួម ទាមទារឲ្យមានការចូលរួមពីរដ្ឋាភិបាល និងការពិចារណាផ្អែកការទូត និងផ្លូវច្បាប់មួយចំនួន។[50]

តាមច្បាប់អន្តរជាតិ មានការទទួលស្គាល់ថា បណ្តាប្រទេសទាំងនោះ មានកាតព្វកិច្ចត្រូវ "ធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកន្លែងណាដែលមានការប្រឈម ដោយសារគម្រោងដែលស្នើសុំនោះ អាចបង្កផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង ក្នុងបរិបទឆ្លងដែនជាពិសេសចំពោះធនធានដែលប្រើប្រាស់រួមគ្នា"។[51] ក្នុងការសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ក្នុងករណីមួយរវាងប្រទេសអាហ្សង់ទីន និងអ៊ុយរូហ្គាយ តុលាការនេះបានទទួលស្គាល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាការអនុវត្ត ដែលក្លាយជាផ្នែកមួយនៃច្បាប់អន្តរជាតិទូទៅក្នុងការអភិវឌ្ឍឧស្សាហកម្មទ្រង់ទ្រាយធំលើផ្លូវទឹកអន្តរជាតិដែលប្រើប្រាស់រួមគ្នា ដោយអាចមានសក្តានុភាពបង្កឲ្យមានការបំពុលបរិស្ថានឆ្លងដែននោះ ជាលទ្ធផលមួយសំខាន់ខ្លាំងណា

---

[47] Kersten, p.178.

[48] All members of ASEAN except Brunei are signatories to the Rio Declaration.

[49] The list of activities likely to have transboundary impacts, for which notification is required under the Espoo Convention is defined in Articles 2 and 3 and Appendix I List of activities. http://www.unece.org/env/eia/about/eia_text.html#appendix1.

[50] Badenoch and WRI, 2002.

[51] Pulp Mills Case (Provisional Measures)(Argentina v. Uruguay) ICJ Reports 2006, p.204

ស់។[52] ករណីនេះ ទោះបីជា គ្មានកាតព្វកិច្ចក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅក្នុងលក្ខន្តិកៈក៏ដោយ ក៏ភាគីទាំងពីរនៅតែឯកភាពគ្នាថា វាគឺជាការចាំបាច់។[53] អាចនិយាយបានថា មានកាតព្វកិច្ចរួមក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅក្នុងកាលៈទេសៈបែបនេះ ទោះបីជាគ្មានការកំណត់អំពីវិសាលភាព និងខ្លឹមសារក៏ដោយ។[54] វាក៏គ្មានការបញ្ជាក់ដែរក្នុងកាតព្វកិច្ចអនុវត្តដំណើរការចូលរួមជាសាធារណៈជាមួយប្រជាជនដែលរងផលប៉ះពាល់។[55]

អាស៊ានបានព្យាយាមរួចហើយក្នុងការដោះស្រាយបណ្តាសកម្មភាព ការបំពុលបរិស្ថានចំហាយផ្សែង សត្វជិតផុតពូជ និងគ្រោះមហន្តរាយធម្មជាតិ ដែលអាចបង្កឲ្យមានផលប៉ះពាល់ឆ្លងដែន។ ទោះយ៉ាងនេះក្តី ក៏មានសកម្មភាព និងគម្រោងជាច្រើនដែលស្ថិតនៅក្នុងប្រទេសតែមួយអាចបង្កផលប៉ះពាល់ហួសពីព្រំដែននៃប្រទេសខ្លួន។ សកម្មនេះអាចជាគម្រោងវារីអគ្គិសនីស្ថានីយ៍ថាមពលដើរដោយធ្យូងថ្ម និងគម្រោងអភិវឌ្ឍនិងឧស្សាហកម្មនុយក្លេអ៊ែរ ឬគម្រោងអាជីវកម្មធនធានធម្មជាតិ។ ទាំងនេះគឺជាគម្រោង ឬសកម្មភាពដែលអាចមានផលប៉ះពាល់ឆ្លងដែនដែលគប្បីត្រូវធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវ មុនពេលការអនុម័ត។

នៅក្នុងតំបន់ទន្លេមេគង្គ មានកិច្ចព្រមព្រៀងនិងយន្តការជាច្រើនសម្រាប់ការពិចារណាអំពីបញ្ហាបរិស្ថានឆ្លងដែន ប៉ុន្តែនៅតែគ្មានកិច្ចព្រមព្រៀងសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដូចជា គ្មានក្របខណ្ឌថ្នាក់តំបន់សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចំពោះគម្រោងដែលស្នើឡើង ហើយមានផលប៉ះពាល់ឆ្លងដែន។ គណៈកម្មការទន្លេមេគង្គ មានបទពិសោធន៍យ៉ាងទូលំទូលាយក្នុងបញ្ហាការគ្រប់គ្រងទឹកដែលមានផលប៉ះពាល់ឆ្លងដែន។ នៅឆ្នាំ ២០០២ គណៈកម្មការទន្លេមេគង្គ បានរៀបចំតាក់តែងសេចក្តីព្រាងក្របខណ្ឌមួយសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលនៅតែជាសំណើទូលំទូលាយបំផុតនៅក្នុងតំបន់រហូតដល់ពេលនេះ។

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចការពារ និងការប្រើប្រាស់ផ្លូវទឹកឆ្លងដែននិងបឹងអន្តរជាតិ អំពាវនាវឱ្យរដ្ឋជាសមាជិកអនុម័តច្បាប់ដែលត្រូវអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះសន្ធិសញ្ញាព្រំដែនទឹក។[56] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់អភិរក្សនិងប្រើ

[52] See unpublished paper by Remy Kinna, and McIntyre (2011) and McIntyre (2010).
[53] Pulp Mills on the River Uruguay (Argentina v Uruguay) ICJ Advisory Opinion (Order of 20 April, 2010) I.C.J. Reports 2010, at Par 203 & 204.
[54] Pulp Mills on the River Uruguay (Argentina v Uruguay) ICJ Advisory Opinion (Order of 20 April, 2010) I.C.J. Reports 2010, at Par 205.
[55] Pulp Mills on the River Uruguay (Argentina v Uruguay) ICJ Advisory Opinion (Order of 20 April, 2010) I.C.J. Reports 2010, at Par 204.
[56] Kersten, p.180.

ប្រាស់ផ្លូវទឹកអន្តរជាតិ មានចែងតែចំពោះការជូនដំណឹងអំពីវិធានការដែលបានគ្រោងឡើង ដោយអាចនឹងបង្កផលប៉ះពាល់អាក្រក់តែប៉ុណ្ណោះ។ ព័ត៌មានបែបនេះអាចមានបញ្ចូលលទ្ធផលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[57]ដោយសារមាន កាតព្វកិច្ចនៅក្នុងអនុសញ្ញានេះ ក្នុងកិច្ច "ការពារនិងអភិរក្សប្រព័ន្ធអេកូឡូស៊ីផ្លូវទឹកអន្តរជាតិ" ដូច្នេះពុំមានលក្ខខណ្ឌតម្រូវឲ្យធ្វើការវាយតម្លៃបរិស្ថានឆ្លងដែនទេ។[58]

គណៈកម្មាការសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិទទួលបន្ទុកតំបន់អឺរ៉ុបបានដើរតួឈានមុខក្នុងការអភិវឌ្ឍយន្តការដែលគាំទ្រផង និងលើកកម្ពស់តួនាទីនៃច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានផង ព្រមទាំងពិនិត្យវិធីនានាដែលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចជួយក្នុងបរិបទតំបន់។ លិខិតុបករណ៍បីដែលអន្តរជាតិទទួលស្គាល់ភាគច្រើនបំផុតទាក់ទងទៅនឹងការវាយតម្លៃបរិស្ថានគឺះ

- អនុសញ្ញាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែន (អនុសញ្ញាទីក្រុងអ៊ែស្ពូ)
- ពិធីសារស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត និង
- អនុសញ្ញាស្តីពីសិទ្ធិទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេច និងសិទ្ធិទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន (អនុសញ្ញាអាហ៊ូស)។

លិខិតុបករណ៍អន្តរជាតិនីមួយៗយកចេញពីបទដ្ឋានច្បាប់បរិស្ថានអន្តរជាតិ ដែលមានស្រាប់។ លិខិតុបករណ៍នីមួយៗ ឆ្លើយតបនឹងលក្ខណៈនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

គណៈកម្មការសេដ្ឋកិច្ចសម្រាប់តំបន់អឺរ៉ុបបានអនុម័តគោលការណ៍ណែនាំស្តីពីការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែន ដើម្បីគាំទ្រដល់កិច្ចព្រមព្រៀងអន្តររដ្ឋាភិបាលអឺរ៉ុបសំខាន់ពីរស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការចូលរួមជាសាធារណៈ - អនុសញ្ញាឆ្នាំ១៩៩១ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែន (អនុសញ្ញាទីក្រុងអ៊ែស្ពូ) និងអនុសញ្ញាឆ្នាំ១៩៩៨ ស្តីពីសិទ្ធិទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈ ក្នុងការធ្វើសេចក្តីសម្រេចនិងការទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន (អនុសញ្ញាអាហ៊ូស)។[59]

---

[57] Article 12. Viet Nam is the only ASEAN Member State that is a signatory to this Convention.
[58] Article 20.
[59] UNECE (2006) *Guidance on Public Participation in Environmental Impact Assessment in a Transboundary Context*, ECE/MP.EIA/7.

## អនុសញ្ញាស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែន (អនុសញ្ញាអ៊ែស្ពូ)

ជាលទ្ធផលនៃការអនុម័តប្រើប្រាស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បណ្តារដ្ឋជាសមាជិកភាគច្រើន នៅតំបន់អឺរ៉ុប គឺនៅឆ្នាំ១៩៨៧ មានអ្នកជំនាញមួយក្រុមមកពីគណៈកម្មាធិការសេដ្ឋកិច្ចអង្គការសហប្រជាជាតិសម្រាប់តំបន់អឺរ៉ុប បានពន្យល់យ៉ាងលម្អិតអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងបរិបទឆ្លងដែន។ អនុសញ្ញានេះត្រូវបានលើកមកពិភាក្សាពីឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩០ និងត្រូវបានបើកឲ្យផ្តល់សច្ចាប័នចាប់ពីថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៩១។ អនុសញ្ញានេះបានចូលជាធរមាននៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧។ បច្ចុប្បន្ន អនុសញ្ញាទីក្រុងអ៊ែស្ពូ មាន៤៥ភាគីរួមទាំងសហភាពអឺរ៉ុប សហរដ្ឋអាមេរិក និងសហព័ន្ធរុស្ស៊ីផង។

អនុសញ្ញាអ៊ែស្ពូគឺជាយន្តការបង្ការដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន យ៉ាងសំខាន់ ក្នុងគោលបំណងជួយធ្វើឱ្យការអភិវឌ្ឍមាននិរន្តរភាព ដោយជំរុញឲ្យមានកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលអាចកើតឡើងពី សកម្មភាពដែលបានស្នើឡើង។ ជាពិសេសអនុញ្ញានេះអនុវត្តចំពោះសកម្មភាពដែលអាចបង្កផលប៉ះពាល់ដល់បរិស្ថាននៅក្នុងប្រទេសដទៃទៀត។[60]

សំខាន់គឺត្រូវកត់សម្គាល់ថា អនុសញ្ញាអ៊ែស្ពូ គឺជាអនុសញ្ញាផ្តោតលើដំណើរការ ដែលតាមអនុសញ្ញាអ៊ែស្ពូនេះ បណ្តាភាគីត្រូវចាត់ "រាល់វិធានការសមស្រប និងមានប្រសិទ្ធភាពដើម្បីទប់ស្កាត់ កាត់បន្ថយ និងគ្រប់គ្រងផលប៉ះពាល់បរិស្ថានឆ្លងដែនធ្ងន់ធ្ងរ ដែលបណ្តាលមកពីសកម្មភាពដែលបានស្នើឡើង"។[61]

លក្ខខណ្ឌនៃអនុសញ្ញាអ៊ែស្ពូ គឺកាតព្វកិច្ចតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានកម្រិតគម្រោង ផ្តល់ដំណឹងទៅបណ្តាប្រទេសដែលអាចប្រឈមផលប៉ះពាល់ ផ្តល់សិទ្ធិទទួលព័ត៌មានជូនបណ្តាភាគីដែលអាចប្រឈមផលប៉ះពាល់ និងអនុញ្ញាតឲ្យផ្តល់មតិ និងជូនដំណឹងស្តីពីការសម្រេចចុងក្រោយពាក់ព័ន្ធនឹងគម្រោង។[62] អនុសញ្ញាអ៊ែស្ពូមានបញ្ជីសកម្មភាពក្នុងឧបសម្ព័ន្ធ ១ ដែលមានចែងក្នុងអនុសញ្ញា និងបញ្ជីព័ត៌មានជា

[60] Vesna Kolar Planinšič (2016), Ministry of the Environment and Spatial Planning of the Republic of Slovenia. Various presentations to the RTWG on EIA.
[61] Espoo Convention, Article 2.
[62] These are contained in Articles 3 to 6 of the Espoo Convention.

អប្បបរមា ដែលគប្បីត្រូវបញ្ចូលនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងឧបសម្ព័ន្ធ ២។

អនុសញ្ញាអ៊ែស្ពូមានសារសំខាន់ ព្រោះវាផ្អែកលើបទដ្ឋានច្បាប់អន្តរជាតិ និងផ្ដល់សិទ្ធិទទួលបានព័ត៌មាន ព្រមទាំងសិទ្ធិចូលរួម និងជូនដំណឹងអំពីផលប៉ះពាល់ធ្ងន់ធ្ងរពីបណ្ដាសកម្មភាពដែលមានផលប៉ះពាល់ឆ្លងដែន។

## ពិធីសារស្ដីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

បន្ថែមលើអនុសញ្ញាស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែន បណ្ដាភាគីបានចរចារអំពីពិធីសារស្ដីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនេះ។ ពិធីសារនេះ ចូលជាធរមាននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១០។ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រគ្របលើការវាយតម្លៃគោលនយោបាយ ឬកម្មវិធីបរិស្ថាន ដោយសមាជិករដ្ឋាភិបាលដែលអាចនឹងប្រឈមផលប៉ះពាល់បរិស្ថានខ្លាំង រួមទាំងផលប៉ះពាល់ដល់សុខភាពផង។[63]

តាមពិធីសារនេះ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ បានកំណត់និយមន័យដូច្នេះ៖

> ការវាយតម្លៃហេតុផលប៉ះពាល់ដែលអាចនឹងកើតមានលើបរិស្ថាន រួមទាំងផលប៉ះពាល់សុខភាពផង ដោយមានការកំណត់អំពីវិសាលភាពនៃរបាយការណ៍បរិស្ថាន និងការរៀបចំរបាយការណ៍ ការអនុវត្តការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈ និងការពិចារណាលើរបាយការណ៍បរិស្ថាន និងលទ្ធផលនៃការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈក្នុងផែនការ ឬកម្មវិធី។[64]

ពិធីសារស្ដីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ តម្រូវឱ្យមានការរៀបចំការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ សម្រាប់ផែនការ និងគោលនយោបាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការចូលរួម និងការពិគ្រោះយោបល់ជាសាធារណៈជាលក្ខខណ្ឌតម្រូវដែលភាគីជាសមាជិកត្រូវបំពេញ។[65] ពិធីសារវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រសំដៅលើ "ការផ្ដល់ឱកាសគ្រប់គ្រាន់ ទាន់ពេល និងមានប្រសិទ្ធភាព"។ ពិធីសារនេះ ក៏តម្រូវឲ្យផ្ដល់ជូនសាធារណជន រួមទាំងអង្គការមិនមែនរ

[63] SEA Protocol, Article 4.
[64] SEA Protocol, Article 2.
[65] SEA Protocol, Article 8.

ដ្ឋាភិបាលផងនូវព័ត៌មានចាំបាច់ៗដើម្បីអនុញ្ញាតឲ្យផ្តល់មតិ "ក្នុងពេលវេលាកំណត់សមហេតុសមផល"។

ទន្ទឹមនឹងនេះ ក៏មានលក្ខខណ្ឌតម្រូវអំពីការពិគ្រោះយោបល់ឆ្លងដែនដែរ ប្រសិនបើ មើលទៅទំនងជាឃើញថា ការអនុវត្តផែនការ ឬគោលនយោបាយនេះនឹងបង្កឲ្យមានផលប៉ះពាល់ឆ្លងដែន។[66]

## អនុសញ្ញាស្តីពីសិទ្ធិទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេច និងសិទ្ធិទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន (អនុសញ្ញាអាហ៊្វស)

ធាតុមួយក្នុងចំណោមធាតុយ៉ាងសំខាន់បំផុតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺតម្រូវការឲ្យមានការចូលរួមជាសាធារណៈប្រកបដោយប្រសិទ្ធភាព។ ដើម្បីសម្រេចបាននូវការចូលរួមជាសាធារណៈប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវឲ្យសហគមន៍មានលទ្ធភាពទទួលបានព័ត៌មានស្តីពីគម្រោងនិងផលប៉ះពាល់បណ្តាលមកពីគម្រោង ដែលរៀបចំដោយអ្នកគាំទ្រគម្រោង និងដោយរដ្ឋាភិបាល។ គោលការណ៍ទី១០នៃសេចក្តីប្រកាសក្រុងរីយ៉ូឆ្លើយតបនឹងលក្ខខណ្ឌតម្រូវជាមូលដ្ឋានទាំងនេះ។

អនុសញ្ញាអាហ៊្វស ត្រូវបានសម្រេចជាផ្នែកមួយនៃដំណើរការ "បរិស្ថានដើម្បីអឺរ៉ុប" របស់គណៈកម្មាធិការសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិសម្រាប់តំបន់អឺរ៉ុប និងបានចូលជាធរមាន នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០១។[67] វាត្រូវបានគេទទួលស្គាល់ថា មានសារសំខាន់ជាសកលសម្រាប់ការលើកកម្ពស់អភិបាលកិច្ចបរិស្ថាន។[68]

អនុសញ្ញាអាហ៊្វសមានសសរស្តម្ភសំខាន់ៗបីគឺ៖

- សិទ្ធិរបស់សាធារណជនក្នុងការទទួលប្រើប្រាស់ព័ត៌មានអំពីបរិស្ថាននិងការអភិវឌ្ឍ
- លក្ខខណ្ឌតម្រូវឲ្យមានការចូលរួមជាសាធារណៈក្នុងការវាយតម្លៃបរិស្ថានពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ជាក់លាក់[69] និង

[66] SEA Protocol, Article 10.

[67] http://www.unece.org/env/pp/welcome.html http://europa.eu.int/comm/environment/aarhus.

[68] D. Craig and M. Jeffrey, Non-Lawyers and Legal Regimes, in Leary, 2010, p.105.

[69] These matters are listed in Annex 1 of the Aarhus Convention. These matters also include any activity not specifically covered in the Annex, where public participation is provided for under an environmental impact assessment procedure in accordance with national legislation.

- សិទ្ធិសម្រាប់សាធារណជនដែលត្រូវមានលទ្ធភាពប្រើប្រាស់តុលាការ និងសាលាក្តី ដើម្បីទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន។[70]

រហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ២០១៤ អនុសញ្ញានេះមាន៤៦ភាគី ពិធីសារស្តីពីការបញ្ចេញជាតិពុលនិងការចុះបញ្ជីផ្ទេរ មាន៣៣ភាគី និងវិសោធនកម្មស្តីពីការចូលរួមជាសាធារណៈក្នុងការសម្រេចចិត្តលើការបញ្ចេញដោយចេតនាទៅក្នុងបរិស្ថាន និងការដាក់ក្នុងទីផ្សារនូវសរីរាង្គកែប្រែហ្សែន មាន២៧ភាគី។[71]

បុព្វកថានៃអនុសញ្ញានេះ យោងទៅគោលការណ៍ទី១នៃសេចក្តីប្រកាសរដ្ឋធានី Stockholm ស្តីពីបរិស្ថានមនុស្សជាតិ និងយោងទៅគោលការណ៍ទី១០នៃសេចក្តីប្រកាសទីក្រុងរីយ៉ូស្តីពីបរិស្ថាន និងការអភិវឌ្ឍ។ គោលការណ៍ទី១០ចែងថា៖

> បញ្ហាបរិស្ថានត្រូវដោះស្រាយឲ្យបានល្អបំផុតដោយមានការចូលរួមរបស់ពលរដ្ឋពាក់ព័ន្ធទាំងអស់ ក្នុងថ្នាក់ពាក់ព័ន្ធ។ នៅថ្នាក់ជាតិ បុគ្គលម្នាក់ៗ គប្បីត្រូវមានលទ្ធភាពសមស្របទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹងបរិស្ថាន ដែលគ្រប់គ្រងដោយអាជ្ញាធរសាធារណៈ រួមទាំងព័ត៌មានស្តីពីសារធាតុបង្កគ្រោះថ្នាក់ និងបណ្តាសកម្មភាពនៅក្នុងសហគមន៍របស់ពួកគាត់ និងទទួលបានឱកាសចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេច។ បណ្តារដ្ឋ ត្រូវសម្រួល និងបំផុសឲ្យមានការយល់ដឹង និងមានការចូលរួមជាសាធារណៈ ដោយផ្សព្វផ្សាយ ឬប្រកាសព័ត៌មានឲ្យបានទូលំទូលាយ។ ត្រូវផ្តល់ជូននូវលទ្ធភាពប្រើប្រាស់កិច្ចដំណើរការនីតិវិធីតុលាការនិងរដ្ឋបាលដោយប្រសិទ្ធភាព រួមទាំងការផ្តល់សំណងនិងដំណោះស្រាយផង។

អនុសញ្ញាអាហ៊ូស បានទទួលស្គាល់ថា ការផ្តល់ឱកាសឲ្យសាធារណជនចូលរួម សំខាន់ណាស់ ក្នុងការបង្កើតអនាគតប្រកបដោយនិរន្តរភាពបរិស្ថាន។ ការទទួលស្គាល់នេះ ត្រូវបានបន្តដោយកិច្ចប្រជុំរបស់ភាគីក្នុងអនុសញ្ញាអាហ៊ូស។ អានុភាពមួយក្នុងចំណោមអានុភាពនៃអនុសញ្ញាអាហ៊ូស គឺសមត្ថភាពរបស់បណ្តាភាគីក្នុងការបន្តការចរចាដើម្បីក្តោបទៅលើបញ្ហាបន្ថែមទៀត ទៅតាមអនុសញ្ញាអាហ៊ូស ដែលអានុភាពទាំងនោះ រួមមានពិធីសារមួយដើម្បីបង្កើនលទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មាន តាមរយៈការបង្កើតបញ្ជីផ្ទេរ និងការបញ្ចេញសារធាតុពុលទូទាំងប្រទេស រួម ច្បាស់លាស់។

---

70 Aarhus Convention, Articles 4-9.

71 Detailed information about ratification of the Aarhus Convention is available at http://www.unece.org/env/pp/ratification.html.

លើសពីនេះទៅទៀត គោលការណ៍ណែនាំនៃកម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ ដើម្បីការអភិវឌ្ឍច្បាប់ជាតិស្តីពីសិទ្ធិទទួលបានព័ត៌មាន ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន ឆ្លើយតបនឹងគោលការណ៍ អាហ៊ូស នៅថ្នាក់សកល។[72] គេអាចចាត់ទុកថា គោលការណ៍ស្នូលនៃអនុសញ្ញា អាហ៊ូស ឆ្លើយតបទៅនឹងបទដ្ឋាននៃច្បាប់បរិស្ថានអន្តរជាតិបែបប្រពៃណី និងជាសសរស្តម្ភគ្រឹះសម្រាប់អភិបាលកិច្ចបរិស្ថានកាន់តែល្អប្រសើរ និងដើម្បីទទួលបានសមិទ្ធផលនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព។[73]

## កិច្ចព្រមព្រៀងទន្លេមេគង្គ

កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ (កិច្ចព្រមព្រៀងមេគង្គ) ឆ្នាំ១៩៩៥ តម្រូវឲ្យប្រទេសជាសមាជិកផ្តល់ដំណឹងនិងមានការពិគ្រោះយោបល់ជាមុនដើម្បីពិភាក្សា អំពីផលប៉ះពាល់ឆ្លងដែនសម្រាប់គម្រោងធនធានទឹកនៅតំបន់ទន្លេមេគង្គដែលអាចមានផលប៉ះពាល់ដល់ប្រទេសជិតខាង មុនពេលមានកិច្ចសន្យាអនុវត្តគម្រោងបន្ត។[74]

កិច្ចព្រមព្រៀងមេគង្គត្រូវបានចុះហត្ថលេខានៅក្រុងឈៀងម៉ៃ ប្រទេសថៃ កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៥។ អង្គការសហប្រជាជាតិបានបង្កើតគណៈកម្មាការទន្លេមេគង្គនៅឆ្នាំ១៩៥៩ ប៉ុន្តែកិច្ចព្រមព្រៀងមេគង្គបានឆ្លើយតបទៅនឹងការសម្រេចចិត្តដោយប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមដើម្បីបង្កើតក្របខ័ណ្ឌថ្នាក់តំបន់មួយសម្រាប់កិច្ចសហប្រតិបត្តិការនៅតាមបណ្តោយអាងទន្លេមេគង្គនេះ។

តាំងតែពីពេលចាប់ផ្តើមនោះមក កិច្ចព្រមព្រៀងមេគង្គត្រូវបានផ្តោតលើការអភិវឌ្ឍ ការប្រើប្រាស់ ការអភិរក្ស និងការគ្រប់គ្រងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព។[75]

*ប្រការ ៣៖ ការការពារបរិស្ថាន និងតុល្យភាពបរិស្ថានវិទ្យា*

[72] Detailed information on the history of the Aarhus Convention is available at http://www.unece.org/fileadmin/DAM//env/pp/welcome.html. Chisinau Declaration As adopted on 1 July 2011.
[73] Craig and Jeffrey, in Leary, 2010, p.123.
[74] Mekong River Commission, *Transboundary EIA*, http://www.mrcmekong.org/about-mrc/programmes/environment-programme/transboundary-eia.
[75] Preamble, Mekong Agreement.

ការការពារបរិស្ថាន ធនធានធម្មជាតិ វារីជាតិ និងស្ថានភាពវារីជាតិ និងតុល្យភាពបរិស្ថានវិទ្យានៃអាងទន្លេមេគង្គពីភាពល្អក់ក្រខ្វក់ ឬក៏ផលប៉ះពាល់អាក្រក់ឯទៀត ដែលកើតឡើងពីផែនការអភិវឌ្ឍន៍ និងការប្រើប្រាស់ទឹក និងធនធានធម្មជាតិដែលទាក់ទងឯទៀតនៅក្នុងអាងទន្លេ។

*ប្រការ ៤៖ អធិបតេយ្យភាពស្មើគ្នា និងបូរណភាពដែនដី*
រួមសហគ្នាដោយឈរលើគោលការណ៍នៃអធិបតេយ្យភាពស្មើភាពគ្នា និងបូរណភាពដែនដីក្នុងការប្រើប្រាស់ និងថែរក្សាធនធានទឹកនៃអាងទន្លេមេគង្គ។

គន្លឹះទទួលជោគជ័យ (និងបរាជ័យ) ក្នុងការអនុវត្តកិច្ចព្រមព្រៀងមេគង្គ គឺតម្រូវការចាំបាច់ឲ្យគ្រប់ភាគីធ្វើសកម្មភាពដោយសហការគ្នា ក្នុងបញ្ហាដែលប៉ះពាល់សិទ្ធិរបស់សមាជិកនៃរដ្ឋនីមួយៗក្នុងការប្រើប្រាស់ធនធានទន្លេមេគង្គ។ លើសពីនេះទៅទៀត កិច្ចព្រមព្រៀងមេគង្គទទួលស្គាល់យ៉ាងច្បាស់ថា មានសកម្មភាពជាច្រើន ដែលអាចមានផលប៉ះពាល់ឆ្លងដែន មិនត្រឹមតែលើវារីអគ្គិសនីនោះទេ ប៉ុន្តែថែមទាំងលើ ការដឹកទំនិញតាមកប៉ាល់ ប្រព័ន្ធធារាសាស្ត្រ និងការនេសាទថែមទៀតផង។

កិច្ចព្រមព្រៀងមេគង្គ បានបង្កើតឡើងនូវគណៈកម្មការទន្លេមេគង្គ ដែលមានក្រុមប្រឹក្សា គណៈកម្មាធិការចម្រុះ និងលេខាធិការដ្ឋាន។[76] ចាប់តាំងពីពេលនោះមក ការងាររបស់គណៈកម្មការទន្លេមេគង្គ បានរីកកាន់តែធំ ហើយបានបញ្ចូលកម្មវិធីសំខាន់ៗដើម្បីវាយតម្លៃនិងស្រាវជ្រាវលើសកម្មភាពនៅតាមអាងទន្លេមេគង្គ។ នៅឆ្នាំ២០១១ គណៈកម្មការទន្លេមេគង្គ បានអនុម័តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ សម្រាប់អាងទន្លេមេគង្គ និងបានអនុម័តផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១១-២០១៥ របស់ខ្លួន។

លក្ខណៈសំខាន់នៃកិច្ចព្រមព្រៀងមេគង្គ តាមទស្សនៈនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនគឺលក្ខខណ្ឌតម្រូវឲ្យមានការពិគ្រោះពិភាក្សាជាមុន។ ការពិគ្រោះពិភាក្សាជាមុនត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងមេគង្គ ដូចខាងក្រោម៖

[76] Chapter IV.

**ការពិគ្រោះពិភាក្សាជាមុន៖** ការជូនដំណឹងយ៉ាងទាន់ពេលវេលា រួមទាំងទិន្នន័យនិងព័ត៌មានបន្ថែម ចំពោះគណៈកម្មាធិការរួម ដូចមានចែងក្នុងបទប្បញ្ញត្តិសម្រាប់ការប្រើប្រាស់ទឹក និងការបង្វែរទឹកពីអាងទន្លេមួយទៅអាងទន្លេមួយទៀត ស្របតាមមាត្រា ២៦ ដែលអនុញ្ញាតឱ្យប្រទេសស្ថិតនៅតាមដងទន្លេជាសមាជិកធ្វើការពិភាក្សានិងវាយតម្លៃផលប៉ះពាល់នៃគម្រោងសំណើប្រើប្រាស់ណាមួយ មកលើការប្រើប្រាស់ទឹករបស់ប្រទេសជាសមាជិកឯទៀត និងអំពីផលប៉ះពាល់ដែលជាមូលដ្ឋាន សម្រាប់ការឈានដល់ការសម្រេចកិច្ចព្រមព្រៀងណាមួយ។ ការសុំយោបល់ជាមុន មិនមែនជាសិទ្ធិបដិសេធ ការប្រើប្រាស់ ហើយក៏មិនមែនជាសិទ្ធិឯកតោភាគីក្នុងការប្រើទឹកដោយប្រទេសតាមដងទន្លេណាមួយ ដោយមិនបានគិតគូរដល់សិទ្ធិនៃប្រទេសតាមដងទន្លេផ្សេងទៀតឡើយ។[77]

មានការទទួលស្គាល់ថា គណៈកម្មការទន្លេមេគង្គ ក្នុងរយៈពេលជាង២០ឆ្នាំមកនេះបានរួមចំណែកច្រើនណាស់ក្នុងការសិក្សាអំពីអាងទន្លេមេគង្គ។ គម្រោងរបស់ខ្លួនជាច្រើនពិនិត្យលើផលប៉ះពាល់ពីការអភិវឌ្ឍ និងលើស្ថានភាពកំពុងប្រើប្រាស់អាងទន្លេមេគង្គ។ ថ្មីៗនេះ ការងាររបស់គណៈកម្មការទន្លេមេគង្គផ្តោតសំខាន់លើការពិភាក្សាអំពីការពង្រីកការអភិវឌ្ឍទំនប់វារីអគ្គិសនី ទាំងនៅទន្លេមេគង្គដែលជាទន្លេមេ និងនៅដៃទន្លេនេះ។

ជោគជ័យ (និងបរាជ័យ) របស់គណៈកម្មការទន្លេមេគង្គគឺ គណៈកម្មការនេះបានអនុម័តវិធីសាស្ត្រកិច្ចសហប្រតិបត្តិការដោយផ្អែកលើការលើកកម្ពស់ការឯកភាពគ្នា និងកិច្ចសហប្រតិបត្តិការ មិនមែនជាការប្រឈមមុខគ្នា។ គណៈកម្មការទន្លេមេគង្គក៏ពឹងផ្អែកយ៉ាងខ្លាំងលើជំនួយបរទេសដែរ។ មានការលើកឡើងថា ការពឹងផ្អែកលើជំនួយបរទេសបែបនេះបានបង្កើតនូវ "អារម្មណ៍បាត់បង់ការគាំទ្ររបស់គណៈកម្មការទន្លេមេគង្គចំពោះរដ្ឋជាសមាជិករបស់ខ្លួន"។[78]

## នីតិវិធីជូនដំណឹង ពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង

ដូចបានលើកឡើងខាងលើរួចហើយថា លក្ខណៈសំខាន់មួយក្នុងចំណោមលក្ខណៈសំខាន់ៗនៃកិច្ចព្រមព្រៀងមេគង្គ គឺលក្ខខណ្ឌតម្រូវឲ្យមានការពិគ្រោះយោបល់ជាមុន។ ចំណុចនេះត្រូវបានធ្វើឲ្យកាន់តែប្រសើរឡើងទៀតដោយប្រើនីតិវិធីជូនដំណឹង ពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៣។

[77] The Mekong Agreement, Chapter 2
[78] Only One Mekong, p.961.

នីតិវិធីជូនដំណឹង ពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងនេះ ត្រូវបានអនុម័តដើម្បីលើកកម្ពស់ការយល់ដឹងនិងកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរជាងមុន ក្នុងចំណោមប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ។ គោលការណ៍ណែនាំនៃនីតិវិធីជូនដំណឹង ពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងគឺ៖

- អធិបតេយ្យភាពស្មើគ្នា និងបូរណភាពដែនដី
- ការប្រើប្រាស់ដោយសមហេតុផល និងដោយសមធម៌
- ការគោរពសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់
- សុចរិតភាព និង
- តម្លាភាព។[79]

គោលបំណងនៃនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង ដែលមានសារធាតុស្រដៀងគ្នាទៅនឹងលក្ខខណ្ឌតម្រូវឲ្យមានការជូនដំណឹងដែលមានចែងក្នុងអនុសញ្ញាអ៊ែស្ពូ គឺត្រូវជូនដំណឹងទៅបណ្តាប្រទេសជាសមាជិកផ្សេងៗទៀត អំពីការអភិវឌ្ឍដែលអាចមានផលប៉ះពាល់ឆ្លងដែន។ នីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងនេះ ក៏ផ្តល់ឱកាសជូនភាគីដែលរងផលប៉ះពាល់ ពិចារណាអំពីព័ត៌មានដែលមាននៅក្នុងសេចក្តីជូនដំណឹង និងស្នើសុំព័ត៌មាន ឬសុំការបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់ដែរ។ ពេលវេលាសម្រាប់ការពិគ្រោះយោបល់ជាមុន ត្រូវកំណត់រយៈពេលប្រាំមួយខែ ដោយអាចមានលទ្ធភាពពន្យារបន្ថែម។[80] ការអនុម័តត្រូវបានពិចារណាដោយផ្អែកលើមូលដ្ឋានជាក់ស្តែងពីករណីមួយទៅករណីមួយ។[81]

ទាំងគណៈកម្មការទន្លេមេគង្គ ទាំងគណៈកម្មាធិការចម្រុះនៃគណៈកម្មការទន្លេមេគង្គ មានតួនាទីជួយក្នុងដំណើរការបញ្ជូន និងដំណើរការពិគ្រោះយោបល់។[82] ដំណើរការនៃនីតិវិធីសម្រាប់ជូនណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងនេះធ្វើឱ្យមានការប្រើប្រាស់បានល្អនូវការរៀបចំស្ថាប័នដែលមានស្រាប់ រួមទាំងគណៈកម្មាធិការជាតិទន្លេមេគង្គ ដែលត្រូវបានបង្កើតឡើងតាមកិច្ចព្រមព្រៀងមេគង្គ។

គុណតម្លៃនៃដំណើរការនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងមិនអាចត្រូវមើលរំលងនោះឡើយ ទោះបីជា វាអនុវត្តចំពោះតែគម្រោងមួយចំនួន និងបានក្លាយជា

[79] PNPCA, Article 3.
[80] See PNPCA, Article 5.5
[81] PNPCA, Article 6.
[82] PNPCA, Article 5.3.3

ប្រធានបទនៃការរិះគន់ក៏ដោយ។[83] អ្វីដែលច្បាស់អំពីនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង និងកិច្ចព្រមព្រៀងមេគង្គគឺបណ្តាប្រទេសជាសមាជិកបានឯកភាពគ្នាអនុញ្ញាតឱ្យមានការជូនដំណឹងជាមុន និងការពិគ្រោះយោបល់ជាមុនសម្រាប់បណ្តាសកម្មភាព និងគម្រោងដែលអាចមានផលប៉ះពាល់ឆ្លងដែន។ ក៏មានទទួលស្គាល់ដែរថា អង្គភាពលេខាធិការដ្ឋានចាំបាច់ត្រូវជួយក្នុងដំណើរការនៃការជូនដំណឹង និងការពិគ្រោះយោបល់។

**ការពិចារណាអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយគណៈកម្មការទន្លេមេគង្គ**

គណៈកម្មការទន្លេមេគង្គបានព្យាយាមជំរុញគំនិត អំពីក្របខណ្ឌនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែននេះ។ នៅឆ្នាំ១៩៩៨ គណៈកម្មការទន្លេមេគង្គបានយល់ព្រមបង្កើតនិងអនុម័តប្រព័ន្ធមួយសម្រាប់វាយតម្លៃបរិស្ថានក្នុងបរិបទឆ្លងដែន។[84] អនុវត្តតាមរបាយការណ៍មួយដែលរៀបចំដោយគណៈគ្រប់គ្រងធនធានបរិស្ថាននៅខែមេសា ឆ្នាំ២០០២ មានរបាយការណ៍គោលការណ៍ណែនាំមួយត្រូវបានដាក់ជូន គណៈកម្មការទន្លេមេគង្គ។[85] របាយការណ៍របស់គណៈគ្រប់គ្រងធនធានបរិស្ថាននេះ រួមមានរបាយការណ៍អំពីសារតារ និងរបាយការណ៍ស្តីពីប្រព័ន្ធដែលស្នើឡើង។

របាយការណ៍ប្រព័ន្ធដែលស្នើឡើងនោះ បានកត់សម្គាល់ថា ឯកសារគោលនយោបាយនោះ "មិនមានបំណងដាក់ជំនួសលក្ខខណ្ឌតម្រូវនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននានា ដែលមានស្រាប់ នៅក្នុងប្រទេសនីមួយៗនោះទេ" ប៉ុន្តែគ្រាន់តែជាសំណើបំពេញបន្ថែមលើក្របខណ្ឌដែលអនុវត្តចំពោះបណ្តាគម្រោងទាំងឡាយដែលមានសក្តានុភាពអាចបង្កឱ្យមានផលប៉ះពាល់ឆ្លងដែនតែប៉ុណ្ណោះ។[86]

របាយការណ៍ប្រព័ន្ធដែលស្នើឡើងនោះត្រូវបំបែកទៅជាបីផ្នែកគឺ៖

- ប្រព័ន្ធរងសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

[83] PNPCA, Article 4.
[84] P. King, Transboundary EIA and Climate Change in the Greater Mekong Subregion (GMS), presented at the Stimson Centre Conference, Finding Solution to Equitable Hydropower Development Planning in the Lower Mekong Basin, Chiang Rai, 2014
[85] Environmental Resources Management, Development of an EIA/SEA System for the Lower Mekong Basin, April 2002 (ERM Report)
[86] Environmental Resources Management, Development of an EIA/SEA System for the Lower Mekong Basin Proposed System, April 2002 (the Proposed System Report).

- គោលនយោបាយស្តីពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែនសម្រាប់គណៈកម្មការទន្លេមេគង្គ និង
- ប្រព័ន្ធវងសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ប្រព័ន្ធដែលស្នើឡើងនោះ ក៏មានធាតុមួយចំនួនទៀតដែរ គឺៈ

- សេចក្តីស្នើគោលនយោបាយស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងបរិបទឆ្លងដែន
- គោលការណ៍ណែនាំស្តីពីការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ
- គោលការណ៍ណែនាំស្តីពីការវាយតម្លៃផលប៉ះពាល់កើនឡើង
- គោលការណ៍ណែនាំស្តីពីការចូលរួមជាសាធារណៈក្នុងការវាយតម្លៃបរិស្ថាន
- លក្ខណៈវិនិច្ឆ័យពិនិត្យឡើងវិញលើសេចក្តីថ្លែងការណ៍អំពីផលប៉ះពាល់បរិស្ថាន
- គោលការណ៍ណែនាំស្តីពីវិស័យ និង
- កម្មវិធីបណ្តុះបណ្តាលដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធ វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ដូចលោកឃីង (King) បានកត់សម្គាល់ តាំងពីបានធ្វើបទបង្ហាញរបាយការណ៍លម្អិតទាំងនេះជូនគណៈកម្មការទន្លេមេគង្គ នៅឆ្នាំ២០០២ នោះមក ឃើញមានចំណាត់ការតិចតួចណាស់។ នៅឆ្នាំ២០០៧ គណៈកម្មាធិការជាតិទន្លេមេគង្គថៃ បានលើកឡើងនូវក្តីបារម្ភយ៉ាងខ្លាំងពាក់ព័ន្ធនឹងក្របខណ្ឌនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។[87] នៅឆ្នាំ២០០៩ វិទ្យាស្ថានច្បាប់បរិស្ថានបានធ្វើការពិនិត្យឡើងវិញបន្ថែមទៀត[88] និងបានវាយតម្លៃ សំណើក្របខណ្ឌស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការវាយតម្លៃបរិស្ថាន ក្នុងបរិបទនៃវិធីអនុវត្តល្អបំផុតនៅលើពិភពលោកនិងបានផ្តល់នូវសេចក្តីព្រាងក្របខណ្ឌដែលបានពិនិត្យកែសម្រួល។[89] គណៈកម្មការទន្លេមេគង្គនៅតែបានតាំងចិត្តអនុវត្តក្របខណ្ឌវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន តាមផែនការយុទ្ធសាស្ត្រ២០០៦-២០១០ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥។ ប៉ុន្តែ ចាប់តាំងពីមានការពិនិត្យឡើងវិញនៅឆ្នាំ២០០៩ ដោយវិទ្យាស្ថានច្បាប់បរិស្ថាននោះមក ពុំមានការបោះជំហានទៅមុខពាក់ព័ន្ធការអនុម័តក្របខណ្ឌនោះទេ។

---

[87] King, p.2.

[88] Establishing a Transboundary Environmental Impact Assessment Framework for the Mekong River Basin, an Assessment of the Draft Mekong River Commission TbEIA Framework, Environmental Law Institute, April 2009.

[89] King, p.1.

## កិច្ចព្រមព្រៀងបរិស្ថានមហាអនុតំបន់ទន្លេមេគង្គ

មានការព្យាយាមរៀបចំបង្កើតកិច្ចព្រមព្រៀងបរិស្ថានមហាអនុតំបន់ទន្លេមេគង្គ ជាការឆ្លើយតបថ្នាក់តំបន់ទៅនឹងការប្រែប្រួលអាកាសធាតុ នៅឆ្នាំ២០០៩។ កាលពីខែមករា ឆ្នាំ២០០៩ អង្គការមូលនិធិសត្វព្រៃពិភពលោក បានប្រគល់បេសកកម្មឲ្យមានការសិក្សាសារតារ ដោយពិនិត្យឡើងវិញលើក្របខណ្ឌច្បាប់នៅមហាអនុតំបន់ទន្លេមេគង្គ រួមទាំងកិច្ចព្រមព្រៀងក្នុងតំបន់ និងពហុភាគី និងការរៀបចំច្បាប់ថ្នាក់ជាតិនៃបណ្ដាប្រទេសមហាអនុតំបន់ទន្លេមេគង្គផង។ របាយការណ៍នេះបានកត់សម្គាល់ថា វាជារឿងខុសធម្មតាដែលមហាអនុតំបន់ទន្លេមេគង្គ គ្មានកិច្ចព្រមព្រៀងបរិស្ថានមហាអនុតំបន់។

មានកិច្ចពិភាក្សាដែលផ្ដោតយ៉ាងខ្លាំងលើ ការប្រើប្រាស់កិច្ចព្រមព្រៀងថ្នាក់តំបន់ដើម្បីជំរុញការបន្សុាំទៅនឹងការផ្លាស់ប្ដូរអាកាសធាតុ។ ទោះបីជា មានកិច្ចប្រជុំពិភាក្សាមួយដែលបានប្រារព្ធឡើងនៅទីក្រុងបាងកកនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ក៏ដោយ ក៏ពុំមានការតាមដានបន្ថែម ឬការអភិវឌ្ឍគំនិតសម្រាប់ កិច្ចព្រមព្រៀងបន្សុាំការប្រែប្រួលអាកាសធាតុក្នុងតំបន់ឡើយ។ ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ បណ្ដារដ្ឋាភិបាលបានរៀបចំការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមប្រទេស ជាជាងប្រើវិធីសាស្ត្រតំបន់។

ដូចបានរកឃើញដោយលោក Peter King អាចមានហេតុផលមួយចំនួន ចំពោះការបរាជ័យក្នុងការរៀបចំបង្កើតកិច្ចព្រមព្រៀងបរិស្ថានថ្នាក់តំបន់សម្រាប់មហាអនុតំបន់ទន្លេមេគង្គ។[90] ប៉ុន្តែ ក៏អាចថា មានហេតុផលចម្បងដែលកិច្ចព្រមព្រៀងបរិស្ថានពុំមានភាពជឿនលឿនទៅមុខដោយសារខ្វះឆន្ទៈនយោបាយនៅចំពោះមុខភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចពិភពលោក។ ប្រសិនបើ គ្មានឆន្ទៈនយោបាយទេ នោះកិច្ចព្រមព្រៀងបរិស្ថាននឹងមិនមានភាពជឿនលឿនទៅមុខឡើយ។ ហេតុផលផ្សេងទៀត ក៏អាចថាមកពី កិច្ចព្រមព្រៀងបរិស្ថានតំបន់ នៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ត្រូវបានចង្អុលយ៉ាងច្បាស់ឲ្យប្រើប្រាស់ទន្លេ ដូចជា ទន្លេមេគង្គ និងទន្លេសាលវីន និងគម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីដែលមានបញ្ហានយោបាយមិនចុះសម្រុងគ្នាយ៉ាងក្ដៅគគុក ទាំងនៅក្នុងប្រទេស ទាំងរវាងបណ្ដាប្រទេសជិតខាង។

នៅតំបន់ទន្លេមេគង្គ (និងតំបន់អាស៊ានកាន់តែធំ) សក្ដានុភាពដែលអាចបណ្ដាលឲ្យមានផលប៉ះពាល់បរិស្ថានអវិជ្ជមានធ្ងន់ធ្ងរក៏ត្រូវបានទទួលស្គាល់ដែរ ជាពិសេសទាក់ទងនឹងការអភិវឌ្ឍធនធានទឹក ការដឹកជញ្ជូនទំនិញប្រកបដោយគ្រោះថ្នាក់ ការបាត់បង់ជីវចម្រុះ និងចំហាយ

[90] Presentation by Dr. Peter King, July 2009.

ខ្យល់ក្តៅ ឆ្លងដែនជាដើម។ កម្មវិធីបរិស្ថានស្នូលនិងគំនិតផ្តួចផ្តើមអភិរក្សច្រករបៀងជីវចម្រុះនៃមហាអនុតំបន់ទន្លេមេគង្គ ជាពិសេស ដោះស្រាយកង្វល់អំពីផលប៉ះពាល់ឆ្លងដែនដែលបណ្តាលមកពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់។[91] ការអភិវឌ្ឍស្ថាប័នឆ្លងដែនផ្សេងទៀត រួមមាន សមាគមផ្លូវដែកមហាតំបន់ទន្លេមេគង្គ មជ្ឈមណ្ឌលសម្របសម្រួលថាមពលតំបន់ និងការិយាល័យសម្របសម្រួលទេសចរណ៍ទន្លេមេគង្គ និងស្ថាប័នផ្សេងៗទៀត។[92]

កិច្ចព្រមព្រៀងសម្រួលចរាចរណ៍ដឹកជញ្ជូនឆ្លងដែននៃមហាអនុតំបន់មេគង្គ (ឆ្នាំ១៩៩៩) មានចែងផ្នែកជាក់លាក់អំពីការដឹកជញ្ជូនទំនិញប្រកបដោយគ្រោះថ្នាក់[93] ដែលគេកំណត់និយមន័យថា "សារធាតុ និងរបស់របរទាំងឡាយ ដែលអាចបង្កផលប៉ះពាល់ដល់ ប្រយោជន៍បរិស្ថាន សុខភាព សុវត្ថិភាព និងសន្តិសុខជាតិ"។ ប្រសិនបើ ភាគីជាប់កិច្ចសន្យាអនុញ្ញាតដោយឈរលើមូលដ្ឋានជាក់ស្តែងតាមករណីនីមួយៗ ដែលជាចលនាដឹកទំនិញឆ្លងដែនប្រកបដោយគ្រោះថ្នាក់ ដូចបានកំណត់និយមន័យខាងលើ ភាគីទាំងនោះ គប្បីត្រូវតម្រូវឲ្យមានការអនុវត្តវិធានការពេញលេញទៅតាមអនុសាសន៍អង្គការសហប្រជាជាតិស្តីពីការដឹកជញ្ជូនទំនិញប្រកបដោយគ្រោះថ្នាក់/បទបញ្ជាគំរូ (គំរូបទបញ្ជាអង្គការសហប្រជាជាតិ) និង / ឬកិច្ចព្រមព្រៀងអឺរ៉ុបស្តីពីការដឹកជញ្ជូនទំនិញអន្តរជាតិប្រកបដោយគ្រោះថ្នាក់តាមផ្លូវគោក។

## លក្ខខណ្ឌតម្រូវឲ្យមានប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដោយប្រសិទ្ធភាព

លក្ខខណ្ឌតម្រូវឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដោយប្រសិទ្ធភាព មាន៖

- ការបង្កើតនិតិវិធីវាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព
- ការកំណត់មន្ត្រីទំនាក់ទំនងក្នុងប្រទេស ដើម្បីទទួលខុសត្រូវក្នុងការប្រស្រ័យទាក់ទងរវាងប្រទេសម្ចាស់គម្រោង និងប្រទេស ឬបណ្តាប្រទេសរងផលប៉ះពាល់
- ឱកាសសម្រាប់ការចូលរួមជាសាធារណៈស្មើគ្នាក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទាំងសម្រាប់សាធារណជននៃប្រទេសរងផលប៉ះពាល់ និងសាធារណជននៃប្រទេសម្ចាស់គម្រោង

---

[91] The CEP-BCI is Administered by ADB and overseen by the environment ministries of the six countries that form the Greater Mekong Subregion Working Group on Environment - http://www.adb.org/countries/gms/sector-activities/environment.

[92] Comments from Dr Peter King.

[93] More details on the Greater Mekong Subregion Cross-Border Transport Facilitation Agreement are available at http://www.gms-cbta.org/uploads/resources/15/attachment and at ADB_TF_CBTA_Full_Text_gms-cbta-instruments-history.pdf.

- ការជូនដំណឹងទៅមន្ត្រីទំនាក់ទំនងនៃប្រទេសរងផលប៉ះពាល់ឲ្យបានកាន់តែឆាប់កាន់តែល្អ នូវព័ត៌មានពាក់ព័ន្ធ
- ការទទួលខុសត្រូវរួមគ្នា ក្នុងការផ្ដល់ឱកាសឲ្យមានការចូលរួមជាសាធារណៈ ក្នុងតំបន់ ដែលអាចប្រឈមផលប៉ះពាល់ដោយសារគម្រោងដែលស្នើឡើង
- ការទទួលខុសត្រូវរួមក្នុងការចែកចាយឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងក្នុងការដាក់ជូន និងបញ្ជូនឯកសារទៅមន្ត្រីទំនាក់ទំនងរបស់ប្រទេសជាម្ចាស់គម្រោង
- លក្ខខណ្ឌតម្រូវដែលប្រទេសជាម្ចាស់គម្រោងធ្វើការពិចារណាលើសំណើសុំពីប្រទេសរងផលប៉ះពាល់ដើម្បីឈានដល់ការសម្រេចចិត្តលើគម្រោង ឬសកម្មភាព
- ផ្ដល់សេចក្ដីសម្រេចរបស់ប្រទេសម្ចាស់គម្រោងមួយច្បាប់ និងផែនការគ្រប់គ្រងបរិស្ថាន ឬលក្ខខណ្ឌអនុម័ត និង
- យន្តការសម្រាប់ទូទាត់ដំណើរវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

ការណែនាំរបស់គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប កំណត់នូវវិធីអនុវត្តល្អបំផុតមួយចំនួនដែលសមស្របចំពោះបណ្ដាប្រទេសនៅតំបន់មេគង្គ៖

- ការគាំទ្រផ្នែកហិរញ្ញវត្ថុអាចជាការចាំបាច់៖ សម្រាប់បកប្រែកម្រងឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅជាភាសារបស់ប្រទេសដែលរងផលប៉ះពាល់, បកប្រែយោបល់របស់សាធារណជន និងអនុសាសន៍នានាទៅជាភាសារបស់ប្រទេសស្នើគម្រោងវិញ, ផ្សព្វផ្សាយឯកសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (រួមទាំង កូនសៀវភៅផ្សព្វផ្សាយ) នៅក្នុងប្រទេសជិតខាង, ចំណាយសម្រាប់ការផ្សព្វផ្សាយព័ត៌មានតាម កាសែត វិទ្យុ ទូរទស្សន៍ អ៊ីម៉ែល ឬអ៊ីនធើណិត, និងសម្រាប់រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ
- គប្បីត្រូវផ្ដល់ដំណឹងទៅបណ្ដាប្រទេសជិតខាង អំពីសំណើគម្រោងដែលអាចបណ្ដាលឲ្យមានផលប៉ះពាល់ឆ្លងដែន ឲ្យបានកាន់តែឆាប់ កាន់តែល្អ ព្រមទាំងទទួលបានព័ត៌មានបែបនេះមិនយូរជាងសាធារណជន នៅក្នុងប្រទេសអ្នកស្នើគម្រោងឡើយ
- គ្រប់ប្រទេសដែលអាចនឹងទទួលរងរងផលប៉ះពាល់ ដោយគម្រោងដែលស្នើសុំ ទាំងប្រទេសដែលជាអ្នកស្នើសុំគម្រោង ទាំងប្រទេសជិតខាង គប្បីត្រូវរួមគ្នាទទួលខុសត្រូវក្នុងការផ្សព្វផ្សាយព័ត៌មានអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រមូលយោបល់ដែលប្រជាជនរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធផ្ដល់ជូនមកពិចារណា ក្នុងដំណើរការធ្វើសេចក្ដីសម្រេច និង

- យោបល់ទាំងអស់ដែលទទួលបានពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ពីភាគីពាក់ព័ន្ធ នៅក្នុងប្រទេសដែលអាចប្រឈមផលប៉ះពាល់គប្បីត្រូវលើកយកទៅពិចារណាក្នុង ការធ្វើការសម្រេចអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងថា ការសម្រេចចុងក្រោយគប្បីត្រូវប្រកាសផ្សាយនៅតាមបណ្ដាប្រទេសជិតខាង។

ការចូលរួមជាសាធារណៈដែលជាផ្នែកមួយយ៉ាងសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនជួយជំរុញឲ្យមានតម្លាភាព និងភាពស្របច្បាប់ក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចំពោះបណ្ដាគម្រោងដែលមានផលប៉ះពាល់ឆ្លងដែន។ ការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែនដែលធ្វើឡើងដោយគ្មានការចូលរួមជាសាធារណៈសមល្មម អាចដោះស្រាយកង្វល់ពីប្រទេសមួយទៅប្រទេសមួយតែប៉ុណ្ណោះ ប៉ុន្តែមិនបានគិតដល់បញ្ហាធំៗនៅមូលដ្ឋាន និងមិនបានគិតដល់ព័ត៌មានយ៉ាងមានតម្លៃពីជនជាតិដើមភាគតិចនៅមូលដ្ឋានឡើយ។ មានយន្តការទទួលមតិប្រកបដោយប្រសិទ្ធភាពអាចធានាថា កិច្ចខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការដោះស្រាយកង្វល់របស់មូលដ្ឋាននៅក្នុងប្រទេសជិតខាងត្រូវបានបង្កើតឡើងក្នុង ផែនការពិនិត្យតាមដាន និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន ដែលធ្វើបែបនេះអាចបញ្ចៀសជម្លោះនាពេលអនាគតក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការគម្រោង។

ការណែនាំរបស់គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប បញ្ជាក់ថា ទោះបីជាមានតម្រូវការឲ្យពិចារណាបញ្ហាតាមនីតិវិធីគ្មានពីរក្នុង ការបង្កើតឲ្យមានការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនក៏ដោយ ក៏គំនិតនិងវិធីសាស្ត្រតាមអនុសាសន៍ភាគច្រើនដែលមានរៀបរាប់នៅក្នុងគោលការណ៍ណែនាំទាំងនេះត្រូវអនុវត្តចំពោះ គម្រោងដែលស្នើសុំដែលមានផលប៉ះពាល់ឆ្លងដែនដែរ។ តាមន័យម្យ៉ាងទៀត គោលការណ៍និងវិធីសាស្ត្រដូចគ្នាអំពីការចូលរួមជាសាធារណៈ ត្រូវអនុវត្តទាំងក្នុងប្រទេសស្នើគម្រោង និងក្នុងប្រទេសជិតខាង ទោះបីជាយន្តការរបស់ស្ថាប័នអាចខុសគ្នាក៏ដោយ។

## ការសង្ខេបបញ្ចប់គំនិតអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតាមបណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គ

មានសំណេរច្រើនអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅតាមប្រទេសនានានៅតំបន់ទន្លេមេគង្គ។ ហើយការវិភាគភាគច្រើនបានផ្តោតលើការប្រៀបធៀបរវាងបណ្តាប្រទេសនៅតាមទន្លេមេគង្គក្រោម និងប្រទេសចិន ឬជប៉ុន ឬកូរ៉េ។ នេះគឺជាការវិភាគដំបូងដែលបានប្រៀបធៀប ប្រទេសទាំងប្រាំមួយនេះ។ ពីការពិនិត្យឡើងវិញលើច្បាប់និងបទប្បញ្ញត្តិ ដែលបានបង្កើតមូលដ្ឋានសម្រាប់សៀវភៅនេះ និងសង្ខេបអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន *តំបន់ទន្លេមេគង្គ៖ ការវិភាគប្រៀបធៀបការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅតាមបណ្តាប្រទេសតាមដងទន្លេមេគង្គក្រោម*[94] គេអាចសង្កេតឃើញថា មានភាពស្រដៀងគ្នាមួយចំនួន ក្នុងនីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលបានអនុម័តដោយបណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គ។ ហើយក៏មានភាពខុសគ្នាមួយចំនួនធំគួរឲ្យចាប់អារម្មណ៍ដែរ។ ភាពខុសគ្នាយ៉ាងខ្លាំងនោះអាចត្រូវបានរកឃើញទៅតាមវិធីដែលអង្គភាពពាក់ព័ន្ធក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានធ្វើការវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងថា តើការសម្រេចចុងក្រោយលើគម្រោងត្រូវធ្វើឡើងដោយរបៀបណា។ មានកិច្ចសហប្រតិបត្តិការថ្នាក់តំបន់កាន់តែខ្លាំងឡើងៗ ហើយការចែករំលែកវិធីអនុវត្តល្អក្នុងតំបន់អាចជំរុញឲ្យមានវិធីអនុវត្តដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានកាន់តែល្អប្រសើរ។

ដំណាក់កាលនៃការពិនិត្យតាមដាន ការប្រតិបត្តិ និងការពង្រឹងការអនុវត្ត ក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាទូទៅនៅទន់ខ្សោយនៅឡើយ។ ខណៈដែលមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងលើការរៀបចំ និងការពិនិត្យឡើងវិញលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលឈានទៅរកការសម្រេចចិត្តលើគម្រោង (អនុម័ត ឬការបដិសេធ) នោះ នៅមានការយកចិត្តទុកដាក់តិចតួចលើការពង្រឹងការអនុវត្ត និងប្រតិបត្តិ ផែនការគ្រប់គ្រងបរិស្ថាន។ មានកិច្ចខិតខំប្រឹងប្រែងតិចតួច ក្នុងការធានាថា បណ្តាលក្ខខណ្ឌដែលបានអនុម័ត ត្រូវបានប្រតិបត្តិតាម និងថា រាល់ការប្តេជ្ញាចិត្តរបស់គម្រោងត្រូវបានបំពេញដោយអ្នកស្នើសុំគម្រោង។

មានកត្តាបួនយ៉ាងដែលមានលក្ខណៈរួម ចំពោះប្រព័ន្ធវាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្នាក់ជាតិ គឺ៖ ទីមួយ គ្រប់ប្រទេសមានការពិនិត្យបញ្ជីគម្រោង។ ទីពីរ គ្រប់ប្រទេសមានវិធីសាស្ត្រតាមលំដាប់ថ្នាក់ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ទីបី គ្រប់ប្រទេស ផ្តល់សិទ្ធិទទួលបាន

[94] Available online at the following website: http://www.pactworld.org/sites/default/files/local-updates-files/MPE_Mekong_EIA_Briefing_Final.pdf.

ព័ត៌មាន។ ទីបួន គ្រប់ប្រទេសផ្តល់ឱកាសឲ្យមានការចូលរួមជាសាធារណៈនៅស្ទើរគ្រប់ជំហាន ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

## ការពិនិត្យបញ្ជី

គ្រប់ប្រទេសបានអនុម័តបញ្ជីពិនិត្យគម្រោង។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានរៀបចំតាក់តែងឡើង ដើម្បីធានាថា គម្រោងទាំងអស់ "ដែលអាចបង្កផលប៉ះពាល់បរិស្ថាន"[95] ត្រូវតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ បញ្ជីបែបនេះ ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ ជាធម្មតា វាកំណត់ថា តើត្រូវអនុវត្ត ការពិនិត្យបរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែរឬទេ ឬថា តើវាមិនចាំបាច់តម្រូវឲ្យវាយតម្លៃទេ។ នៅប្រទេសថៃ ដំណើរការពិនិត្យ ក៏ត្រូវកំណត់ដែរ ប្រសិនបើ មានលក្ខខណ្ឌតម្រូវឲ្យមានការវាយតម្លៃផលប៉ះពាល់ជាក់លាក់ផ្នែកសុខភាព។

## វិធីសាស្ត្រតាមលំដាប់ថ្នាក់ក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

បញ្ជីពិនិត្យនេះ ក៏មានប្រាប់អំពីលំដាប់ថ្នាក់នៃការវាយតម្លៃដែរគឺពី គ្មានការវាយតម្លៃទៅ ការពិនិត្យបរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ លើសពីនេះទៅទៀតប្រទេសខ្លះមានទម្រង់នៃការវាយតម្លៃបរិស្ថាន ជាជាងគ្មានជម្រើសនៃការវាយតម្លៃ (កម្ពុជានិងវៀតណាម) ។ នៅក្នុងប្រទេសខ្លះទៀត ប្រសិនបើ ការពិនិត្យបរិស្ថានដំបូង បង្ហាញថា គម្រោងអាចនឹងបង្កឱ្យមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ នោះអង្គភាពវាយតម្លៃហេតុប៉ះពាល់បរិស្ថាដាក់លក្ខខណ្ឌតម្រូវឲ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

## សិទ្ធិទទួលបានព័ត៌មាន

គ្រប់ប្រទេសអនុញ្ញាតឱ្យប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងមានសិទ្ធិទទួលបានព័ត៌មាន។ ឧទាហរណ៍ ប្រទេសថៃ មានភាពជឿនលឿន ក្នុងការផ្តល់សិទ្ធិទទួលព័ត៌មានយ៉ាងទូលំទូលាយ។ ប៉ុន្តែ នៅប្រទេសខ្លះ វាមិនចេះតែច្បាស់ជានិច្ចថា តើត្រូវផ្តល់ព័ត៌មានអ្វី ហើយនៅក្នុងដំណាក់កាលណានៃដំណើរការនោះទេ។ ប្រទេសភូមា មានចែងច្បាស់ថា ឯកសារណាត្រូវដាក់ឲ្យប្រើប្រាស់ជាសាធារណៈនៅក្នុងពេលវេលាជាក់លាក់។ ទោះជាយ៉ាងនេះក្តី ក៏នីតិវិធី

[95] This phrase has been the subject of considerable debates and discussion. The aim of EIA is to ensure that these impacts are identified, assessed and mitigated.

នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មិនមានចែងច្បាស់ទេ ក្នុងច្បាប់និងបទបញ្ញាអំពីសិទ្ធិទទួលបានព័ត៌មាន និងព័ត៌មានជាអប្បបរមាដែលត្រូវផ្តល់ជូន។

**ការចូលរួមជាសាធារណៈ**

គ្រប់ប្រទេសផ្តល់ឱកាសឲ្យមានការចូលរួមជាសាធារណៈនៅស្ទើរគ្រប់ជំហាន ក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ប៉ុន្តែ ជារឿយៗ នោះគឺជាការសន្យាដែលមិនត្រូវបានបំពេញ។ បញ្ហាប្រឈមមួយ ក្នុងបញ្ហាប្រឈមធំៗបំផុត ដែលឥឡូវនេះកំពុងត្រូវបានដោះស្រាយ គឺត្រូវធ្វើយ៉ាងណាដើម្បីជំរុញ និងបង្កើនការចូលរួមជាសាធារណៈ និងការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងតំបន់ដើម្បីបង្កើនការអភិវឌ្ឍ និងការអនុវត្តគម្រោង។

**ឧបសម្ព័ន្ធ ១៖ តារាងរៀបរាប់ចំណុចសំខាន់ៗនៃគម្រោង**[96]

| ខ្លឹមសារបង្ហាញសង្ខេប | កំណត់សម្គាល់អំពីសេចក្តីណែនាំ |
|---|---|
| 1. វិស័យ និងអនុវិស័យ | ឧ. ផលិតកម្មថាមពល វារីអគ្គិសនី |
| 2. ទំហំ | ទំហំអាចត្រូវគិតជាក្រឡាផ្ទៃ (ឬប្រវែង ប្រសិនបើវាជាផ្លូវ ឬគម្រោងខ្សែផ្សេងៗទៀត) ផលិតកម្ម ជំពូក/ប្រភេទ ចំនួនបុគ្គលិក ទុនវិនិយោគលើគម្រោង |
| 3. ទីតាំង | ខ្នាតផែនទីទូទៅ ១:២០០០០០ ឬ ១:២០០០០ អាស្រ័យលើប្រភេទនៃគម្រោង។ ផែនទីនេះគប្បីត្រូវមានបង្ហាញលក្ខណៈធម្មជាតិសំខាន់ៗ ដូចជា ផ្ទៃទឹក ព្រៃឈើ ។ល។ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ (ផ្លូវ ស្ពាន ជាដើម) និងភូមិឋានរស់នៅរបស់ប្រជាជន នៅជិតគម្រោង ជាដើម។ ក្នុងករណីគម្រោងអភិវឌ្ឍន៍ទីក្រុង តំបន់ងាយមានប្រតិកម្ម (សាលារៀន វត្ត ទីផ្សារ ការដ្ឋាន ឬវិមានដែលមានសារសំខាន់ខាងវប្បធម៌ តំបន់ពាណិជ្ជកម្ម។ល។) គប្បីត្រូវបង្ហាញឲ្យបានច្បាស់។ |
| 4. សមាសភាគគម្រោង | • សំណង់ផលិតកម្មសំខាន់ៗ<br>• ហេដ្ឋារចនាសម្ព័ន្ធខាងក្នុង<br>• ហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងបរិក្ខារចម្បងៗ |
| 5. កាលវិភាគទូទៅ | បង្ហាញដ្យាក្រាមដោយមានការកំណត់ពេលវេលាតាមការគ្រោងទុកអំពី៖<br>• ការសិក្សា (រួមទាំង ការសិក្សាអំពីការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន)<br>• ការអនុញ្ញាត ឬផ្តល់អាជ្ញាបណ្ណ<br>• កិច្ចព្រមព្រៀងសម្បទាន<br>• ការរៀបចំបង្កើត កិច្ចសន្យាលម្អិត<br>• បណ្តាសកម្មភាពមុនពេលសាងសង់<br>• បណ្តាសកម្មភាពពេលសាងសង់<br>• ប្រតិបត្តិការ<br>• ការបញ្ឈប់ការប្រើប្រាស់ការដ្ឋាន ពេលបិទ ក្រោយ |

[96] Laos EIA Guidelines, MONRE, 2012.

| | |
|---|---|
| | ពេលបិទ |
| 6. អង្គការចាត់តាំងនៃគម្រោង | តារាងអង្គការចាត់តាំង ការគ្រប់គ្រង តួនាទី និងការទទួលខុសត្រូវ។ល។ |
| **ដំណាក់មុនពេលសាងសង់ និងក្នុងពេលសាងសង់** | |
| 7. កាលវិភាគសកម្មភាព | ដ្យាក្រាមដោយមានបង្ហាញមាសភាគសំខាន់ៗ និងបណ្តាសកម្មភាពសាងសង់ចម្បងៗតាមសមភាគនីមួយៗ និងវិធានការកាត់បន្ថយផលប៉ះពាល់ដែលពាក់ព័ន្ធ |
| 8. ទីតាំងសមាសភាគគម្រោង | ផែនទីការដ្ឋាន (ខ្នាត 1: 50.000 ឬ 1: 10.000) ដោយមានទីតាំងនៃសមាសភាគគម្រោង ដូចជា ផ្លូវថ្នល់ ជំរុំ រ៉ែ រោងចក្រកែច្នៃ ឃ្លាំង ទំនប់កាករ៉ែ អាងស្តុកទឹក បន្ទប់អគ្គិសនី ខ្សែបញ្ជូនភ្លើង ស្ពាន។ល។ |
| 9. លក្ខណៈគម្រោង | ការរៀបរាប់អំពីលក្ខណៈសំខាន់ៗនីមួយៗរបស់គម្រោង៖<br>• សម្ភារៈ (បរិមាណ ប្រភេទ ប្រភព)<br>• បរិក្ខារ គ្រឿងយន្ត<br>• គំនូររចនាតាមទស្សនៈ: តារាងបញ្ជីជម្រើសនានាដែលបានពិចារណានិងវាយតម្លៃ។ ពិចារណាតែលើជម្រើសប្រាកដនិយម និងអាចធ្វើទៅបានយ៉ាងសមរម្យ |
| 10. ពលកម្ម | • កម្លាំងពលកម្មដែលបានរំពឹងទុក ប្រសិនបើអាចធ្វើបាន ចូររៀបរាប់ខ្លីៗអំពីកម្លាំងពលកម្មតាមប្រភេទការងារនីមួយៗ<br>• ប្រភពដើមនៃកម្លាំងពលកម្មដែលបានរំពឹងទុក<br>• ប្រភេទនិងទីតាំងនៃកន្លែងស្នាក់នៅរបស់កម្មករ<br>• ការតាំងចិត្តផ្នែកសុខភាពនិងសុវត្ថិភាព |
| **ដំណាក់កាលប្រតិបត្តិការ** | |
| 11. ស្ថានភាពទូទៅអំពីប្រតិបត្តិការ | ការរៀបរាប់សង្ខេបអំពីសមាសភាគគម្រោង រួមទាំងដំណើរការនិងបច្ចេកវិទ្យាផលិតកម្ម អគារគ្រឿងបរិក្ខារ និងហេដ្ឋារចនាសម្ព័ន្ធ។<br>ការបង្ហាញដែលមើលឃើញអំពីគម្រោងដែលបានបញ្ចប់ (ឧ. រូបគូរដោយដៃ ប្លង់) |

| | |
|---|---|
| | ការបង្ហាញទិន្នន័យផលិតកម្ម ដូចជា៖<br>• វត្ថុធាតុដើម (បរិមាណ/ឆ្នាំ, ប្រភេទ គុណភាព និងលក្ខណៈ ប្រភព)<br>• ការប្រើប្រាស់ទឹកនិងថាមពល ព្រមទាំងប្រភព<br>• លទ្ធផល៖ ផលិតផល (បរិមាណ លក្ខណៈ) អនុផល សំណល់ និងកាកបញ្ចេញចោលផ្សេងៗទៀត) |
| 12. ការវិភាគប្រតិបត្តិការ | ដ្យាក្រាមពេលវេលាដែលបង្ហាញសមាសភាគសំខាន់ៗ និង ប្រតិបត្តិការ/ដំណើរការចម្បងៗនិងវិធានការកាត់បន្ថយរបស់សមាសភាគនីមួយៗ |
| 13. ផែនទីបង្ហាញការដ្ឋាន | ផែនទីប្លង់ការដ្ឋាន (ខ្នាត 1: 20.000 ឬខ្នាតល្អប្រសើរជាង) ដែលបង្ហាញទីតាំងនៃសមាសភាគប្រតិបត្តិការសំខាន់ៗ |
| 14. សមាសភាគ | រៀបរាប់ដោយសង្ខេបអំពីសមាសភាគនីមួយៗ៖<br>• អគារនិងសម្ភារៈបរិក្ខារ បច្ចេកវិទ្យា ការកែច្នៃដោយមានដ្យាក្រាមលំហូរសាមញ្ញងាយយល់<br>• ទីតាំង និងការដាក់បង្ហាញ<br>• គំនូររចនាតាមទស្សនៈ<br>• ដ្យាក្រាមរំហូរ៖ សម្ភារៈ ទឹក ថាមពល សំណល់ និង កាកបញ្ចេញចោលផ្សេងៗទៀត<br>• ការទុកដាក់សម្ភារៈ ឃ្លាំង<br>• គ្រប់គ្រងសំណល់រឹងនិងរាវ<br>• ការដឹកជញ្ជូន (មធ្យោបាយ ពេលវេលា ផ្ទុក ផ្លូវ) |
| 15. ពលកម្ម | កម្លាំងពលកម្មដែលបានគេរំពឹងទុក (ប្រសិនបើអាចធ្វើទៅបាន កម្លាំងពលកម្មក្នុងប្រភេទការងារនីមួយៗ) និងប្រភពដើមនៃកម្លាំងពលកម្ម<br>ប្រភេទនិងទីតាំងនៃកន្លែងស្នាក់នៅរបស់កម្មករ<br>ការតាំងចិត្តផ្នែកសុខភាពនិងសុវត្ថិភាព |
| **ដំណាក់កាលបញ្ឈប់ការប្រើប្រាស់ការដ្ឋាន ពេលបិទ ក្រោយពេលបិទ** | |
| 16. ទស្សនៈទូទៅ | លក្ខខណ្ឌតម្រូវឲ្យមានផែនការបិទ (យុទ្ធសាស្ត្រ គោលនយោបាយ គោលបំណងសំខាន់ៗ កាលវិភាគពេលវេលា ថវិកា។ល។) |

## ឧបសម្ព័ន្ធ ២៖ ច្បាប់ពាក់ព័ន្ធ

- (ច្បាប់ស្តីពី) កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦
- អនុក្រឹត្យស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩
- ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ (លេខ៣៧៦ ប្រក. ប.ស្ថ ឆ្នាំ២០០៩)
- ប្រកាសស្តីពីការចុះបញ្ជីក្រុមហ៊ុនទីប្រឹក្សាសម្រាប់ការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (លេខ ២១៥ ប្រ.ក ប.ស្ថ ឆ្នាំ២០១៤)
- ប្រកាសស្តីពីប្រតិភូកម្មអំណាចទៅមន្ទីរបរិស្ថានស្តីពីបញ្ហាទាក់ទងនឹងគម្រោងវិនិយោគតាងនាមក្រសួងបរិស្ថាន (លេខ ២៣០ ប្រ.ក ប.ស្ថ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៥)
- ប្រកាសអន្តរក្រសួងស្តីពីការពិនិត្យលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់អាជីវកម្មរ៉ែ និងអាជីវកម្មរ៉ែខ្នាតតូច (លេខ ១៩១ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦)
- ប្រកាសរួម (សេចក្តីប្រកាស) ស្តីពីតម្លៃសេវាសាធារណៈ នៃក្រសួងបរិស្ថាន លេខ ៩៩៩ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២
- អនុក្រឹត្យលេខ១៤៦ស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥

## ឧបសម្ព័ន្ធ ៣៖ ប្រភពបន្ថែម

បញ្ជីពិនិត្យសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការពិនិត្យបរិស្ថានដំបូង នៅក្នុងប្រទេសមួយចំនួននៃតំបន់ទន្លេមេគង្គ

- មានដាក់ឲ្យប្រើប្រាស់ និងអាចចូលទៅមើលបានលើបណ្ដាញអ៊ីធើណិត តាមអាសយដ្ឋាននេះ៖ https://www.earthrights.org/publications

សេចក្ដីព្រាងគោលការណ៍ណែនាំថ្នាក់តំបន់ស្ដីពីការចូលរួមជាសាធារណៈក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- មានដាក់ឲ្យប្រើប្រាស់ និងអាចចូលទៅមើលបានលើបណ្ដាញអ៊ីធើណិត តាមអាសយដ្ឋានដូចខាងក្រោម៖ http://eia.mekongcitizen.org

សេចក្ដីព្រាងគោលការណ៍ណែនាំរបស់ប្រទេសកម្ពុជា ស្ដីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

- កំពុងដំណើរការធ្វើសេចក្ដីព្រាងនៅឡើយ ពុំទាន់ដាក់ឲ្យប្រើប្រាស់ ហើយពុំទាន់មាននៅលើបណ្ដាញអ៊ីនធើណិតនៅឡើយ។

Mekong Legal Network


**AMAZON OFFICE**
INFOPERU@EARTHRIGHTS.ORG
Casilla Postal 195
Miraflores 18, Lima, Peru

**MEKONG OFFICE**
INFOASIA@EARTHRIGHTS.ORG
P.O. Box 123
Chiang Mai University
Chiang Mai, 50202, Thailand

**MYANMAR OFFICE**
INFOASIA@EARTHRIGHTS.ORG
Yangon, Myanmar

**U.S. OFFICE**
INFOUSA@EARTHRIGHTS.ORG
1612 K St NW, Suite 401
Washington, DC 20006

EarthRightsIntl
WWW.EARTHRIGHTS.ORG